សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ប្រាតិភោគដោយអនុប្បទាន

ស្រាវជ្រាវចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ កញ្ញា **លេខ មុយលាំង**
កញ្ញា **ផល ស្រីដាច**

ណែនាំដោយ
បណ្ឌិត **ទេព សុខ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី២៣

ឆ្នាំចូលសិក្សា ២០១៩
ឆ្នាំសរសេរសារណា ២០២៣

# **សេចក្តីថ្លែងអំណរគុណ**

យើងខ្ញុំឈ្មោះ **លេខ មុយលាំង** និង **ផល ស្រីដាវ** ជានិស្សិតថ្នាក់បរិញ្ញាប័ត្រផ្នែក នីតិសាស្ត្រ នៃ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច សូមលំអោនកាយគោរព និង ថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅបំផុតចំពោះ៖

លោកអ្នកមានគុណដ៏ធំធេងទាំងពីរគឺ **លោកឪពុក** និង **អ្នកម្តាយ** ដែលបានចិញ្ចឹមបីបាច់ថែរក្សា និង ផ្តល់នូវសេចក្តីស្រឡាញ់ មេត្តាករុណា អប់រំទូន្មានអោយមានសេចក្តីព្យាយាមអំណត់ក្លាហាន និង ទំនុកបម្រុងគ្រប់បែបយ៉ាងទាំងសម្ភារៈសិក្សា ទាំងស្មារតី និងថវិកាឱ្យកូនបានសិក្សារៀនសូត្ររហូតដល់ បច្ចុប្បន្ននេះ។

**ឯកឧត្តមបណ្ឌិត លុយ ចន្ណា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានអនុញ្ញាតិឱ្យយើងខ្ញុំបានចូលសិក្សានៅសាកលវិទ្យាល័យនេះ និងបង្កលក្ខណៈងាយស្រួលដល់ការសិក្សារបស់យើងខ្ញុំ។

លោកសាស្ត្រាចារ្យ **បណ្ឌិត ទេព សុខ** ជាសាស្ត្រចារ្យណែនាំដែលបានចំណាយពេលដ៏មានតម្លៃក្នុងការបង្ហាត់បង្រៀន ផ្តល់ការណែនាំល្អៗ ថែមទាំងបានផ្តល់ឯកសារមួយចំនួនដល់យើងខ្ញុំដើម្បីរៀបចំសរសេរសារណាបញ្ចប់ការសិក្សានេះផងដែរ។

ថ្នាក់ដឹកនាំ បុគ្គលិកសិក្សា នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ ដែលបានលើកទឹកចិត្ត ព្រមទាំងបាន ត្រួសត្រាយផ្លូវដល់យើងខ្ញុំក្នុងការសិក្សារយៈពេល បួនឆ្នាំនេះ។

សូមសម្តែងនូវអំណរគុណដ៏ជ្រាលជ្រៅបំផុត និង មិនអាចបំភ្លេចបានចំពោះអ្នក និពន្ធ និង អ្នកប្រាជ្ញ ព្រមទាំងទស្សនៈវិទូល្បីៗក្នុងពិភពលោក ដែលបានចងក្រងជាឯកសា ជាហេតុធ្វើឱ្យយើងខ្ញុំបានសិក្សាស្រាវជ្រាវ ពីស្នាដៃរបស់លោកក្នុងការបំពេញកិច្ចការស្រាវជ្រាវនាពេលកន្លងមក។

សូមមេត្តាទទួលនូវអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះឧបការគុណដ៏ធំធេងអំពីយើងខ្ញុំ។

ជាទីបញ្ចប់ យើងខ្ញុំសូមប្រសិទ្ធិពរជ័យ សិរីបវរជូនដល់ លោកអ្នកមានគុណ ឯកឧត្តម លោកជំទាវ លោក លោកស្រី និង សាស្ត្រចារ្យ ទាំងអស់ សូមបានប្រកបតែជោគជ័យគ្រប់ភារកិច្ច និងសូមទទួលបាននូវពុទ្ធិ ទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

អស់រយៈពេល៤ឆ្នាំ កន្លងមក ដែលយើងខ្ញុំទាំងពីរនាក់បានសិក្សាលើមុខវិជ្ជាជាច្រើននៅក្នុងជំនាញនីតិសាស្ត្រនេះ ព្រមទាំងមាន លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យទាំងអស់ នៅចាំបង្ហាត់បង្រៀនយ៉ាង ស្វះស្វែង សុទ្ធតែអ្នកមានបទពិសោធន៍នៅក្នុងការបង្រៀនដល់សិស្ស និស្សិត ប្រកបដោយសមត្ថភាព ចំណេះដឹង និងជំនាញ ។ ដោយហេតុនេះហើយទើបធ្វើឱ្យយើងខ្ញុំទទួលបាននូវចំណេះដឹង និងបានសិក្សាស្រាវជ្រាវ សរសេរសារណាបញ្ចប់ឆ្នាំសិក្សា។ ការសរសេរសារណានេះ គឺទាមទារឱ្យមានការតស៊ូ ព្យាយាមអត់ធ្មត់ ក្នុងការស្រាវជ្រាវរកអ្វីដែលថ្មីទាក់ទងទៅនឹងបទបញ្ញត្តិថ្មីៗ ដើម្បីកុំឱ្យមានការភ័ន្តច្រលំ និងអនុវត្តខុសអំពីច្បាប់កំណត់ ។

យើងខ្ញុំមានការចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើប្រធានបទ **ប្រាតិភោគដោយអនុប្បទាន** នេះ ដោយសារតែប្រជាជន ក៏ដូចជាអ្នកសិក្សាច្បាប់ជាច្រើនរូបនៅមានការភន្ត័ច្រឡំរវាងប្រាតិភោគដោយអនុប្បទាន និង បញ្ចាំ ហើយម្យ៉ាងទៀត ប្រធានបទមួយនេះក៏បានរួមចំណែកក្នុងការជួយដល់អ្នកសិក្សា គ្រប់រូបបានយល់ដឹងកាន់តែច្បាស់អំពី ប្រាតិភោគដោយអនុប្បទានផងដែរ។

យើងខ្ញុំបានជ្រើសរើសយកការសរសេរសារណាមួយនេះមក ដែលផ្តោតសំខាន់ទៅលើប្រធានបទ ប្រាតិភោគដោយអនុប្បទាន ដែលមានសារៈសំខាន់ណាស់នៅក្នុងសង្គមយើងបច្ចុប្បន្ន ទុកគ្រាន់ជាឯកសារសម្រាប់ជំនួយដល់ប្អូនៗជំនាន់ក្រោយ។ យើងឃើញហើយថា ការរស់នៅក្នុងសង្គមយើងបច្ចុប្បន្ននេះមិនអាចជៀសឆ្ងាយពីបញ្ហាសេដ្ឋកិច្ចនោះឡើយ ជាពិសេសសម្រាប់ពាណិជ្ជករ និងវិនិយោគិនជាដើម ។

យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ស្នាដៃមួយនេះនឹងជាប្រយោជន៍ ក្នុងការចូលរួមវិភាគទានដល់បុគ្គលគ្រប់រូប និង គ្រប់វិស័យ ជាពិសេសគឺក្នុងវិស័យសេដ្ឋកិច្ចដែលជាចលករសំខាន់ក្នុងការចូលរួមអភិវឌ្ឍសង្គមជាតិទាំងមូលផងដែរ។

ទន្ទឹមនឹងនេះ ការចងក្រងសារណានេះឡើង និងមានចំណុចខ្វះចន្លោះដោយប្រការណាមួយ ដែលត្រូវកែតម្រូវនាពេលខាងមុខ ដូចច្នេះយើងខ្ញុំទាំងពីរនាក់ សូមមេត្តាខន្តីអភ័យទោសចំពោះរាល់កំហុសខុសឆ្គងក្នុងការតាក់តែងនេះ ហើយក៏សូមស្វាគមន៍នូវការរិះគន់ដើម្បីស្ថាបនាពីសំណាក់អ្នកស្រាវជ្រាវគ្រប់រូប។ ហើយយើងខ្ញុំក៏សង្ឃឹមថា សារណាមួយនេះ នឹងក្លាយទៅជាចំណេះដឹងថ្មីរបស់អ្នកអានចំពោះប្រធានបទមួយនេះដែរ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........ ១

## ជំពូកទី១

## សញ្ញាណគតិយុត្តនៃសិទ្ធិលើប្រាតិភោគដោយអនុប្បទាន

**១.១ របបគតិយុត្តសំខាន់ៗទាក់ទងនឹងសិទ្ធិប្រាតិភោគដោយអនុប្បទាន** ........ **៣**

១.១.១ និយមន័យ ........ ៤

១.១.២ អ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ........ ៤

១.១.៣ ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ........ ៤

១.១.៤ ចលនវត្ថុ ........ ៤

**១.២ ប្រភពនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន** ........ **៥**

**១.៣ គោលបំណង និង ផលប្រយោជន៍នៃសិទ្ធិប្រាតិភោគដោយអនុប្បទាន** ........ **៥**

**១.៤ លក្ខខណ្ឌសុពលភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន** ........ **៦**

១.៤.១ លក្ខខណ្ឌគ្រឹះ ........ ៧

១.៤.២ លក្ខខណ្ឌទម្រង់ ........ ១០

១.៤.៣ លក្ខខណ្ឌតតាំង ........ ១១

**១.៥ អានុភាពតតាំងនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន** ........ **១២**

១.៥.១ ការប្រគល់ដោយជាក់ស្តែង ........ ១២

១.៥.២ ការកាន់កាប់ដោយការព្រមព្រៀង ........ ១៣

១.៥.៣ ការប្រគល់ដោយសង្ខេប ........ ១៣

១.៥.៤ ការផ្ទេរការកាន់កាប់ដោយបញ្ជា ........ ១៤

## ជំពូកទី២

## អានុភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន

**២.១. ទំហំនៃអានុភាពរបស់សិទ្ធិប្រាតិភោគដោយអនុប្បទាន** ........ **១៥**

២.១.១ អានុភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទានចំពោះផល ........ ១៦

២.១.២. ឧបាទេសកម្មលើវត្ថុ ........ ១៧

**២.២ ការចាត់ចែងវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន** ........ **១៨**

២.២.១ ការចាត់ចែងវត្ថុដែលជាកម្មវត្ថុដោយអ្នកធានាដោយអនុប្បទាន.................................. ១៨
២.២.១.១ ចលនវត្ថុធម្មតា.................................................................................... ១៨
២.២.១.២ ចលនវត្ថុផ្គុំគ្នា...................................................................................... ១៩
២.២.២ ការចាត់ចែងវត្ថុដែលជាកម្មវត្ថុដោយម្ចាស់សិទ្ធិដោយអនុប្បទាន ................................ ២០
**២.៣ ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា ........................................................ ២១**
**២.៤ បញ្ញត្តិពិសេសនៅក្នុងសិទ្ធិប្រាតិភោគដោយអនុប្បទាន........................................ ២២**
២.៤.១ អានុភាពនៃការឃាត់ទុក ........................................................................... ២២
២.៤.២ ករណីកិច្ចរបស់ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានក្នុងការរក្សាទុកវត្ថុដែលជាកម្មវត្ថុ...... ២៣
២.៤.៣ សិទ្ធិទាមទារឱ្យសងសោហ៊ុយរបស់ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន.....................២៣

## ជំពូកទី៣
## ការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន

**៣.១ ការអនុវត្តក្នុងការចាត់ចែងវត្ថុ**.............................................................................២៤
៣.១.១ ការប្តូរវត្ថុដែលជាកម្មវត្ថុជាប្រាក់.............................................................................២៤
៣.១.២ អនុប្បទានជាស្ថាពរ ...............................................................................................២៥
**៣.២ ការប្រគល់វត្ថុដែលជាកម្មវត្ថុឱ្យអ្នកបង្កើត ........................................................២៦**
**៣.៣ ករណីកិច្ចត្រូវបង់ប្រាក់ដែលលើស.....................................................................២៦**
**៣.៤ សិទ្ធិទទួលយកមកវិញរបស់អ្នកបង្កើត.....................................................................២៦**
**៣.៥ ស្ថាប័នមានសមត្ថកិច្ចអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន.............................២៦**
៣.៥.១ ក្រសួងយុត្តិធម៌ .................................................................................................. ២៦
៣.៥.២ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ............................................................................. ២៧
៣.៥.៣ ស្ថាប័នតុលាការ.................................................................................................... ២៨
**៣.៦ ការអនុវត្តក្នុងការប្រកបអាជីវកម្មប្រាតិភោគដោយអនុប្បទាន ..............................២៨**
៣.៦.១ ការប្រកបអាជីវកម្មប្រាតិភោគដោយអនុប្បទានមានអាជ្ញាបណ្ណ.................................. ២៨
៣.៦.២ ការប្រកបអាជីវកម្មប្រាតិភោគដោយអនុប្បទានពុំមានអាជ្ញាបណ្ណ.................................២៩
**៣.៧ អត្រាការប្រាក់ក្នុងការប្រកបអាជីវកម្មប្រាតិភោគដោយអនុប្បទាន ................. ៣០**
**សេចក្តីសន្និដ្ឋាន ............................................................................................. ៣២**
**អនុសាសន៍.................................................................................................. ៣៤**

**ឯកសារយោង**

**បញ្ជីឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

ប្រទេសកម្ពុជាជាប្រទេសមួយដែលប្រកាន់យករបបទីផ្សាសេរី។[1] មានន័យថាផ្តល់សិទ្ធិសេរីភាព ព្រមទាំងលទ្ធភាពខ្ពស់ដែលជម្រុញឱ្យមានការប្រកួតប្រជែងស្មើរគ្រប់វិស័យ។ ដោយឃើញថាមនុស្សជាច្រើនបានជួបប្រទះនូវបញ្ហាសេដ្ឋកិច្ច ដូចជាការចំណាយច្រើនជាងចំណូល ការរកស៊ីខាតបង់ ឬ កត្តាផ្សេងទៀតហេតុនេះហើយទើបមនុស្សមួយចំនួនធំធ្វើកិច្ចប្រតិបត្តិការខ្ចីប្រាក់ ដែលជាមធ្យោបាយមួយអាចជួយសម្រួលដល់បញ្ហាសេដ្ឋកិច្ចរបស់ពួកគេក្នុងគ្រាមានអាសន្ន។ ជាក់ស្តែងក្នុងការអនុវត្តកន្លងមកនេះ ការខ្ចីប្រាក់អាចប្រព្រឹត្តទៅបានតាមវិធីជាច្រើន ដែលវិធីខ្លះមានលក្ខណៈងាយស្រួល រីឯវិធីខ្លះមានលក្ខណៈស្មុគស្មាញ។ ចំពោះផ្លូវច្បាប់ ការខ្ចីប្រាក់អាចប្រព្រឹត្តទៅបានតាមវិធីមួយចំនួនដូចជា ការធ្វើកិច្ចសន្យាខ្ចីបរិភោគ ដែលជាកិច្ចសន្យាមួយប្រភេទដែលត្រូវបានគេប្រើប្រាស់ជាញឹកញាប់នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃក៏ដូចជានៅក្នុងកិច្ចការរកស៊ីផងដែរ ព្រោះកិច្ចសន្យានេះបានដើរតួនាទីយ៉ាងសំខាន់ដើម្បីធានានូវភាពសុចរិត និងភាពស្មោះត្រង់រវាងអ្នកឱ្យខ្ចី និងអ្នកខ្ចី ក្នុងគោលបំណងធានាពីភាពច្បាស់លាស់ក្នុងការអនុវត្តសិទ្ធិ និងកាតព្វកិច្ចរបស់គូភាគី។

ដោយឃើញថាមនុស្សជាច្រើនមិនទាន់បានយល់ច្បាស់ពី **ប្រាតិភោគដោយអនុប្បទាន** ហេតុដូចនេះហើយទើបប្រធានបទ **ប្រាតិភោគដោយអនុប្បទាន** នេះនឹងត្រូវបានសរសេរឡើង ក្នុងបំណងបំពេញតម្រូវការដល់ម្ចាស់អាជីកម្មក៏ដូចជាសិស្សផ្សេងៗ បានយល់កាន់តែច្បាស់អំពីប្រធានបទនេះជៀសវាងការចាញ់បោកពីជនទុច្ចរិតមួយចំនួន។

ទោះបីប្រទេសកម្ពុជាមានក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ដែលបានចែងអំពីប្រាតិភោគដោយអនុប្បទានក្តីនៅក្នុងជំពូកទី៦ នៃគន្ថីទី៥ ក៏ដូចជាប្រកាសរបស់ប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។[2] ទាក់ទិននឹងប្រភេទនៃអាជីវកម្មបញ្ចាំ និងប្រាតិភោគដោយអនុប្បទានយ៉ាងណាក្តី ក៏ការអនុវត្តជាក់ស្តែងនៅតែមិនមានតម្លាភាពមួយចំនួននៅតែបន្តកើតឡើងជារឿយៗ។ បញ្ហាដែលកើតឡើងនោះគឺការច្រឡំមិនដាច់រវាង **បញ្ចាំ** និង **ប្រាតិភោគដោយអនុប្បទាន**។ ហេតុដូចនេះហើយទើបសារណានេះលេចឡើងដើម្បីឆ្លើយតបទៅនឹងសំណួរមួយចំនួនដូចជា៖

(1) តើអ្វីទៅជាប្រាតិភោគដោយអនុប្បទាន?

(2) តើត្រូវធ្វើដូចម្តេចដើម្បីឱ្យប្រាតិភោគដោយអនុប្បទានមានអានុភាព?

---

[1] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២១ កញ្ញា ១៩៩៣, មាត្រា ៥៦(១)

[2] ប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលេខ ០៣០ សហវ.ប្រក បានកំណត់អំពីប្រភេទនៃអាជីវកម្មបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន https://m.freshnewsasia.com/index.php/en/freshnewsplus/281966-2023-03-12-05-00-35.html

(3) តើមាននីតិវិធីអ្វីខ្លះក្នុងការអនុវត្តប្រាតិភោគដោយអនុប្បទាន?

ដោយផ្អែកទៅលើចំណោទបញ្ហាដូចដែលបានរៀបរាប់ខាងលើ សារណាមួយនេះនឹងលើកឡើងពីសញ្ញាណគតិយុត្តផ្សេងៗដែលទាក់ទងនិងប្រាតិភោគដោយអនុប្បទាន លក្ខខណ្ឌដែលត្រូវបំពេញក្នុងការធ្វើកិច្ចសន្យាខ្ចីប្រាក់ដោយប្រាតិភោគដោយអនុប្បទាន ព្រមទាំងនីតិវិធីផ្សេងទៀត។

គោលបំណងនៃកិច្ចការស្រាវជ្រាវនេះ មាន ៣ចំណុច (ទី១) ចង់ស្វែងរកចំណេះដឹងថ្មីៗស្តីពីប្រាតិភោគដោយអនុប្បទាន ដល់អ្នកសិក្សាទាំងឡាយដែលតែងតែមានការភ័ន្តច្រឡំរវាង បញ្ចាំ និង ប្រាតិភោគដោយអនុប្បទាន (ទី២) វែកញែកប្រធានបទឱ្យកាន់តែមានភាពងាយស្រួលក្នុងការយល់ (ទី៣) ចង់លើកយកអានុភាពនិងនីតិវិធីក្នុងការអនុវត្តប្រាតិភោគដោយអនុប្បទាន មកបង្ហាញឲកាន់តែច្បាស់។

គួរបញ្ជាក់ផងដែរថាវិសាលភាពនៃខ្លឹមសារសារណានេះ នឹងបង្ហាញត្រឹមតែចំណុចពាក់ព័ន្ធមួយចំនួនទៅនឹងសញ្ញាណទូទៅ លក្ខខណ្ឌ ការអនុវត្ត យោងទៅតាមក្រមរដ្ឋប្បវេណីរបស់ប្រទេសកម្ពុជាឆ្នាំ២០០៧ ប្រការចុះដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុព្រមទាំងឯកសារផ្សេងទៀតដែលទាក់ទងនឹង ប្រាតិភោគដោយអនុប្បទានតែប៉ុណ្ណោះ មិនបានលើកយកការបញ្ចាំ មកធ្វើការវែកញែកនោះទេ។

វិធីសាស្រ្តប្រមូលឯកសារ គឺបានប្រមូលនៅបណ្ណាល័យនីតិសាស្រ្តរបស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និង វិទ្យាសាស្រ្តសេដ្ឋកិច្ច ប្រពន្ធ័អ៊ីនធ័រណេត គ្រុបតេលេក្រាម វេបសាយបណ្ណាល័យរបស់សាលា និងឯកសារផ្សេងៗទៀត។ ការអានច្បាប់ ឯកសារទាំងនេះ បានក្លាយជាវិធីសាស្រ្តក្នុងការរៀបចំចងក្រងសារណានេះឱ្យលេចចេញជារូបរាងឡើង។ បន្ថែមពីលើនេះទៅទៀត ការស្វែងរកឯកសារតាមគេហទំព័រនានា ក៏បានផ្តល់នូវទិន្នន័យជាក់លាក់ ជាប្រយោជន៍ឱ្យអត្ថន័យរបស់សារណាកាន់តែមានភាពស៊ីជម្រៅបន្ថែមទៀត។

ការសិក្សាស្រាវជ្រាវមួយនេះ មានសារៈសំខាន់ដល់សង្គមជាតិកម្ពុជា ទាំងផ្នែកសេដ្ឋកិច្ច និង សង្គមផងដែរ។ ការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទានមានតម្លាភាព ផ្តល់ភាពងាយស្រួលចំពោះការមូលធនធានសម្រាប់ការចិញ្ចឹមជីវិត ក៏ដូចជាការប្រកបអាជីវកម្ម ការធ្វើពាណិជ្ជកម្ម តូច ធំ ដែលជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ប្រជាជនកម្ពុជា។

ដើម្បីឱ្យមានភាពងាយស្រួលក្នុងការសិក្សាស្វែងយល់ទៅលើប្រធានសារណានេះឱ្យកាន់តែច្បាស់ និងមានភាពស៊ីជម្រៅនោះ សារណានេះ នឹងបង្ហាញពីៈ

ជំពូកទី១ ស្តីអំពី សញ្ញាណគតិយុត្តនៃសិទ្ធិលើប្រាតិភោគដោយអនុប្បទាន។

ជំពូកទី២ ស្តីអំពី អានុភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន។

ជំពូកទី៣ ស្តីអំពី លំហូរនីតិវិធីក្នុងការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន។

# ជំពូកទី១

# សញ្ញាណគតិយុត្តនៃសិទ្ធិលើប្រាតិភោគ ដោយអនុប្បទាន

# ជំពូកទី១

# សញ្ញាណគតិយុត្តនៃសិទ្ធិលើប្រាតិភោគដោយអនុប្បទាន

ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានរដ្ឋសភាអនុម័ត នៅថ្ងៃទី០៥ ខែតុលា ឆ្នាំ ២០០៧ នាសម័យប្រជុំលើកទី៧ នីតិកាលទី៣ និងត្រូវបានព្រឹទ្ធសភាយល់ស្រប នៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៤ នីតិកាលទី២ ដោយប្រកាសឲ្យប្រើនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ ២០០៧ និងចូលជាធរមានទៅតាមការកំណត់របស់ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ហើយប្រកាសឱ្យប្រើនៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ មានបញ្ញត្តិអំពីប្រាតិភោគដោយអនុប្បទាន។ នៅក្នុងក្រមរដ្ឋប្បវេណីគេឃើញមានប្រភេទប្រាតិភោគថ្មីមួយ នៅក្នុងប្រភេទនៃប្រាតិភោគប្រត្យក្ស ដែលនោះគឺប្រាតិភោគដោយអនុប្បទាន។ ក្នុងក្រមរដ្ឋប្បវេណីនេះដែរ ក៏បានកំណត់ប្រាតិភោគដោយអនុប្បទាន ដែលត្រូវបានចង្អុលបង្ហាញនៅក្នុងជំពូកទី ៦ នៃគន្ថីទី៦ ស្តីពីការធានាកាតព្វកិច្ច។ ដោយហេតុថាប្រធានបទសារណារនេះធ្វើការបកស្រាយអំពីប្រាតិភោគដោយអនុប្បទាន ដូច្នេះហើយ ទើបសារណារនេះនឹងមិនធ្វើការបកស្រាយទៅលើសិទ្ធិប្រត្យក្សផ្សេងក្រៅពីប្រាតិភោគដោយអនុប្បទាននេះឡើយ។ ក្នុងការបង្ហាញអំពីសញ្ញាណគតិយុត្តនៃប្រាតិភោគដោយអនុប្បទានឲ្យកាន់តែងាយស្រួលយល់ និងច្បាស់លាស់ទៅលើការបកស្រាយបន្តទៅនេះ នឹងធ្វើការចង្អុលបង្ហាញនូវ (១)របបគតិយុត្តសំខាន់ៗទាក់ទងនឹងសិទ្ធិប្រាតិភោគដោយអនុប្បទាន (២)ប្រភពនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន (៣)គោលបំណង និងផលប្រយោជន៍នៃសិទ្ធិប្រាតិភោគដោយអនុប្បទាន (៤)លក្ខខណ្ឌសុពលភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន និង (៥)អានុភាពតតាំងនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន ។

## ១.១ របបគតិយុត្តសំខាន់ៗទាក់ទងនឹងសិទ្ធិប្រាតិភោគដោយអនុប្បទាន

### ១.១.១ និយមន័យ

តើប្រាតិភោគដោយអនុប្បទានគឺជាអ្វី? ជាបឋមដើម្បីឈានដល់ការបកស្រាយឱ្យបានស៊ីជម្រៅទៅលើប្រធានបទដែលបានចោទសួរខាងលើ យើងគប្បីត្រូវឈ្វេងយល់អំពីពាក្យគន្លឹះជាមុនសិន ពាក្យ ប្រាតិភោគ និង អនុប្បទាន។ បើយោងទៅតាមសន្ទានុក្រមរដ្ឋប្បវេណី អង់គ្លេស-ខ្មែរ-បារាំង បានឱ្យនិយមន័យពាក្យ **ប្រាតិភោគ** គឺ ជាការធានាដល់ម្ចាស់បំណុលក្នុង ការប្រមូលឥណទេយ្យ របស់ខ្លួនមកវិញ ឬជាមធ្យោបាយមួយដើម្បីសងកាតព្វកិច្ច។[3] រីឯពាក្យថា **អនុប្បទាន** មានន័យថា ការផ្ទេរសិទ្ធិ ឬទ្រព្យសម្បត្តិរបស់នរណាម្នាក់ដែលជាអនុប្បទាយីទៅឱ្យបុគ្គលម្នាក់ទៀត ដែលជាអនុប្បទានិក។[4] សរុបមក **ប្រាតិភោគដោយអនុប្បទាន** គឺជាកិច្ចធានាដល់ម្ចាស់

[3] សន្ទានុក្រមរដ្ឋប្បវេណីអង់គ្លេស-ខ្មែរ-បារាំង ឆ្នាំ២០០៧

[4] សន្ទានុក្រមរដ្ឋប្បវេណីអង់គ្លេស-ខ្មែរ-បារាំង ឆ្នាំ២០០៧

បំណុលតាមរយៈការផ្ទេរ សិទ្ធិ ឬទ្រព្យសម្បត្តិរបស់អនុប្បទាយី ដើម្បីធានាដល់អនុប្បទានិកក្នុងការប្រមូលឥណទេយ្យរបស់ខ្លួនមកវិញ ។

ជារួមមក តាមការបកស្រាយនិយមន័យខាងលើនេះមានន័យថា ប្រាតិភោគដោយអនុប្បទាន ជាកិច្ចធានាមួយសម្រាប់ម្ចាស់បំណុល ដោយផ្អែកលើការផ្ទេរសិទ្ធិ ឬ ទ្រព្យសម្បត្តិរបស់បុគ្គលណាម្នាក់ដែលអាចជាកូនបំណុល ឬតតិយជន ទៅឱ្យម្ចាស់បំណុលក្នុងការធានាដល់ការប្រមូលបំណុលរបស់ខ្លួនត្រឡប់មកវិញ។

### ១.១.២ អ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន

អ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន តាមអត្ថន័យដែលមានចែងក្នុងក្រមរដ្ឋប្បវេណី សំដៅទៅលើកូនបំណុល ឬ តតិយជនដែលបានធ្វើអនុប្បទាននូវចលនវត្ថុរបស់ខ្លួន ទៅកាន់ម្ចាស់បំណុល ដើម្បីធានានូវកាតព្វកិច្ចសងបំណុលរបស់ខ្លួន។

### ១.១.៣ ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន

ដោយយោងតាមក្រមរដ្ឋប្បវេណី «**ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន**» សំដៅទៅលើម្ចាស់បំណុលដែលអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានបានធ្វើអនុប្បទាននូវចលនវត្ថុឱ្យ ដើម្បីទទួលបាននូវការធានាបំណុល។

### ១.១.៤ ចលនវត្ថុ

មុននឹងធ្វើការសិក្សាទៅលើ និយមន័យនៃចលនវត្ថុ យើងត្រូវធ្វើការយល់ដឹងនូវអត្ថន័យនៃពាក្យ វត្ថុ និង អចលនវត្ថុ គឺជាមូលដ្ឋានគន្លឹះដ៏សំខាន់សម្រាប់ការបកស្រាយបន្ត។ ពាក្យ វត្ថុ សំដៅទៅលើរបស់ដែលមានរូបរាង ជាសារធាតុឧស្ម័ន ជាសារធាតុរាវ ជាសារធាតុរឹង ដែលវត្ថុត្រូវបែងចែកជា ២ គឺ ចលនវត្ថុ និង អចលនវត្ថុ។[5] ចំពោះ អចលនវត្ថុ សំដៅទៅលើដីធ្លី និងវត្ថុដែលនៅលើដីធ្លី ហើយមិនអាចផ្លាស់ប្តូរទីកន្លែងបាន ដូចជាអាគារ សំណង់ ដំណាំ រុក្ខជាតិ ជាអាទិ៍។[6] បន្ទាប់ពីក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ អធិប្បាយអំពីនិយមន័យនៃពាក្យ និង អចលនវត្ថុ រួចមក ក្រមនេះក៏កំណត់នូវនិយមន័យថា ចលនវត្ថុ ជាវត្ថុក្រៅពី អចលនវត្ថុ។[7] បន្ថែមពីនេះ ក្រមនេះក៏កំណត់បន្ថែមថា "បញ្ញត្តិស្តីពីចលនវត្ថុត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះទ្រព្យសម្បត្តិគ្មានរូបរាង ដែលអាចគ្រប់គ្រងបាន លើកលែងតែមានបញ្ញត្តិក្នុងច្បាប់ពិសេស។[8] ដូចនេះតាមអត្ថន័យនៃឃ្លាទាំងពីរខាង លើអាចបញ្ជាក់បានថា ចលនវត្ថុ សំដៅទៅលើវត្ថុក្រៅពីអចលនវត្ថុ រួមទាំងទ្រព្យសម្បត្តិគ្មានរូបរាងដែលអាច គ្រប់គ្រង

[5] ក្រមរដ្ឋប្បវេណី, មាត្រា១១៩

[6] ក្រមរដ្ឋប្បវេណី, មាត្រា១២០(២)

[7] ក្រមរដ្ឋប្បវេណី, មាត្រា១២០(៣)

[8] ក្រមរដ្ឋប្បវេណី, មាត្រា១២០(៥)

បានផងដែរ ដែលជាទូទៅ "ទ្រព្យសម្បត្តិគ្មានរូបរាងដែលអាចគ្រប់គ្រងបាន គឺជាវត្ថុអរូបិយ ដែលមាន ដូចជា សិទ្ធិ អគ្គិសនី កំដៅ ពន្លឺជាដើម"។[9]

## ១.២ ប្រភពនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន

ក្រមរដ្ឋប្បវេណីកម្ពុជា បានទទួលឥទ្ធិពលពីច្បាប់របស់ប្រទេសជប៉ុនក្នុងវិស័យឯកជន ប៉ុន្តែមិនមានន័យថា ក្រមរដ្ឋប្បវេណីកម្ពុជាមានអត្ថន័យ និងខ្លឹមសារដូចទៅនឹងរាល់វិធានគតិយុត្តនៅប្រទេសជប៉ុននោះទេ។ តែរាល់ការចងក្រងវិធានច្បាប់របស់ប្រទេសកម្ពុជាសុទ្ធសឹង តែឈរលើមូលដ្ឋាគ្រឹះនៃស្ថានភាពជាក់ស្តែង ឬបដិបទនៅក្នុងសង្គមកម្ពុជាផ្ទាល់តែម្តង។ យើងសង្កេតឃើញថា ប្រាតិភោគដោយអនុប្បទានទើបកើតមានឡើងនៅក្នុងឆ្នាំ២០០៧ តែប៉ុណ្ណោះ ដែលមានចែងក្នុងក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧។[10] ដោយហេតុមានការសហការជាមួយនឹង ភ្នាក់ងារកិច្ចសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) ដែលនាំឱ្យច្បាប់នៃប្រទេសជប៉ុន ជះឥទ្ធិពលមកលើក្រមរដ្ឋប្បវេណីរបស់កម្ពុជា ទើបមានការលេចឡើងមកប្រាតិភោគដោយអនុប្បទាននេះ។ បើយើងពិនិត្យទៅមើលលើក្រមរដ្ឋប្បវេណីនៃប្រទេសជប៉ុន ដែលជាប្រភពនៃក្រមរដ្ឋប្បវេណីនៃប្រទេសកម្ពុជាឆ្នាំ២០០៧ គឺមិនមានឃើញចែងឡើយអំពីបញ្ញត្តិស្តីពីប្រាតិភោគដោយអនុប្បទាន ពោលគឺការដោះស្រាយរាល់វិវាទ បញ្ហាទាំងនេះគឺធ្វើឡើងទៅតាមយុទ្ធសាស្ត្ររបស់តុលាការប្រទេសជប៉ុន។ ដូចដែលបានលើកឡើងនេះ ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាដែលបានប្រកាសនៅថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ ២០០៧ គឺមិនមែនបានមកពីក្រមរដ្ឋប្បវេណីនៃប្រទេសជប៉ុននោះទេ ពោលគឺបានទទួលយកនូវគោលគំនិតនៃបទប្បញ្ញត្តិស្តីពីប្រាតិភោគដោយអនុប្បទាន ដែលចេញពីការអនុវត្តកន្លងមករបស់ប្រទេសជប៉ុនតែប៉ុណ្ណោះ។

## ១.៣ គោលបំណង និង ផលប្រយោជន៍នៃសិទ្ធិប្រាតិភោគដោយអនុប្បទាន

អត្ថប្រយោជន៍នៃ សិទ្ធិប្រាតិភោគដោយអនុប្បទាន គឺជាការធានាសិទ្ធិលើបំណុលដោយអនុញ្ញាតឱ្យអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានអាចប្រើប្រាស់ និងបន្តការកាន់កាប់វត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគក្នុង កំឡុងពេលនៃការធ្វើប្រាតិភោគដោយអនុប្បទាន។[11] ជាគោលការណ៍ ប្រាតិភោគដោយអនុប្បទានកម្ពុជាមានលក្ខណៈដូចគ្នាច្រើនទៅនឹងបញ្ញត្តិប្រាតិភោគដោយអនុប្បទាននៅប្រទេសជប៉ុន ហើយទន្ទឹមនឹងការលេចឡើងនៃបញ្ញត្តិនេះ យើងឃើញមានសំណួរចោទសួរជាច្រើនថា តើគេបង្កើតប្រាតិភោគប្រភេទថ្មីនេះឡើងក្នុងគោលបំណងអ្វី ?

[9] គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី, សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ១, គម្ពីទី១-ទី៣ (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០០៩), ៩៨។

[10] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, ជំពូកទី៦

[11] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៨៤៨

យើងឃើញថា ការបង្កើតប្រាតិភោគដោយអនុប្បទាននេះ មានគោលបំណងដោះស្រាយ នូវផលវិបាកដែលកើតមានកន្លងមកនៅក្នុងរូបភាពនៃសិទ្ធិលើការបញ្ចាំ ហើយលើសពីនេះទៅទៀត វាបានផ្តល់នូវភាពងាយស្រួលទាំងកូនបំណុល និងម្ចាស់បំណុលផងដែរ។ ចំពោះកូនបំណុល ក្នុងការខ្ចីប្រាក់បុគ្គលណាម្នាក់ ខ្លួនអាចពុំចាំបាច់ធ្វើការផ្ទេរនូវចលនវត្ថុដោយផ្ទាល់ទៅម្ចាស់បំណុលនោះឡើយ។ នេះគឺជាគោលបំណងសំខាន់មួយ ហើយក៏ជាគុណប្រយោជន៍មួយ ដែលជាគោលគំនិតបង្កើតឲ្យមានប្រាតិភោគដោយអនុប្បទាននេះឡើង។ លើសពីនេះទៅទៀត សកម្មភាពនៃការប្រាក់ក្នុងរូបភាពជាប្រាតិភោគដោយអនុប្បទាន ពោលគឺការធ្វើអនុប្បទាននូវចលនវត្ថុរបស់ខ្លួនជាកំណត់ ទៅឱ្យម្ចាស់បំណុលដើម្បីធានាកាតព្វកិច្ចក្នុងការសងបំណុលរបស់ខ្លួន គឺជាសកម្មភាពមួយ ដែលកូនបំណុលអាចទទួលបានផលប្រយោជន៍ជាច្រើន ដូចជាអាចគ្រាន់តែធ្វើការផ្ទេរការកាន់កាប់ដោយប្រយោល ហើយខ្លួនអាចនៅតែកាន់កាប់លើចលនវត្ថុដែលបានធ្វើប្រាតិភោគនោះ និងរកប្រាក់ចំណូលពីវា។ ប្រាតិភោគដោយអនុប្បទានក៏បានផ្តល់ផលប្រយោជន៍ដល់ម្ចាស់បំណុលផងដែរ ដោយម្ចាស់បំណុលពុំចាំបាច់រងនូវហានិភ័យ ឬ ទទួលខុសត្រូវព្យសនកម្មដែលអាចនឹងកើតមានឡើងទៅលើចលនវត្ថុដែលជាកម្មវត្ថុឡើយ ក្នុងករណីដែលម្ចាស់បំណុលមិនធ្វើការកាន់កាប់លើវត្ថុនោះ។ ប៉ុន្តែទោះបីជាការបង្កើតប្រាតិភោគដោយអនុប្បទាននេះមានគុណសម្បត្តិជាច្រើនក្តី ទន្ទឹមនឹងនោះ ក៏វាកើតមានផងដែរនូវគុណវិបត្តដែលគួរឱ្យកត់សម្គាល់ ពោលគឺត្រង់ចំណុចដែលថា ម្ចាស់បំណុលមិនបានកាន់កាប់វត្ថុដែលជាកម្មវត្ថុប្រាតិភោគដោយអនុប្បទានដោយផ្ទាល់ ដែលក្នុងចំណុចនេះអាចបណ្តាលឱ្យមានវិវាទកើតឡើងដូចជា អ្នកបង្កើតប្រាតិភោគនោះ ធ្វើការលក់ដូរ ឬ ចាត់ចែងលើវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគ ឬ អ្នកបង្កើតយកវត្ថុដែលជាកម្មវត្ថុនោះរត់ចោលស្រុកជាដើម។ ទាំងអស់នេះសុទ្ធសឹងតែជាបញ្ហាអាចនឹងកើតមានឡើងដែលយើងគួរធ្វើការពិចារណា។

## ១.៤ លក្ខខណ្ឌសុពលភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន

ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងជំពូកទីមួយ ស្តីពីបទប្បញ្ញត្តិទូទៅបានឆ្លុះបង្ហាញពីគោលការណ៍សំខាន់ៗដែលបុគ្គលម្នាក់ៗត្រូវគោរពនិងប្រតិបត្តិតាម។ បន្ថែមពីលើនេះទៅទៀតនោះគោលការណ៍នៃការធានាសេចក្តីថ្លៃថ្នូររបស់មនុស្សម្នាក់ មានភាពស្មើគ្នាទាំងបុរស នារី និងសិទ្ធិទៅលើទ្រព្យសម្បត្តិដែលត្រូវបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញ។[12] សិទ្ធិប្រាតិភោគដោយអនុប្បទានត្រូវបានបង្កើតឡើងដោយការព្រមព្រៀងរវាងម្ចាស់បំណុល និង កូនបំណុល ឬ តតិយជនដែលផ្តល់ចលនវត្ថុសម្រាប់ប្រាតិភោគដោយអនុប្បទាន។[13] មានន័យថាប្រាតិភោគដោយអនុប្បទានត្រូវបានបង្កើតឡើង រវាងភាគីដោយការព្រមព្រៀងគ្នាទៅវិញទៅមក។ ពាក់ព័ន្ធនឹង

[12] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ២

[13] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ៨៤៩

កិច្ចសន្យាដើម្បីបង្កើតប្រាតិភោគដោយអនុប្បទានដែលមានអានុភាព អាចពិចារណាអំពីការតម្រូវឱ្យមានលិខិតយថាភូត ឬលិខិតឯកជន។ ការបង្កើតប្រាតិភោគដោយអនុប្បទាន ក្នុងទម្រង់បែបបទបំពេញដូចគ្នានឹងសិទ្ធិប្រាតិភោគប្រត្យក្សផ្សេងទៀតផងដែរ។

សិទ្ធិប្រាតិភោគដោយអនុប្បទានត្រូវបានបង្កើតឡើងដើម្បីធានាកាតព្វកិច្ច ហើយសិទ្ធិនេះត្រូវបានបង្កើតរវាងភាគីចាប់ពី ពីរនាក់ឡើងទៅ សិទ្ធិនេះមិនអាចបង្កើតឡើងដោយឯកឯងនោះទេ មានន័យថា ក្នុងការបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន គឺទាមទារឱ្យមានការព្រមព្រៀងគ្នាជាមួយនឹងគូរភាគីនៃកិច្ចសន្យាព្រមទាំង ត្រូវគោរពនូវគោលការមូលដ្ឋាននៃក្រមរដ្ឋប្បវេណីកម្ពុជាយើងផងដែរ។ យ៉ាងណាមិញសិទ្ធិប្រាតិភោគដោយ អនុប្បទាន គឺជាប្រភេទសិទ្ធិមួយក្នុងចំណោមសិទ្ធិប្រត្យក្ស មានន័យថាជាសិទ្ធិប្រាតិភោគប្រត្យក្សដែលបង្កើតឡើងដោយកិច្ចសន្យា។[14] ហេតុនេះហើយក្នុងការបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានរមែងត្រូវគោរពយ៉ាងខ្ជាប់ខ្ជួននូវលក្ខខណ្ឌផ្សេងៗ ដែលអាចឈានទៅរកសុពលភាពនៃកិច្ចសន្យា។ បញ្ញត្តិដែលបានបង្កើតឡើងនេះក្នុងគោលបំណងដោះស្រាយនូវផលវិបាកដែលកើតមានកន្លងមក ក្នុងរូបភាពនៃសិទ្ធិលើការបញ្ចាំដែលក្នុងនោះសិទ្ធិលើការបញ្ចាំកើតមានដោយកូនបំណុល ឬតតិយជនដែលបង្កើតសិទ្ធិលើការបញ្ចាំនោះប្រគល់វត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំទៅឱ្យម្ចាស់សិទ្ធិលើការបញ្ចាំ[15] ហើយម្ចាស់សិទ្ធិនៃការបញ្ចាំមិនអាចឱ្យអ្នកបង្កើតសិទ្ធិលើការបញ្ចាំនោះ កាន់កាប់ដោយផ្ទាល់លើវត្ថុបញ្ចាំនោះបានឡើយ។[16] យើងនឹងធ្វើការបកស្រាយអំពីតម្រូវការនៃការបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានដែលច្បាប់បានកំណត់រួមមាន៖ (១) លក្ខខណ្ឌគ្រឹះ (២) លក្ខខណ្ឌទម្រង់ និង (៣) លក្ខខណ្ឌតតាំង។

### ១.៤.១ លក្ខខណ្ឌគ្រឹះ

លក្ខខណ្ឌគ្រឹះ ជាកត្តាដ៏សំខាន់ឆ្ពោះទៅកាន់សុពលភាពនៃកិច្ចសន្យា ដែលរាល់ដំណើរការនៃការបង្កើតកិច្ចសន្យាទាំងឡាយតែងតម្រូវឱ្យគោរពតាមលក្ខខណ្ឌគ្រឹះ។ លក្ខខណ្ឌដែលខ្វះមិនបានរបស់កិច្ចសន្យាប្រាតិភោគដោយអនុប្បទាន គឺតម្រូវឱ្យគោរពនូវគោលការណ៍សិទ្ធិសេរីភាពរបស់គូភាគី ពោលគឺ បង្កើតដោយការព្រមព្រៀង ហើយត្រូវឱ្យភាគីមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបង្កើតកិច្ចសន្យា និងត្រូវមានកម្មវត្ថុសមស្របតាមច្បាប់កំណត់។

#### ក. ការព្រមព្រៀង

[14] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៧៦៧

[15] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៨១៨

[16] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៨១៩

កិច្ចសន្យាមានអានុភាពដោយសារសំណើ និងស្ទីការត្រូវគ្នាដោយការព្រមព្រៀងគ្នារវាងគូភាគីនៃកិច្ចសន្យា ពោលគឺការបង្កើតកិច្ចសន្យាត្រូវឈរលើឆន្ទៈសេរីភាពដោយមិនអាចមានការចាប់បង្ខំឡើយ។[17]

ដូចច្នេះ សិទ្ធិប្រាតិភោគដោយអនុប្បទាន ត្រូវបានបង្កើតឡើង ដោយការព្រមព្រៀងរវាងម្ចាស់បំណុល និងកូនបំណុល ឬ តតិយជន ដែលផ្តល់ចលនវត្ថុសម្រាប់ប្រាតិភោគដោយអនុប្បទាន។[18]

*ឧទាហរណ៍ លោក ក បានទៅខ្ចីប្រាក់លោក ខ ចំនួន ១០លានរៀល ដូចនេះលោក ក បានបង្កើតកិច្ចសន្យាប្រាតិភោគដោយអនុប្បទាន ដោយដាក់អនុប្បទានម៉ូតូរបស់ខ្លួនឱ្យលោក ខ ដើម្បីខ្ចីប្រាក់នោះ ប៉ុន្តែលោក ខ មិនព្រមឱ្យខ្ចីឡើយ។ ក្នុងករណីបានលើកឡើងនេះ លោក ក មិនអាចបង្ខិតបង្ខំទៅលើលោក ខ ដើម្បីធ្វើកិច្ចសន្យាឱ្យខ្លួនខ្ចីប្រាក់នោះទេ ព្រោះធ្វើដូច្នេះអាចបណ្តាលឱ្យកើតមាននូវវិការៈនៃកិច្ចសន្យា។*

គូរភាគីម្ខាងត្រូវធ្វើសំណើសុំបង្កើត កិច្ចសន្យាដែលមានឆន្ទៈភ្ជាប់ខ្លួនជាមួយនឹងចំណងគតិយុត្ត ហើយគូរភាគីម្ខាងទៀតត្រូវបង្ហាញឆន្ទៈ ទទួលយកសំណើរបស់ខ្លួននោះផងដែរ ទើបកិច្ចសន្យាអាចត្រូវបានបង្កើតឡើង វិការៈនឹងកើត មានឡើងប្រសិនបើមានប្រតិបត្តិការផ្ទុយពីការចែងនេះ។ អ្នកបង្ហាញឆន្ទៈអាចលុបចោលកិច្ចសន្យា បាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ដែលយោងតាមក្រមរដ្ឋប្បវេណីកម្ពុជាយើង វិការៈនៃកិច្ចសន្យារួមមាន ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយការភាន់ច្រឡំ ដោយការ ឆបោក ឬ ការគំរាមកំហែង ឬ ការបង្ហាញការមិនពិតរបស់ភាគីម្ខាងទៀត និង ការបង្ហាញឆន្ទៈត្រូវ បានធ្វើឡើងដោយអំពើឆ្លៀតឱកាសដោយមានគោលបំណងកេងយកចំណេញហួសហេតុ។[19]

**ខ. សមត្ថភាពគូរភាគី**

**ខ.១ សមត្ថភាពអ្នកបេង្កើតសិទ្ធិប្រាតេិភោគេដោយអនុប្បទាន**

សមត្ថភាពក្នុងការបង្កើតកិច្ចសន្យាប្រាតិភោគដោយអនុប្បទាន របស់អ្នកបង្កើតសិទ្ធិប្រាតិភោគ អនីតិជនដែលទទួលបានអត្តាធីនភាព អនីតិជនដែលអនុញ្ញាតឱ្យចាត់ចែងទ្រព្យសម្បត្តិដោយអ្នកមានសិទ្ធិដោយអនុប្បទាន សំដៅទៅលើសមត្ថភាពខាងឆន្ទៈ និងសមត្ថភាពក្នុងការធ្វើសកម្មភាព។ ជាទូទៅ អ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន អាចជានីតិបុគ្គល ឬរូបវន្តបុគ្គល។[20] ដោយសារនីតិបុគ្គល ជាបុគ្គលដែលបង្កើតឡើងដោយច្បាប់ ដូចនេះលក្ខខណ្ឌសមត្ថភាព ពុំចោទជាបញ្ហានោះទេ។ ប៉ុន្តែចំពោះរូបវន្តបុគ្គលវិញ លក្ខខណ្ឌនៃសមត្ថភាពត្រូវបានកំណត់ដោយច្បាប់ ដែលលក្ខខណ្ឌសមត្ថភាពនេះ កំណត់ឱ្យរូបវន្តបុគ្គលត្រូវតែជា នីតិជន អំណាចមេបា

---

[17] ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧, មាត្រា ៣៣៦.១

[18] ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧, មាត្រា ៨៨៩

[19] ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧, មាត្រា ៣៤៥, ចំណុច ក ខ និង គ

[20] ក្រមរដ្ឋប្បវេណី, មាត្រា៨៨៩

ឬ អ្នកអាណាព្យាបាល អនីតិជនដែលត្រូវបានអនុញ្ញាតឱ្យប្រកបអាជីវកម្ម ជនដែលមិនមែនជាជននៅក្រោមអាណាព្យាបាលទូទៅ ឬជនដែលមិនមែនជាជននៅក្រោមហិតូបត្ថម្ភ។[21]

### ខ.២ សមត្ថភាពម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន

បើតាមក្រមរដ្ឋប្បវេណី ចំពោះលក្ខខណ្ឌសមត្ថភាពរបស់ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន មិនមានភាពខុសគ្នាទៅនឹងអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានប៉ុន្មាននោះទេ គឺអាចជានីតិបុគ្គល អនុញ្ញាតឱ្យប្រកបអាជីវកម្ម ជនដែលមិនមែនជាជននៅក្រោមអាណាព្យាបាលទូទៅ ឬជនដែលមិនមែនជាជននៅបុគ្គលដែលមានសមត្ថភាពដូចជានីតិជន អនីតិជនដែលទទួលបានអត្តាធីនភាព អនីតិជនដែលត្រូវបានក្រោមហិតូបត្ថម្ភ។ ប៉ុន្តែប្រកាសស្តីពីការគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទានបញ្ជាក់ថា ដើម្បីទទួលបានសមត្ថភាពពេញលេញក្នុងការប្រកបអាជីវកម្មប្រាតិភោគដោយអនុប្បទានស្របច្បាប់ ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានត្រូវតែជានីតិបុគ្គលសញ្ជាតិខ្មែរ និងបានចុះបញ្ជីពាណិជ្ជកម្មស្របតាមច្បាប់នៅព្រះរាជាណាចក្រកម្ពុជា។[22] បន្ទាប់មក នីតិបុគ្គលខាងលើត្រូវធ្វើការចុះបញ្ជីប្រកបអាជីវកម្មប្រាតិភោគដោយអនុប្បទានបន្ថែមទៀត ដោយការចុះបញ្ជីត្រូវធ្វើឡើងនៅឯនាយកដ្ឋានគ្រប់គ្រងអាជីវកម្មអចលនវត្ថុបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន នៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំពោះម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាននេះដែលប្រកបអាជីកម្មខ្នាតមធ្យម និងធំ ឬ មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានីខេត្ត ចំពោះអាជីវកម្មខ្នាតតូច។ បន្ថែមពីនេះ អាជីវកម្មទទួលប្រាតិភោគដោយអនុប្បទានត្រូវមានដើមទុន ចាប់ពី ២០លានរៀលឡើងទៅ និងត្រូវតម្កល់ប្រាក់ធានា អាជីវកម្មចំនួន២% នៃដើមទុនផងដែរ។[23]

ប៉ុន្តែប្រកាសនេះពុំបានចែងអំពីការមិនគោរពលក្ខខណ្ឌសមត្ថភាពដែលអាចធ្វើឱ្យលុបចោល ឬ មោឃភាពនៃកិច្ចសន្យាប្រាតិភោគដោយអនុប្បទាននោះទេ។ ប៉ុន្តែករណីដែលម្ចាស់សិទ្ធិប្រាតិភោគដោយ អនុប្បទានមិនគោរពលក្ខខណ្ឌសមត្ថភាពនេះ នឹងត្រូវទទួលរងនូវពិន័យអន្តរការណ៍ចំនួន ៥,០០០,០០០ រៀល ចំពោះអាជីវកម្មខ្នាតតូច និង ៩,០០០,០០០ រៀល ចំពោះអាជីកម្មខ្នាតតូច និង ១០,០០០,០០០ រៀលចំពោះអាជីវកម្មខ្នាតមធ្យម និងធំ ដែលកំណត់នៅក្នុងប្រកាស ស្តីពីការគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំនឹងទទួលប្រាតិភោគដោយអនុប្បទាន(ទំហំដើមទុនអាជីវកម្មមានកំណត់នៅក្នុងឧបសម្ព័ន្ធទី២)។[24]

---

[21] ក្រមរដ្ឋប្បវេណី, មាត្រា១៦

[22] ក្រមរដ្ឋប្បវេណី, មាត្រា១៤ និងមាត្រា១៥

[23] ប្រកាសអាជីវកម្មបញ្ចាំ និង ប្រាតិភោគដោយអនុប្បទាន, ប្រការ ៦, ៧, ៩

[24] ប្រកាសអាជីវកម្មបញ្ចាំ និង ប្រាតិភោគដោយអនុប្បទាន, ប្រការ ៣៧

**ខ.៣ កម្មវត្ថុ**

ជាខ្លឹមសារសំខាន់នៃកិច្ចសន្យា ដែលកម្មវត្ថុនោះត្រូវតែជាក់លាក់ ដែលអាចធ្វើទៅបាន ឬបំពេញបាន និងស្របច្បាប់ មិនប៉ះពាល់ដល់របៀបរៀបរយសាធារណៈ ឬទំនៀមទំលាប់ល្អរបស់ប្រពៃណី ។ ការបង្ហាញឆន្ទៈដោយមិនពិតប្រាកដ និងដោយសេរីត្រូវវៀរចាកនូវវិការៈក្នុងការបង្ហាញឆន្ទៈដូចជា៖ ការភាន់ច្រឡំ ការឆបោក ការគំរាមកំហែង ការបង្ហាញការមិនពិត ឬការកេងចំណេញហួសហេតុ។[25]

នៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា បានបញ្ជាក់អំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលុបចោលកិច្ចសន្យាដែលបញ្ញត្តិថា សកម្មភាពដែលអាចលុបចោលបាន មានសុពលភាព រហូតដល់ពេលដែលអ្នកមានសិទ្ធិលុបចោលលុបចោលសកម្មភាពនោះ។[26] ក្នុងការអនុវត្ត សិទ្ធិលុបចោលកិច្ចសន្យាអាចធ្វើឡើងក្នុងរយៈពេល ៣ (បី) ឆ្នាំ បន្ទាប់ពីបានដឹងអំពីវិការៈនៃ ការព្រមព្រៀង ឬ ក្នុងកំឡុងពេល ១០ (ដប់) ឆ្នាំ គិតចាប់តាំងពីកាលបរិច្ឆេទនៃការបង្កើតកិច្ចសន្យា។ [27] ដូចនេះ បើកិច្ចសន្យាត្រូវបានរំលត់ នោះសិទ្ធិ និងកាតព្វកិច្ចក៏ត្រូវរលត់ដែរ តែក្នុងករណីមិនអនុវត្តការលុបចោលកិច្ចសន្យា សិទ្ធិនៃការលុបចោលនោះនឹងត្រូវបានរលត់នៅពេលផុតអាជ្ញាយុកាល។[28]

ជារួម ក្នុងការបង្កើតកិច្ចសន្យាប្រាតិភោគដោយអនុប្បទាន ទាមទារតម្រូវឱ្យមានជាចាំបាច់នូវល័ក្ខខ័ណ្ឌដែលបានលើកឡើងនោះគឺ "ការព្រមព្រៀង" ទើបការបង្កើតកិច្ចសន្យានោះមាន អានុភាពចំពោះមុខច្បាប់បាន។ ម្យ៉ាងវិញទៀត ការព្រមព្រៀងនោះត្រូវគោរពនូវគោលការណ៍ សេរីភាពរបស់គូភាគី ដោយគ្មានការបង្ខិតបង្ខំឡើយ បើពុំនោះទេនឹងអាចបណ្តាលឱ្យមានវិការៈក្នុងការបង្កើតកិច្ចសន្យាបាន។ ក្នុងស្ថានភាពជាក់ស្តែងនៅក្នុងសង្គមយើងនេះ ឃើញថាពុំសូវមានករណីប្រាតិភោគដោយអនុប្បទានកើតឡើងទេ ហើយករណីដែលកើតឡើងក៏មិនបានប្រទះឃើញនូវបញ្ហាលំបាកពាក់ព័ន្ធទៅនឹងវិការៈនៃកិច្ចសន្យាដែលឈានដល់ការលុបចោលនោះដែរ។

**១.៤.២ លក្ខខណ្ឌទម្រង់**

ក្រៅពីលក្ខខណ្ឌគ្រឹះ លក្ខខណ្ឌទម្រង់ក៏ជាលក្ខខណ្ឌចាំបាច់ក្នុងការបង្កើតកិច្ចសន្យា ប្រាតិភោគដោយអនុប្បទានដែរ។ ក្នុងចំណុចនេះ ការព្រមព្រៀងគឺជាលក្ខខណ្ឌទម្រង់ក្នុងការបង្កើតប្រាតិភោគដោយអនុប្បទាន ដូចដែលមានចែងក្នុងក្រមរដ្ឋប្បវេណីថា សិទ្ធិប្រាតិភោគដោយអនុប្បទាន ត្រូវបានបង្កើតឡើង ដោយការព្រមព្រៀងរវាងម្ចាស់បំណុល និង កូនបំណុល ឬតតិយជន ដែលផ្តល់ចលនវត្ថុសម្រាប់ប្រាតិភោគដោយអនុប្បទាន។

---

[25] មាត្រា ៣៨៦, ៣៨៧, ៣៥០ នៃក្រមរដ្ឋប្បវេណី ២០០៧

[26] ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧, មាត្រា ៣៥៨

[27] ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧, មាត្រា ៣៦៣ កថាខណ្ឌទី១

[28] ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧, មាត្រា ៣៦៣

យោងទៅតាមការចែងនេះ ច្បាប់បានទុកលទ្ធភាពឱ្យភាគីទាំងសងខាងធ្វើការព្រមព្រៀងដោយសេរី ពោលគឺអាចធ្វើការចរចារទៅលើការប្រគល់វត្ថុដែលជាកម្មវត្ថុជាដើម។[29]

លក្ខខណ្ឌទម្រង់ពុំសូវមានលក្ខណៈស្មុគស្មាញឡើយ ព្រោះថាច្បាប់បានគោរពនូវគោលការណ៍សេរីភាពនៃឆន្ទៈរបស់គូភាគី ដោយបើកសិទ្ធិឱ្យធ្វើការបញ្ចេញនូវមតិ និង លក្ខខណ្ឌដែលខ្លួនចង់បាន។ ទោះជាយ៉ាងណាក៏ដោយ ក្នុងការអនុវត្តជាក់ស្តែងសព្វថ្ងៃនេះ ភាគីម្ចាស់បំណុល តែងចរចារទាមទារឱ្យមានការប្រគល់វត្ថុដែលជាកម្មវត្ថុនៃការបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ធ្វើដូច្នេះទើបខ្លួនអាចទុកចិត្តថានឹងទទួលបានសំណងវិញទាន់ពេលវេលា និងឆាប់រហ័ស។ មួយវិញទៀត យើងក៏មិនបានប្រទះឃើញនូវបញ្ញត្តិណាមួយដែលចែងអំពីសិទ្ធិក្នុងការមិនប្រគល់វត្ថុដែលជាកម្មវត្ថុផងដែរ ទាំងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ក្តី ទាំងប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្តី។ អ្វីដែលគួរតែកត់សម្គាល់នោះគឺ ប្រជាពលរដ្ឋពុំបានធៀបនូវបញ្ញត្តិនៃប្រាតិភោគដោយអនុប្បទានដែរ ដែលធ្វើឱ្យការអនុវត្តទៅតាមសិទ្ធិលើការបញ្ចាំនូវតែបន្តកើតមានឡើង។

**១.៤.៣ លក្ខខណ្ឌតតាំង**

លក្ខខណ្ឌតតាំង គឺជាលក្ខខណ្ឌមួយដ៏មានសារៈសំខាន់ក្នុងការបង្កើតកិច្ចសន្យាប្រាតិភោគដោយអនុប្បទាន ដែលលក្ខខណ្ឌនេះអាចឱ្យម្ចាស់បំណុលមានសិទ្ធិពេញលេញក្នុងការអះអាង ចំពោះតតិយជនដទៃទៀតបានថាខ្លួនពិតជាមានសិទ្ធិទៅលើបំណុលជាងជនដទៃនោះ ដូចមានចែងក្នុងក្រមរដ្ឋប្បវេណីកម្ពុជាស្តីពីអានុភាពតតាំងនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន ម្ចាស់សិទ្ធិ ប្រាតិភោគដោយអនុប្បទាន ពុំអាចតតាំងសិទ្ធិប្រាតិភោគដោយអនុប្បទាននោះ ចំពោះតតិយជន ក្រៅពីអ្នកបង្កើតបានឡើយ បើមិនបានទទួលការផ្ទេរការកាន់កាប់វត្ថុដែលជាកម្មវត្ថុ។ ដូចបានលើកឡើងនេះ អានុភាពនៃការតតាំងអាចកើតមានបាននៅពេលមានការផ្ទេរការកាន់កាប់។[30] ប៉ុន្តែចំណុចនៃការផ្ទេរការកាន់កាប់នេះ ខ្ញុំនឹងធ្វើការអត្ថាធិប្បាយនៅក្នុងចំណុចបន្ទាប់។ ដោយឡែក លក្ខខណ្ឌតតាំងនេះផងដែរ ជាលក្ខខណ្ឌទាក់ទងនឹងការផ្សព្វផ្សាយជាសាធារណៈអំពី ការបង្កើត ការផ្ទេរ ឬ ការកែប្រែនូវសិទ្ធិប្រត្យក្សដើម្បីជាប្រយោជន៍សម្រាប់សុវត្ថិភាពគតិយុត្តក្នុងការជួញដូរ។ ដោយហេតុថា ក្នុងការរស់នៅប្រចាំថ្ងៃ កិច្ចសន្យាកើតមានឡើងនៅស្ទើរតែជុំវិញខ្លួន ដែលតម្រូវឱ្យគូភាគីមានការព្រមព្រៀងគ្នាទៅវិញទៅមកលើលក្ខខណ្ឌទាំងឡាយ ដូចនេះហើយ ការតតាំងចំពោះតតិយជន សំដៅទៅដល់ករណីដែលមានការទាមទារ ឬ សកម្មភាពផ្សេងៗទៀត ដែលកើតមានឡើងលើទ្រព្យដែលបានត្រូវដាក់ប្រាតិភោគ បានសេចក្តីថា ម្ចាស់សិទ្ធិប្រាតិភោគ ដោយអនុប្បទានអាចប្រើសិទ្ធិប្រត្យក្សដែលខ្លួនមាននោះ មកអះអាងក្នុងការការពារសិទ្ធិ

---

[29] ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧, មាត្រា ៨៨៩

[30] ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧, មាត្រា ២២៩

របស់ខ្លួន បានដើម្បីធានាឱ្យបានថាខ្លួននឹងនៅតែទទួលបានសំណង់ដដែល។ ក្នុងករណីជាក់ស្តែង គេមិនអាចប្រាកដបានថាកូនបំណុលជំពាក់ម្ចាស់បំណុលតែម្នាក់នោះទេ តែគឺអាចមានករណីដែលថាកូន បំណុលប្រហែលជាមានម្ចាស់បំណុលច្រើន ដែលនៅជាប់ជំពាក់ជំពិននឹងបំណុល។ ហេតុដូចនេះហើយទើបនៅក្នុងការបង្កើត ប្រាតិភោគដោយអនុប្បទាន លក្ខខណ្ឌតតាំងពិតជាសំខាន់ណាស់ ព្រោះម្ចាស់បំណុលណាដែលទទួលបានការផ្ទេរការកាន់កាប់នឹងមានលទ្ធភាពក្នុងការតតាំងជាមួយ នឹងតតិយជនដែលភាគច្រើនគឺសំដៅលើម្ចាស់បំណុលផ្សេងៗ។

## ១.៥ អានុភាពតតាំងនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន

ចំពោះការតតាំងជាមួយតតិយជន ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានពុំអាចតតាំងសិទ្ធិចំពោះតតិយជននោះបានទេ ក្រៅពីអ្នកបង្កើតសិទ្ធិ ប្រសិនបើមិនបានទទួលការផ្ទេរការកាន់កាប់វត្ថុដែលជាកម្មវត្ថុនោះទេ។[31]

ការផ្ទេរការកាន់កាប់នោះ អាចធ្វើឡើងតាម ៤ ប្រភេទដែលរួមមាន៖ ការផ្ទេរការកាន់កាប់ដោយជាក់ស្តែង ការផ្ទេរការកាន់កាប់ដោយការព្រមព្រៀង ការផ្ទេរការកាន់កាប់ដោយការប្រគល់ដោយសង្ខេប និងការផ្ទេរការកាន់កាប់ដោយបញ្ជា។[32]

### ១.៥.១ ការប្រគល់ដោយជាក់ស្តែង

ការប្រគល់ដោយជាក់ស្តែង គឺជាការប្រគល់ដោយផ្ទាល់ដៃពីអ្នកកាន់កាប់ទៅអ្នកទទួលការកាន់កាប់តាមការជាក់ស្តែង។[33] ចំណុចនេះបានសេចក្តីថា មុនការផ្ទេរវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគគឺស្ថិតនៅក្នុងការកាន់កាប់របស់អនុប្បទាយី ហើយអនុប្បទានិកជាអ្នកកាន់កាប់វត្ថុនោះវិញក្រោយការផ្ទេរដោយឈរក្រោមលក្ខខណ្ឌនៃឆន្ទៈព្រមព្រៀងផ្ទេរការកាន់កាប់ និង ការផ្ទេរការកាន់កាប់ដោយផ្ទាល់។

*ឧទាហរណ៍ ក្នុងកិច្ចសន្យាបង្កើតប្រាតិភោគដោយអនុប្បទានដែលមានកម្មវត្ថុជាម៉ូតូ។ ម៉ូតូត្រូវបានផ្ទេរពីអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ឱ្យទៅម្ចាស់សិទ្ធិដោយអនុប្បទានដោយផ្ទាល់។ តាមរយៈការផ្ទេរនេះ ដោយអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន បាត់បង់នូវការកាន់កាប់របស់ខ្លួន ហើយម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ទទួលបាននូវការកាន់កាប់។*

[31] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧,មាត្រា៨៩០

[32] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧,មាត្រា២២៩

[33] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧,មាត្រា២២៩ កថាខណ្ឌទី១

### ១.៥.២ ការកាន់កាប់ដោយការព្រមព្រៀង

ការកាន់កាប់ដោយការព្រមព្រៀង គឺការកាន់កាប់អាចត្រូវបានផ្ទេរដោយការព្រមព្រៀងគ្នារវាងគូរភាគីតែប៉ុណ្ណោះ ដោយគ្មានការប្រគល់វត្ថុនោះដោយជាក់ស្តែងទេ។[34] ក្នុងករណីនេះ អនុប្បទានិកនៃការកាន់កាប់ត្រូវទទួលការកាន់កាប់ដោយប្រយោលតាមរយៈអនុប្បទាយី។ លក្ខខណ្ឌនៃការប្តូរលក្ខណៈនៃការកាន់កាប់នេះ គឺស្ថិតត្រង់ថាគូភាគីទាំងពីរគ្រាន់តែបង្ហាញឆន្ទៈក្នុងការផ្ទេរ ដោយវត្ថុជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទានស្ថិតក្នុងការកាន់កាប់របស់អនុប្បទាយីទាំងមុន និងក្រោយការផ្ទេរសិទ្ធកាន់កាប់។

*ឧទាហរណ៍ តាមរយៈ កិច្ចសន្យាបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ដែលមានកម្មវត្ថុជាម៉ូតូដោយម៉ូតូត្រូវបានផ្ទេរពីអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ទៅឱ្យសិទ្ធិប្រាតិភោគដោយអនុប្បទាន។ ប៉ុន្តែប្រសិនបើសិទ្ធិប្រាតិភោគដោយអនុប្បទាន និងអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ព្រមព្រៀងគ្នាថា អ្នកបង្កើតសិទ្ធិ ប្រាតិភោគដោយអនុប្បទាននៅតែបន្តកាន់កាប់ម៉ូតូ នោះករណីនេះត្រូវបានគេចាត់ទុកថា ការកាន់កាប់ដោយការព្រមព្រៀង។*

### ១.៥.៣ ការប្រគល់ដោយសង្ខេប

ចំពោះអ្នកដែលនឹងទទួលអនុប្បទាននូវការកាន់កាប់ ក្តាប់ទុកវត្ថុកាន់កាប់ដោយចំពោះតាមការជាក់ស្តែង ការកាន់កាប់អាចត្រូវបានផ្ទេរ ដោយការព្រមព្រៀងគ្នារវាងគូភាគីតែប៉ុណ្ណោះ។ ដោយសារហេតុនេះ អនុប្បទាយីនៃការកាន់កាប់ត្រូវបាត់បង់ការកាន់កាប់ដោយប្រយោលដែល ខ្លួនធ្លាប់មាន តាមរយៈអ្នកក្តាប់ទុកវត្ថុកាន់កាប់ ការផ្ទេរការកាន់កាប់បែបនេះហៅថា ការប្រគល់ដោយសង្ខេប។[35] បើមើលលើការផ្ទេរការកាន់កាប់ប្រភេទនេះវិញគឺអនុប្បទានិកកាន់កាប់រួចជាស្រេច គឺមុន និងក្រោយការផ្ទេរវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគដែលស្ថិតនៅក្នុងការកាន់កាប់របស់អនុប្បទានិកតែម្តង។

*ឧទាហរណ៍ បុគ្គល ក ទទួលបញ្ញើរ ពី បុគ្គល ខ ដែលមានកម្មវត្ថុជា ចិញ្ចៀនមាស។ ដូចនេះការកាន់កាប់ដោយចំពោះគឺបានទៅលើបុគ្គល ក ចំណែកការកាន់កាប់ប្រយោលគឺបានទៅលើបុគ្គល ខ។ បន្ទាប់មកដោយសារការខ្វះខាតថវិកា បុគ្គល ខ និង បុគ្គល ក បានព្រមព្រៀងគ្នាបង្កើតកិច្ចសន្យាបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានដោយមានកម្មវត្ថុជា ចិញ្ចៀនមាស។ ក្នុងករណីនេះ បុគ្គល ក ដែលជាម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានទទួលបានការកាន់កាប់ដោយចំពោះរួចទៅហើយ។ ចំណែកសិទ្ធិកាន់កាប់ដោយប្រយោលរបស់អ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានត្រូវបានបាត់បង់ រហូតដល់កាតព្វកិច្ចនៃកិច្ចសន្យាបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានត្រូវបំពេញ។*

---

[34] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧,មាត្រា២២៩ កថាខណ្ឌទី២

[35] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧,មាត្រា២២៩ កថាខណ្ឌទី៣

**១.៥.៤ ការផ្ទេរការកាន់កាប់ដោយបញ្ជា**

ការផ្ទេរការកាន់កាប់ដោយប្រយោល តាមរយៈអ្នកដទៃ អាចផ្ទេរការកាន់កាប់ទៅឱ្យតតិយជនបាន ដោយការព្រមព្រៀង ជាមួយតតិយជន និង ដោយការជូនដំណឹងអំពីហេតុនោះ ទៅឱ្យអ្នកកាន់កាប់ដោយចំពោះ។[36] ការផ្ទេរបែបនេះបានសេចក្តីថា គូភាគីមានឆន្ទៈព្រមព្រៀងផ្ទេរឱ្យតតិយជនណាម្នាក់កាន់កាប់ដោយវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគនោះ ស្ថិតក្នុងការកាន់កាប់របស់តតិយជនដែលទទួលបញ្ជាឱ្យកាន់កាប់។

*ឧទាហរណ៍ អ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន បានផ្ញើម៉ូតូនៅនឹងបុគ្គល ក។ ក្រោយមកអ្នកបង្កើតសិទ្ធិប្រាតិភាគដោយអនុប្បទាន និងម្ចាស់ទ្ធិប្រាតិភាគដោយអនុប្បទាន បានព្រមព្រៀងគ្នាបង្កើតកិច្ចសន្យា បង្កើតសិទ្ធិប្រាតិភាគដោយអនុប្បទាន ដែលមានកម្មវត្ថុជាម៉ូតូខាងលើ និងបានជូនដំណឹងដល់បុគ្គល ក។ ដូចនេះតាមរយៈការផ្ទេរការកាន់កាប់ដោយបញ្ជាអ្នកបង្កើតសិទ្ធិប្រាតិភាគដោយអនុប្បទាន ពុំចាំបាច់ធ្វើការប្រគល់ម៉ូតូទៅកាន់ម្ចាស់សិទ្ធិប្រាតិភាគដោយអនុប្បទានដោយផ្ទាល់នោះទេគ្រាន់តែបញ្ជាឱ្យបុគ្គល ក ប្រគល់ម៉ូតូទៅឱ្យ ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានតែប៉ុណ្ណោះ។*

[36] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧,មាត្រា២២៩ កថាខណ្ឌទី៤

# ជំពូកទី២
# អានុភាពនៃសិទ្ធិប្រាតិភោគដោយ
# អនុប្បទាន

# ជំពូកទី២

# អានុភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន

ជាគោលការណ៍ បុគ្គលដែលមានសិទ្ធិប្រាតិភោគដោយកិច្ចសន្យាដូចជា សិទ្ធិលើការបញ្ចាំហ៊ីប៉ូតែក ឬ ប្រាតិភោគដោយអនុប្បទានជាអាទិ៍ដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី។ នៅពេលដែលប្រាតិភោគដោយអនុប្បទានបានបង្កើតឡើង នាំឱ្យសិទ្ធិប្រាតិភោគដោយអនុប្បទានមានអានុភាពលើវត្ថុ វត្ថុភ្ជាប់ និងផ្នែកនៃវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាន លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះដែលមានកំណត់នៅក្នុងកិច្ចសន្យាបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន និងប្រសិនបើម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ឬ តតិយជនដែលបានទទួលបញ្ជាពីម្ចាស់សិទ្ធិនោះ កាន់កាប់វត្ថុដែលជាកម្មវត្ថុនោះដោយចំពោះ ឬបានទាមទារឱ្យប្រគល់វត្ថុដែលជាកម្មវត្ថុ ផលដែលកើតពីវត្ថុនោះ ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានមានសិទ្ធិទទួលផលនោះ ដោយមិនចាំបាច់យកផលនោះកាត់សិទ្ធិលើបំណុលឡើយ។[37] ក្នុងករណីនេះ ម្ចាស់បំណុលមិនអាចទាមទារការប្រាក់បាននោះទេ លើកលែងតែមានកំណត់ផ្សេងទៀតនៅក្នុងកិច្ចសន្យានៃការបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន និង ប្រសិនបើអ្នកបង្កើតសិទ្ធិនេះ (កូនបំណុល) ឬ តតិយជនដែលបានទទួលបញ្ជាពីអ្នកបង្កើតសិទ្ធិនេះ កាន់កាប់វត្ថុដែលជាកម្មវត្ថុនោះដោយចំពោះស្ថានភាពខាងលើនេះមិនអនុវត្តបានឡើយ។ ដោយអានុភាពនៅក្នុងប្រាតិភោគដោយអនុប្បទានមានភាពទូលំទូលាយ ក្នុងជំពូកទី២នេះ យើងនឹងធ្វើការបែងចែកការពន្យល់ជា បីចំណុចធំៗគឺ (១) ទំហំនៃអានុភាពរបស់សិទ្ធិប្រាតិភោគដោយអនុប្បទាន (២) ឧបាទេសកម្មលើវត្ថុ និង (៣)ការចាត់ចែងវត្ថុដែលជាកម្មវត្ថុដោយអ្នកធានាដោយវត្ថុ និង ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន។

## ២.១. ទំហំនៃអានុភាពរបស់សិទ្ធិប្រាតិភោគដោយអនុប្បទាន

សិទ្ធិប្រាតិភោគដោយអនុប្បទាន មានអានុភាពលើវត្ថុដែលភ្ជាប់នឹងវត្ថុ ដែលជាកម្មវត្ថុ និង ជាផ្នែកមួយនៃវត្ថុដែលជាកម្មវត្ថុនោះ នៅពេលដែលបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន។[38] មានន័យថាទំហំនៃអានុភាពនោះអាចកែប្រែបានតាមការព្រមព្រៀង។ អានុភាពនេះ ក៏មានលើវត្ថុដែលត្រូវបានភ្ជាប់នៅក្រោយពេលបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានផងដែរ។

ចំពោះវត្ថុដែលភ្ជាប់នឹងវត្ថុ និង វត្ថុដែលជាផ្នែកមួយនៃវត្ថុ សំដៅទៅលើសមាសភាគនៃវត្ថុ[39] ឬ វត្ថុចំណុះរបស់វត្ថុចម្បង។[40] តាមអត្ថន័យមានន័យថា សិទ្ធិប្រាតិភោគដោយអនុប្បទានមានអានុភាពទាំងទៅលើវត្ថុដែល

---

[37] មាត្រា៨២២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[38] មាត្រា៨៩១ កថាខណ្ឌទី១នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[39] មាត្រា១២១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[40] មាត្រា ១២៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

រួមទាំងសមាសភាពនៃវត្ថុ និង វត្ថុចំណុះនៃវត្ថុចម្បងដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន ទោះបីជាមុន ឬក្រោយការបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាននេះក៏ដោយ។[41]

បើទោះបីជានៅក្នុងមាត្រា ៨៩១ បានកំណត់អំពីអានុភាពខាងលើក៏ពីមែន ប៉ុន្តែម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន និង អ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន អាចធ្វើការកំណត់សន្យាពិសេសផ្សេងទៀតបានដោយចែងការកំណត់ក្នុងកិច្ចសន្យាបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានបាន។[42]

## ២.១.១ អានុភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទានចំពោះផល

អានុភាពចំពោះផល នឹងត្រូវបានកើតឡើងក្រោយពេលដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានបានទាមទារឱ្យប្រគល់វត្ថុដែលជាកម្មវត្ថុ ដើម្បីធ្វើការចាត់ចែងប្តូរជាប្រាក់ ឬអនុប្បទានជាស្ថាពរ។ ដោយឡែកក្នុងករណីដែលអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ឬតតិយជនដែលបានបញ្ជាពីអ្នកបង្កើតនោះឱ្យកាន់កាប់វត្ថុដែលជាកម្មវត្ថុដោយចំពោះអានុភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន នឹងពុំមានចំពោះផលនោះទេ។[43] ជាក់ស្តែង ចលនវត្ថុដែលយកមកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានអាចជាវត្ថុដែលជាប្រភពស្វែងរកប្រាក់ចំណូលបាន ជាអាទិ៍រួមមាន រថយន្តតាក់ស៊ី សត្វទា ដែលមានពងក្នុងកសិដ្ឋាន ត្រីក្នុងបឹង ទូរស័ព្ទក្នុងហាង ដែលអាចទទួលផលពីវាបានជាដើម។

មូលហេតុដែលមិនឱ្យមានអានុភាព ព្រោះថាអ្នកបង្កើត និងតតិយជនដែលទទួលការបញ្ជាមានសិទ្ធិប្រើប្រាស់ និងអាស្រ័យផលពីវត្ថុដែលខ្លួនកំពុងកាន់កាប់ដោយចំពោះ។

*ឧទាហរណ៍៖ **ក** បានយកម៉ូតូជាច្រើនគ្រឿងដែលខ្លួនទុកសម្រាប់ជួលឲអ្នកដទៃនោះទៅបង្កើតប្រាតិភោគដោយអនុប្បទានជាមួយ **ខ** ហើយបានផ្ទេរការកាន់កាប់ដោយការព្រមព្រៀងដើម្បីខ្ចីប្រាក់ពី **ខ**។ **ក** ជាអ្នកកាប់កាប់ដោយចំពោះលើម៉ូតូដែលជាកម្មវត្ថុនៃប្រាតិភោគនេះ។ ហេតុនេះហើយ **ក** មានសិទ្ធិទទួលផលពីកម្មវត្ថុនោះតាមរយៈការជួលម៉ូតូទាំងនោះ ហើយ ខ មិនអាចទទួលផលដូចជាថ្លៃឈ្នួលឡើយ (អានុភាពនៃប្រាតិភោគដោយអនុប្បទានមិនមានចំពោះផលឡើយ)។*

ផ្ទុយទៅវិញក្នុងករណីដែលម្ចាស់សិទ្ធិដោយអនុប្បទាន ឬ តតិយជនដែលបានទទួលបានការបញ្ជាពីម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាននោះកាន់កាប់វត្ថុដែលជាកម្មវត្ថុដោយចំពោះ អានុភាពចំពោះផលនឹងត្រូវអនុវត្តដូចគ្នាទៅនឹង សិទ្ធិទទួលការសងពីផលដោយមានអាទិភាព ចំពោះសិទ្ធិលើការបញ្ចាំ[44] មានន័យថា ផល

---

[41] មាត្រា៨៩១ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[42] មាត្រា៨៩១ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[43] មាត្រា ៨៩២ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[44] មាត្រា ៨២២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ដែលបានមកពីកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាននេះ ត្រូវយកមកកាត់សិទ្ធិលើបំណុលរបស់ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ដោយមានអាទិភាពជាងម្ចាស់បំណុលដទៃទៀត។ ចំពោះនីតិវិធីនៃការកាត់សិទ្ធិលើបំណុលនោះ គឺត្រូវកាត់ការប្រាក់ជាមុនសិន ហើយប្រសិនបើមានសល់ត្រូវយកទៅកាត់នឹងប្រាក់ដើម។

### ២.១.២. ឧបាទេសកម្មលើវត្ថុ

ពាក្យ **ឧបាទេសកម្ម** មានន័យថា ជាឋានៈមួយដែលបុគ្គលម្នាក់ទទួលជំនួសបុគ្គលណាម្នាក់ទៀតតាមផ្លូវច្បាប់។[45] បន្ថែមពីលើនេះទៅទៀតនោះ ឧបាទេសកម្ម អាចមានន័យមួយទៀតគឺ សំដៅទៅលើ វត្ថុ ផងដែរ។ ដូចដែលបានបញ្ញត្តិក្នុងក្រមរដ្ឋប្បវេណីផងដែរថា ក្នុងករណីដែលចាំបាច់ដើម្បីរក្សាការពារសិទ្ធិលើបំណុលរបស់ខ្លួនម្ចាស់បំណុលអាចអនុវត្តសិទ្ធិដែលកូនបំណុលមានជំនួសកូនបំណុលបាន។[46] ក្នុងការចែងនេះ បានការពារម្ចាស់សិទ្ធិផងដែរក្នុងការរក្សាឱ្យបាននូវវត្ថុដែលជាកម្មវត្ថុ ព្រោះនោះហើយដែលជាការធានាលើបំណុលដែលខ្លួនបានធ្វើកម្ចីទៅអ្នកបង្កើតនោះ។ លើសពីនេះទៅទៀត សិទ្ធិឧបាទេសកម្មនេះអាចអនុវត្តបានគ្រប់ពេល ដរាបណាដែលម្ចាស់សិទ្ធិគិតថាចាំបាច់ដើម្បីរក្សាការពារលើវត្ថុនោះ ឬ អាចមានហានិភ័យណាមួយកើតមានឡើង។

ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន អាចអនុវត្តសិទ្ធិរបស់ខ្លួន ចំពោះទឹកប្រាក់ ឬ វត្ថុផ្សេងទៀតដែលអ្នកបង្កើតត្រូវទទួលដោយការលក់ ការបាត់បង់ ឬការខូចខាតនូវវត្ថុដែលជាកម្មវត្ថុ។ ប៉ុន្តែម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ពុំអាចអនុវត្តសិទ្ធិរបស់ខ្លួនបានឡើយ នៅក្រោយពេលដែលប្រាក់ត្រូវបានបង់ ឬវត្ថុផ្សេងត្រូវបានប្រគល់ទៅឱ្យអ្នកបង្កើត។[47] ក្នុងន័យនេះចង់ផ្តោតសំខាន់ថាប្រសិនជាអ្នកបង្កើតបានធ្វើការលក់វត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទានទៅឱ្យបុគ្គលណាម្នាក់ផ្សេងទៀត ហើយការដែលលក់នោះគឺស្ថិតនៅក្នុងអំឡុងពេលនៃកិច្ចសន្យា នោះម្ចាស់សិទ្ធិមានអានុភាពទៅលើទឹកប្រាក់ដែលបានលក់នោះ ដោយអាចធ្វើការទាមទារយកចំនួនទឹកប្រាក់ ឬ វត្ថុដែលជាទំហំនៃការដាក់ប្រាតិភោគ។ ហើយម្យ៉ាងវិញទៀតនោះ ម្ចាស់សិទ្ធិក៏អាចធ្វើការអនុវត្តសិទ្ធិលើវត្ថុ ដែលជាកម្មវត្ថុនោះជំនួសអ្នកបង្កើតផងដែរក្នុងករណីចាំបាច់។ ដោយឡែក នៅក្នុងអានុភាពនៃប្រាតិភោគដោយអនុប្បទាន នឹងត្រូវមានចំពោះតម្លៃនៃវត្ថុជំនួសសម្រាប់វត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន។[48] មានន័យថាអ្នកបង្កើតអាចធ្វើការផ្លាស់ប្តូរវត្ថុដែលជាកម្មវត្ថុបានដោយជំនួសវត្ថុណាផ្សេងតាមការចរចាររវាងគូភាគី។

---

[45] សន្ទានុក្រមរដ្ឋប្បវេណី

[46] មាត្រា ៤២២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[47] មាត្រា ៨៩៣ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[48] មាត្រា ៩៣១ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានអាចធ្វើឧបាទេសកម្មចំពោះប្រាក់ ឬវត្ថុផ្សេងទៀតដែលត្រូវទទួលដោយការលក់ ការបាត់បង់ ឬ ការខូចខាតនូវវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាន។

ដោយចលនវត្ថុនៅក្នុងបរិបទនៃប្រាតិភោគដោយអនុប្បទានត្រូវបានបែងចែកជា ចលនវត្ថុធម្មតា និង ចលនវត្ថុផ្គុំគ្នា។ នៅក្នុងចំណុច បន្តទៀត យើងនឹងធ្វើការវែកញែក សិក្សាលើករណីទាំងពីរនេះ។

## ២.២ ការចាត់ចែងវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន

### ២.២.១ ការចាត់ចែងវត្ថុដែលជាកម្មវត្ថុដោយអ្នកធានាដោយអនុប្បទាន

#### ២.២.១.១ ចលនវត្ថុធម្មតា

នៅក្នុងករណី ដែលចលនវត្ថុត្រូវបានធ្វើអនុប្បទានជាប្រាតិភោគចលវត្ថុនោះនៅតែអាចស្ថិតនៅក្រោមការកាន់កាប់របស់អ្នកធានាដោយវត្ថុ។ ក្នុងករណីនេះ ដោយឆ្លៀតឱកាសដែលខ្លួនកំពុងតែកាន់កាប់ជាក់ស្តែង អ្នកធានាដោយវត្ថុអាចធ្វើអនុប្បទាននូវចលនវត្ថុនោះឱ្យទៅតតិយជន ឬ ដាក់ជាប្រាតិភោគបាន។ នៅក្នុងករណីនេះគេចាំបាច់ត្រូវកំណត់ថា តើម្ចាស់សិទ្ធិប្រាតិភោគ ឬ តតិយជនអាចអះអាងអំពីអាទិភាពអំពីចលនវត្ថុចំពោះអ្នកដទៃបាន។

បើអ្នកបង្កើត ដែលបន្តការកាន់កាប់ដោយចំពោះនូវវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន នៅក្រោយពេលបង្កើតសិទ្ធិនោះ បានធ្វើអនុប្បទាននូវវត្ថុដែលជាកម្មវត្ថុនោះទៅ ឱ្យតតិយជន ឬ បានបង្កើតសិទ្ធិប្រាតិភោគប្រត្យក្សលើវត្ថុនោះដើម្បីតតិយជន ប្រសិនបើតតិយជន នោះបំពេញគ្រប់ល័ក្ខខ័ណ្ឌនៃលទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ នោះតតិយជននោះ អាចយកសិទ្ធិរបស់ខ្លួន ទៅតតាំងចំពោះម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានបាន។ ដោយហេតុ ដូចនេះហើយ អ្នកបង្កើតអាចធ្វើការយកនូវវត្ថុជំនួសដើម្បីជំនួសនូវវត្ថុដែលជាកម្មវត្ថុបាន។ ដោយសារថាការធ្វើប្រាតិភោគដោយអនុប្បទានបានផ្តល់នូវភាពទូលំទូលាយដល់កូនបំណុល នោះច្បាប់ បានបើកសិទ្ធិឱ្យម្ចាស់សិទ្ធិក្នុងការទាមទារឲ្យអ្នកបង្កើត យកវត្ថុអ្វីផ្សេងមកជំនួសក្នុងករណីដែលថា អ្នកបង្កើតបានធ្វើលទ្ធកម្មលើវត្ថុដែលជាកម្មវត្ថុ។

*ឧទាហរណ៍ៈ បញ្ហាគឺនៅត្រង់ថា តើតតិយជនបានបំពេលលក្ខខណ្ឌនៃលទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុដែរ ឬ ទេ។*[49] *នៅក្នុងករណី ក បាន ជំពាក់បំណុល ខ បន្ទាប់មក ក បានធ្វើ អនុប្បទានរបស់ខ្លួនជាប្រាតិភោគ ឱ្យទៅ ខ ប៉ុន្តែ ក នៅតែបន្តកាន់កាប់។ បន្ទាប់មក ក បានលក់ឡាននោះឲទៅ គ ដែលមិនបានដឹងពីការបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន។ នៅក្នុងករណីនេះដោយផ្អែកតាមលទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ គ អាចធ្វើលទ្ធកម្ម កម្មសិទ្ធិហើយវាបានឆ្លុះបញ្ចាំងពីការបាត់បង់ប្រាតិភោគចំពោះ ក។ ក្នុង*

[49] មាត្រា ៨៩៤ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

*ករណីនេះ ខ មិនអាច អនុវត្តសិទ្ធិប្រាតិភោគអនុប្បទានចំពោះឡាននោះបានទេ។ ផ្ទុយទៅវិញ នៅក្នុងករណីដែល គ មិនបានបំពេញលក្ខខណ្ឌលទ្ធកម្មដោយសុចរិតទេ ខ អាចអះអាងពីអាទិភាពជាម្ចាស់សិទ្ធិប្រាតិភោគដោយ អនុប្បទាន។*[50]

តើមានវិធីណាដើម្បីការពារ ខ ការពារកម្មវត្ថុ នៃឡានរបស់ ក ដែលធ្វើប្រាតិភោគដោយអនុប្បទាននោះបាន? ចម្លើយនោះគឺ ខ អាច ដាក់សញ្ញាសម្គាល់លើឡាននោះ ដើម្បីបង្ហាញថាជាកម្មវត្ថុដោយអនុប្បទាន។ ប្រសិនបើ គ ទិញឡាននោះ ខ មានសិទ្ធិធ្វើលទ្ធកម្មលើឡាននោះបានពី គ ដែលបានទិញទៅព្រោះ គ បានទិញឡានដោយ ទុច្ចរិត។

**២.២.១.២ ចលនវត្ថុផ្តុំគ្នា**

បើទោះបីជា កថាខណ្ឌទី២ នៃមាត្រា ៨៩៣ នៃក្រមរដ្ឋប្បវេណីចែង ដូចខាងលើក្តី ក្នុងករណីចលនវត្ថុផ្តុំគ្នាដែលមានន័យថា ចលនវត្ថុច្រើន ដែលត្រូវបានកំណត់ទំហំតាមមាត្រដ្ឋានដូចជាប្រភេទ ឬកន្លែងស្ថិតនៅនៃចលនវត្ថុ អាចយកមកធ្វើជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន ដោយចាត់ទុកជាចលនវត្ថុផ្តុំគ្នាតែមួយបានទោះបីជាចលនវត្ថុនីមួយៗដែលផ្តុំគ្នានោះ មានការប្រែប្រួលក៏ដោយ[51] ហើយចលនវត្ថុនោះត្រូវមានគម្រោងលក់តាំងពីដំបូងទៅឱ្យតតិយជន ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានមិនអាចធ្វើឧបាទេសកម្មបាននោះទេ។

ចលនវត្ថុផ្តុំគ្នាគឺមានភាពខុសប្លែក ដោយសារថាវាពិបាកនឹងផ្តល់អានុភាពឱ្យទៅម្ចាស់សិទ្ធិ ពោលគឺម្ចាស់សិទ្ធិមិនអាចអនុវត្តសិទ្ធិ ឧបាទេសកម្មលើវត្ថុផ្តុំគ្នាឡើយ។

*ឧទាហរណ៍ អ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានបានយកទំនិញនៅក្នុងឃ្លាំងដែលជាចលនវត្ថុប្រមូលផ្តុំគ្នាដែលត្រូវបានគ្រោងលក់ ទៅបង្កើតប្រាតិភោគដោយអនុប្បទានជាមួយម្ចាស់សិទ្ធិ ប្រាតិភោគដោយអនុប្បទាន។ នៅក្នុងករណីនេះ វត្ថុដែលចេញចូលក្នុងឃ្លាំង (កន្លែងស្ថិតនៅរបស់ចលនវត្ថុផ្តុំគ្នា) ត្រូវបានចាត់ទុកថាជាចលនវត្ថុផ្តុំគ្នា។ ហេតុនេះអានុភាពនៃប្រាតិភោគមានតែចំពោះវត្ថុផ្តុំគ្នា ប៉ុន្តែមិនមានចំពោះវត្ថុដែលយកចេញបាននោះទេ។ ក្នុងករណីនេះ ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន មិនអាចធ្វើឧបាសទេសកម្មលើទឹកប្រាក់ដែលបានពីការលក់ទំនិញនោះទេ។*

ក្នុងករណីដែលចលនវត្ថុផ្តុំគ្នា អ្នកធានាដោយវត្ថុអាចចាត់ចែងវត្ថុដែលមានគម្រោងនឹងលក់បានដោយសេរី។[52]

[50] មាត្រា ៨៩៤ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[51] មាត្រា ៨៨៨ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[52] មាត្រា ៨៩៤ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

*ឧទាហរណ៍ៈ នៅក្នុងករណី ក បានជំពាក់បំណុល ខ ក បានធ្វើអនុប្បទានទំនិញក្នុងហាង ដែលជាចលនវត្ថុផ្តុំគ្នាជាប្រាតិភោគ ដោយ ក នៅបន្តកាន់កាប់ដោយចំពោះបន្ទាប់មក ក បានលក់ទំនិញដែលមានគម្រោងនឹង លក់តាំងពីដំបូងនោះ ទៅឱ្យ គ ដែលបានដឹងអំពីការបង្កើតសិទ្ធិប្រាតិភោគ ដោយអនុប្បទានដោយ ក ។ នៅក្នុងករណីនេះទោះបីជា គ បានដឹងអំពី អត្ថិភាពនៃសិទ្ធិប្រាតិភោគប្រត្យក្សរបស់ ខ ក៏ដោយ ក៏ គ អាចធ្វើលទ្ធកម្មកម្មសិទ្ធិនៃទំនិញបានដែរ ។ នេះក៏ព្រោះតែទំនិញទាំងនោះ នឹងលែងជាផ្នែកនៃចលនវត្ថុផ្តុំគ្នា នៅពេលដែលនៅក្រៅទំហំនៃចលនវត្ថុផ្តុំគ្នា ។*

**២.២.២ ការចាត់ចែងវត្ថុដែលជាកម្មវត្ថុដោយម្ចាស់សិទ្ធិដោយអនុប្បទាន**

ទាក់ទិននឹងការចាត់ចែងដោយម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានវិញ បើម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ដែលកាន់កាប់ដោយចំពោះនូវវត្ថុនៃប្រាតិភោគដោយអនុប្បទាននោះបានធ្វើអនុប្បទាននូវវត្ថុដែលជាកម្មវត្ថុនោះទៅតតិយជន ឬបាន បង្កើតសិទ្ធិប្រាតិភោគប្រត្យក្សលើវត្ថុនោះដើម្បីតតិយជន[53] ប្រសិនបើតតិយជននោះបំពេញគ្រប់លក្ខខណ្ឌ នោះតតិយជនអាចយកសិទ្ធិរបស់ខ្លួនទៅតតាំងចំពោះអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានបាន។[54]

បញ្ញត្តិដែលបានចែងក្នុងកថាខណ្ឌទី១ ក៏ត្រូវបានយកមកអនុវត្តផងដែរចំពោះករណីដែលអ្នកដទៃបានទទួលការបញ្ជាពីម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ដើម្បីកាន់កាប់ដោយចំពោះនូវវត្ថុដែលជាកម្មវត្ថុហើយម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាននោះបានធ្វើអនុប្បទាននូវវត្ថុដែលជាកម្មវត្ថុនោះទៅតតិយជន ឬ បានបង្កើតសិទ្ធិប្រាតិភោគប្រត្យក្សលើវត្ថុនោះទៅតតិយជន។

ដោយឡែក នៅក្នុងប្រកាសស្តីពីការគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទាន របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុវិញ កំណត់ចែងអំពីកាតព្វកិច្ចរបស់ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន (អ្នកកាន់អាជ្ញាបណ្ណ និងអ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្មប្រាតិភោគដោយអនុប្បទានដែលមាន កាតព្វកិច្ចរក្សាទុកទ្រព្យប្រាតិភោគ ដោយអនុប្បទាននៅកន្លែងដែលមានសុវត្ថិភាព និងមិនត្រូវយកទ្រព្យនោះទៅប្រើប្រាស់ឡើយ។[55] បន្ថែមពីនេះទៀត ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន (អ្នកកាន់អាជ្ញាបណ្ណ និងអ្នកកាន់ លិខិតអនុញ្ញាតប្រកបអាជីវកម្មប្រាតិភោគដោយអនុប្បទាន) ពុំមានសិទ្ធិលក់ ផ្ទេរ ឬ ប្រគល់សិទ្ធិកាន់កាប់ទ្រព្យ ប្រាតិភោគដោយអនុប្បទាន ឱ្យទៅតតិយជនក្នុងអំឡុងពេលដែលទ្រព្យប្រាតិភោគដោយអនុប្បទាន

[53] មាត្រា ៨៩៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[54] មាត្រា ១៩៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[55] ប្រកាសអាជីវកម្មបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន, ប្រការ១៣

នោះកំពុង ជាប់កិច្ចសន្យាបង្កើតសិទ្ធិប្រតិភោគដោយអនុប្បទានឡើយ ប្រសិនពុំមានការយល់ព្រមពីអ្នកបង្កើតសិទ្ធិ ប្រាតិភោគដោយអនុប្បទាន។[56] ថ្វីបើប្រកាសនេះ មានបញ្ជាក់អំពីចំណុចនេះក៏ពិតមែន ប៉ុន្តែក្នុងប្រកាសនេះក៏ពុំ កំណត់បញ្ជាក់អំពីទោសទណ្ឌដែលនឹងត្រូវបានទទួលនោះទេ។

ក្នុងករណី វត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន ត្រូវបានចាត់ចែងដោយម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានដែលគាត់បានកាន់កាប់ដោយផ្ទាល់។[57]

នៅក្នុងករណីនៃការចាត់ចែងដោយម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន វាមានលក្ខណៈស្រដៀងគ្នាទៅនឹងការចាត់ចែងវត្ថុដែលជាកម្មវត្ថុ ដោយអ្នកធានាដោយវត្ថុ បញ្ហា គឺនៅត្រង់ថាតើតតិយជនបានបំពេញលក្ខខណ្ឌនៃលទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុដែរ ឬទេ ។

*ឧទាហរណ៍៖ ខ បានធ្វើលទ្ធកម្មនូវការកាន់កាប់ទំនិញនៅក្នុងឃ្លាំងពី ក ហើយដោយគ្មានការយល់ព្រមពី ក ខ បានលក់ទំនិញនោះទៅឱ្យ គ ។ គ មិនបានដឹងថាវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យាលក់ទិញនេះ ជាកម្មវត្ថុនៃសិទ្ធិ ប្រាតិភោគដោយអនុប្បទាននោះទេ ។ ក្នុងករណីនេះ គ អាចទទួលបាននូវ កម្មសិទ្ធិនៃចលនវត្ថុនោះដោយស្របច្បាប់ ដោយគ្រាន់តែអាចទាមទារ សំណងពី ខ ។ ផ្ទុយទៅវិញ បើសិនជា គ មានកំហុស ឬ ជាជនទុច្ចរិតក អាចទទួលបាននូវចលនវត្ថុនោះត្រឡប់មកវិញបាន ។*

## ២.៣ ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា

ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានារួមមាន ប្រាក់ដើម ការប្រាក់ ប្រាក់ធានាសំណងក្នុងករណីបំពានកិច្ចសន្យា សោហ៊ុយដើម្បីអនុវត្ត សិទ្ធិប្រាតិភោគដោយអនុប្បទាន សោហ៊ុយដើម្បីថែរក្សាវត្ថុដែលជាកម្មវត្ថុ ព្រមទាំងសំណងនៃការខូចខាតដែលកើតឡើងដោយសារការមិនអនុវត្តកាតព្វកិច្ច ឬ វិការៈកំបាំងនៃវត្ថុដែលជាកម្មវត្ថុ។[58] វាមានន័យថានៅពេលម្ចាស់ សិទ្ធិប្រាតិភោគដោយអនុប្បទាន ធ្វើការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន តើទំហំសិទ្ធិលើបំណុលមានដល់កម្រិតណា? ដូចបានលើកឡើង ខាងលើ វាមានអានុភាពធានាដល់ប្រាក់ដើម ការប្រាក់ ប្រាក់ធានាសំណងក្នុង ករណីបំពានកិច្ចសន្យា សោហ៊ុយដើម្បីអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទានសោហ៊ុយដើម្បីថែរក្សាវត្ថុដែលជាកម្មវត្ថុ ព្រមទាំងសំណងនៃការខូចខាត ដែលកើតឡើងដោយសារការមិនអនុវត្តកាតព្វកិច្ចទាំង វិការៈកំបាំងនៃវត្ថុ ដែលជាកម្មវត្ថុ ជាលក្ខណៈសារធាតុ នឹង សិទ្ធិលើការបញ្ចាំ។[59]

---

[56] ប្រកាសអាជីវកម្មបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន, ប្រការ ១៨

[57] មាត្រា ៨៩៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[58] មាត្រា ៨៩៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[59] មាត្រា ៨២០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

## ២.៤ បញ្ញត្តិពិសេសនៅក្នុងករណីដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានកាន់កាប់វត្ថុដែលជាកម្មវត្ថុ

ប្រាតិភោគដោយអនុប្បទាន មិនត្រឹមតែផ្តល់ជូននូវអានុភាពដែលត្រូវបានលើកឡើងបកស្រាយខាងលើនេះទេ លើសពីនេះទៅទៀត ក្នុងនោះក៏មានបន្ថែមបញ្ញត្តិនូវអានុភាពពិសេសផងដែរ។ ក្នុងបញ្ញត្តិពិសេសនេះ ករណីដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ឬ តតិយជនដែលទទួលការបញ្ជាពីម្ចាស់សិទ្ធិនោះ កាន់កាប់ដោយចំពោះនូវវត្ថុដែលជាកម្មវត្ថុ។[60] ក្នុងអត្ថន័យនេះបានសេចក្តីថា ប្រាតិភោគដោយអនុប្បទាននឹង ត្រូវប្រព្រឹត្តទៅដូចទៅនឹងការបញ្ចាំផងដែរព្រោះទំនាក់ទំនងរវាងម្ចាស់សិទ្ធិ និង វត្ថុដែលជាកម្មវត្ថុ។ ជាទូទៅ ការបញ្ចាំ និង ប្រាតិភោគដោយអនុប្បទានមានលក្ខណៈស្រដៀងគ្នា ជាហេតុធ្វើឲមនុស្សជាច្រើនមានការយល់ច្រឡំ ដោយឡែកប្រាតិភោគដោយអនុប្បទានមានលក្ខណៈទូលំទូលាយជាង ដូចជាចលនវត្ថុដែលជាកម្មវត្ថុក្នុងករណីសិក្សាប្រធានយើង គឺអាចកើតជារូបភាពចលនវត្ថុធម្មតា និងចលនវត្ថុផ្គុំគ្នា រីឯ ក្នុងការបញ្ចាំ គឺគេមិនអាចអនុវត្តទៅលើចលនវត្ថុផ្គុំគ្នាបាននោះទេ។

ក្នុងបញ្ញត្តិពិសេសនេះ តាមរយៈការកាន់កាប់វត្ថុដែលជាកម្មវត្ថុដោយម្ចាស់សិទ្ធិ នាំឲម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានមានសិទ្ធិ និង ករណីកិច្ចមួយចំនួនទៅលើវត្ថុនោះដូចគ្នាទៅនឹងម្ចាស់សិទ្ធិលើការបញ្ចាំ ដែលសិទ្ធិ និងករណីកិច្ចនោះរួមមាន (១) អានុភាពនៃការឃាត់ទុក និងទទួលសោហ៊ុយ (២) ករណីកិច្ចរបស់ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានក្នុងការរក្សាទុកវត្ថុដែលជាកម្មវត្ថុ និង (៣) សិទ្ធិទាមទារឲសងសោហ៊ុយរបស់ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានលើការបញ្ចាំ។

### ២.៤.១ អានុភាពនៃការឃាត់ទុក

អានុភាពនៃការឃាត់ទុកចំពោះសិទ្ធិប្រាតិភោគដោយអនុប្បទាននេះ ត្រូវបានអនុវត្តដូចគ្នាទៅនឹងអានុភាពនៃការឃាត់ទុកចំពោះសិទ្ធិលើការបញ្ចាំ។[61] ក្នុងន័យនេះ ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានអាចឃាត់ទុកវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទានបានរហូតដល់ពេល ដែលទទួលការសងចំពោះទំហំសិទ្ធិលើបំណុលដែលត្រូវបានធានាដូចបានកំណត់ខាងលើនេះ។ ប៉ុន្តែសិទ្ធិនេះមិនអាចតតាំងចំពោះម្ចាស់បំណុលដែលមានអាទិភាពជាងខ្លួនបានឡើយ។[62] ការចែងបែបនេះបានផ្តល់ឱកាសឱ្យម្ចាស់សិទ្ធិក្នុងការជួយរំលឹកកូនបំណុលដោយប្រយោល តាមរយៈអានុភាពឃាត់ទុកនៃសិទ្ធិដើម្បីទទួលបានការសងចំពោះសិទ្ធិលើ

[60] មាត្រា ៨២៣, ៨២៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[61] មាត្រា ៨៩៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[62] មាត្រា ៨២១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

បំណុល។ ធ្វើដូចនេះអាចធ្វើឲម្ចាស់សិទ្ធិអាចនឹងទទួលបានសំណងឆាប់រហ័ស និងទាន់ពេលវេលា។ លើសពីនេះទៅទៀតម្ចាស់សិទ្ធិក៏មានអានុភាពផងដែរ ទៅលើការទទួលបាននូវសោហ៊ុយនៃការចំណាយទៅលើវត្ថុដែលជាកម្មវត្ថុនោះ។

### ២.៤.២ករណីកិច្ចរបស់ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានក្នុងការរក្សាទុកវត្ថុដែលជាកម្មវត្ថុ

ចំពោះករណីកិច្ចរបស់ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានវិញ ក្នុងការរក្សាទុកវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាន ដោយមានអត្ថន័យជារួមថា ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ត្រូវកាន់កាប់វត្ថុបញ្ចាំនោះដោយប្រុងប្រយ័ត្នក្នុងនាមជាងអ្នកគ្រប់គ្រងដោយសុចរិត។ ប្រសិនបើម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានមិនបានគោរពកាតព្វកិច្ចនោះទេ អ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានអាចទាមទារឱ្យរំលត់សិទ្ធិប្រាតិភោគដោយអនុប្បទានឱ្យនោះបាន។[63]

### ២.៤.៣ សិទ្ធិទាមទារឱ្យសងសោហ៊ុយរបស់ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន

សិទ្ធិទាមទារឱ្យសងសោហ៊ុយរបស់ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន[64]ករណីម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានបានចេញចំណាយជាចាំបាច់សម្រាប់ការគ្រប់គ្រង និងថែរក្សាវត្ថុ ចំពោះវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាន ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាននោះ អាចទាមទារឱ្យកម្មសិទ្ធិករនៃវត្ថុនោះសងនូវចំណាយនោះវិញបាន។ ប្រសិនបើម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានបានចេញ ចំណាយបង្កើនតម្លៃនៃវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាន ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន នោះអាចទាមទារឱ្យកម្មសិទ្ធិករនៃវត្ថុនោះសងនូវចំណាយទាំងអស់ដែលខ្លួនបានចេញ ឬ សងនូវតម្លៃប្រាក់ដែលកើននោះវិញ តាមការជ្រើសរើសរបស់ខ្លួនបាន ក្នុងករណីដែលកំណើននោះនៅតែមាន។ តុលាការអាចកំណត់ពេលសមរម្យ ដើម្បីសងតាមការទាមទាររបស់កម្មសិទ្ធិករបាន។[65]

[63] មាត្រា ៨២៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[64] មាត្រា ៨៩៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[65] មាត្រា ៨២៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

# ជំពូកទី៣

# ការអនុវត្តសិទ្ធិប្រាតិភោគដោយ

# អនុប្បទាន

# ជំពូកទី៣
# ការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន

បន្ទាប់ពីបានបកស្រាយយ៉ាងក្បោះក្បាយអំពីសញ្ញាណគតិយុត្តសំខាន់ៗ នៃប្រាតិភោគដោយអនុប្បទាន និង អានុភាពនៃប្រាតិភោគដោយអនុប្បទាននៅក្នុង ជំពូកនេះយើងនឹងធ្វើការបកស្រាយអំពី ការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន។ នៅក្នុងដំណើរការនៃប្រាតិភោគដោយអនុប្បទាន ការអនុវត្តគឺមានលក្ខណៈដូចទៅនឹងកិច្ចដំណើរការនៃការបង្កើតសិទ្ធិ ឬ កិច្ចសន្យាផ្សេងៗផងដែរ កិច្ចដំណើរការនេះគឺត្រូវបានឆ្លងកាត់ដំណាក់កាលនៃការបង្កើតកិច្ចសន្យា ដោយយើងត្រូវបំពេញនូវលក្ខខណ្ឌដូចបានលើកឡើងនៅក្នុងជំពូកទី១ ពោលគឺលក្ខខណ្ឌគ្រឹះ លក្ខខណ្ឌទម្រង់ និង លក្ខខណ្ឌតតាំង។

ក្នុងជំពូកនេះដែល នឹងជួយអ្នកអានមានការយល់ដឹងកាន់តែច្បាស់អំពីការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន ព្រមទាំងអាចយកទៅប្រើប្រាស់ក្នុងការរស់នៅប្រចាំថ្ងៃជៀសវាងការក្លែងបន្លំពីជនខិលខូចមួយចំនួន។

## ៣.១ ការអនុវត្តក្នុងការចាត់ចែងវត្ថុ

ជាទូទៅ នៅពេលដែលមានការធ្វើប្រាតិភោគដោយអនុប្បទាន គឺតែងមានការផ្ទេរនូវការកាន់កាប់នូវវត្ថុដែលជាកម្មវត្ថុ។ ការផ្ទេរការកាន់កាប់នោះទៀតសោត គឺចាំបាច់ត្រូវបង្កើតជាកិច្ចសន្យាត្រឹមត្រូវ ព្រមទាំងមានលក្ខខណ្ឌច្បាស់លាស់ក្នុងការអនុវត្តផងដែរ។ ហេតុដូចនេះបានលើកឡើងនេះនៅពេលដែរកិច្ចសន្យាមួយត្រូវបានផុតកំណត់ មានន័យថាការកាន់កាប់ទៅលើវត្ថុនោះក៏ត្រូវបានផុតកំណត់ផងដែរ។ អ្នកកាន់កាប់វត្ថុដោយចំពោះត្រូវធ្វើការប្រគល់វត្ថុទៅឱ្យអ្នកបង្កើតវិញ ឬធ្វើការចាត់ចែងទៅលើវត្ថុនោះក្នុងករណីដែលមិនបានទទួលនូវសំណងរបស់ខ្លួន។ ជាក់ស្តែងនៅក្នុងសង្គមខ្មែរបច្ចុប្បន្ន ការខ្ចីប្រាក់ កូនបំណុលមួយចំនួន មិនបានសងត្រឡប់មកឱ្យម្ចាស់បំណុលវិញនោះ ហេតុដូច្នេះហើយទើបក្រមរដ្ឋប្បវេណីបានបញ្ញត្តិអំពីការចាត់ចែងវត្ថុ។ ដើម្បីអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទានមានវិធីពីរយ៉ាងគឺ ទីមួយការប្តូរវត្ថុដែលកម្មវត្ថុជាប្រាក់ ហើយមួយទៀតគឺអនុប្បទានជាស្ថាពរ។[66]

### ៣.១.១ ការប្តូរវត្ថុដែលជាកម្មវត្ថុជាប្រាក់

ក្នុងករណីដែលម្ចាស់សិទ្ធិមិនបានទទួលសំណងទាន់ពេលវេលានោះទេ ម្ចាស់សិទ្ធិអាចធ្វើការទាមទារឱ្យមានការប្តូរវត្ថុដែលជាកម្មវត្ថុជាប្រាក់បាន។ ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានអាចប្តូរវត្ថុដែលជាកម្មវត្ថុនោះជាប្រាក់ដោយផ្ទាល់ខ្លួន ឬ ធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើវត្ថុដែលជា កម្មវត្ថុជាស្ថាពរបានដោយជូនដំណឹងទៅ

[66] មាត្រា ៨៩៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៦

អ្នកបង្កើត ក្នុងករណីបើកាតព្វកិច្ចពុំត្រូវបានអនុវត្ត។[67] តាមការចែងក្នុងកថាខណ្ឌទី១នេះ ច្បាប់បានផ្តល់អំណាចឱ្យទៅម្ចាស់បំណុលក្នុងការប្តូរវត្ថុទៅជាប្រាក់ ឬ អាចធ្វើលទ្ធកម្មទៅឱ្យតតិយជនដែលការធ្វើលទ្ធកម្មនោះត្រូវប្រព្រឹត្តដោយបំពេញនូវលក្ខខណ្ឌ ស្តីអំពីលទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ។[68] បន្ទាប់ពីបានធ្វើការប្តូរវត្ថុនោះជាប្រាក់ហើយ ឬ បានធ្វើលទ្ធកម្មទៅលើវត្ថុនោះរួចហើយ អ្នកបង្កើតគឺពុំអាចធ្វើការតតាំងបានឡើយ។

*ឧទាហរណ៍៖ ក្នុងករណីដល់កាលបរិច្ឆេទកំណត់សង តែ ក មិនសងទេនោះ ខ អាចធ្វើ ការចាត់ចែងវត្ថុដែលជាកម្មវត្ថុនោះជាប្រាក់ដោយខ្លួនគាត់បាន ដោយគ្រាន់តែជូនដំណឹងទៅអ្នកបង្កើតសិទ្ធិប្រាតិភោគ។*

ក្នុងករណីដែលអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ឬ តតិយជនដែលបានទទួលការបញ្ជាពីអ្នកបង្កើតនេះកាន់កាប់វត្ថុដែលជាកម្មវត្ថុដោយចំពោះម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន អាចទាមទារឱ្យជននោះប្រគល់វត្ថុដែលជាកម្មវត្ថុនោះបាន។[69] ដោយឡែក ប្រសិនបើតម្លៃនៃវត្ថុដែលជាកម្មវត្ថុមានចំនួនលើសពីចំនួនទឹកប្រាក់នៃកាតព្វកិច្ចដែលត្រូវសងម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ត្រូវបង់ចំនួនទឹកប្រាក់ដែលលើសនោះ ទៅឱ្យអ្នកបង្កើតដោយចាត់ជាប្រាក់ជម្រះ។[70] តាមសេចក្តីពន្យល់ ម្ចាស់សិទ្ធិករណីកិច្ចសងប្រាក់ជម្រះ ដើម្បីកុំឱ្យម្ចាស់សិទ្ធិនោះទទួលចំណេញហួសហេតុពេក។ តែទោះជាយ៉ាងណាក្នុងការអនុវត្តជាក់ស្តែងវិញគេសង្កេតឃើញថា នៅតាមហាងបញ្ចាំ ឬ ប្រាតិភោគដោយអនុប្បទាន ម្ចាស់សិទ្ធិភាគច្រើនមិនធ្វើការប្រគល់ ឬ ចាត់ចែងប្រាក់លើសទៅឱ្យអ្នកបង្កើតវិញឡើយ។

### ៣.១.២ អនុប្បទានជាស្ថាពរ

ក្រៅពីជម្រើសនៃការចាត់ចែងដោយការប្តូរជាប្រាក់ ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានអាចប្រើជម្រើសដោយការធ្វើអនុប្បទានជាស្ថាពរ។ ក្នុងករណីដែលម្ចាស់សិទ្ធិមានបំណងចង់ទទួលទុកនូវវត្ថុនោះតែម្តងដូចនេះម្ចាស់សិទ្ធិអាចធ្វើអនុប្បទានជាស្ថាពរ ដោយធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើវត្ថុដែលបានដាក់ធានានោះបានតែម្តង។ ប្រសិនបើកម្មវត្ថុមានតម្លៃលើសលប់ គូភាគីអាចធ្វើការចរចារគ្នា ដើម្បីឱ្យម្ចាស់សិទ្ធិទូទាត់ទឹកប្រាក់ជូនឱ្យអ្នកបង្កើតសិទ្ធិនោះវិញ។

ជារួមមក មធ្យោបាយទាំងពីរខាងលើ ក្នុងករណីកូនបំណុលមិនធ្វើការសងប្រាក់កម្ចីទាន់ពេលវេលានេះគឺយើងអាចអនុវត្តសិទ្ធិរបស់ខ្លួនបានដូចការបកស្រាយនេះ។ ទោះបីមានចែងដូចនេះក្តី ក៏វាហាក់ដូចជាអត្ថន័យ

---

[67] មាត្រា ៨៩៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[68] មាត្រា ១៩៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[69] មាត្រា ៨៩៨ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[70] មាត្រា ៨៩៨ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

នៅមានភាពទូលំទូលាយផងដែរ ព្រោះការអនុវត្តជាក់ស្តែងកន្លងមកគឺមិនបានអនុលោមតាមច្បាប់ទាំងស្រុងទេ តែវាអាស្រ័យទៅតាមការចរចារនៃគូភាគីកិច្ចសន្យាតែប៉ុណ្ណោះ។

### ៣.២ ការប្រគល់វត្ថុដែលជាកម្មវត្ថុឱ្យអ្នកបង្កើត

វត្ថុដែលជាកម្មវត្ថុក្នុងប្រាតិភោគដោយអនុប្បទាន គឺធ្វើការដាក់ធានាដើម្បីខ្ចីប្រាក់ នេះបានឱ្យយើងដឹងថា កាលណាដែលកាតព្វកិច្ចត្រូវបានបំពេញ វត្ថុដែលជាកម្មវត្ថុក៏លែងត្រូវជាកម្មវត្ថុនៃកិច្ចសន្យាទៀតដែរ ដោយហេតុថាកិច្ចសន្យានោះនឹងត្រូវរលត់។

### ៣.៣ ករណីកិច្ចត្រូវបង់ប្រាក់ដែលលើស

ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ត្រូវបង់នូវចំនួនទឹកប្រាក់ដែលលើសនៃចំនួនទឹកប្រាក់កាតព្វកិច្ចទៅអ្នកបង្កើតវិញដោយចាត់ទុកថាជាប្រាក់ជម្រះ។[71] មានន័យថាទោះបីជាម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានប្រើជម្រើសណាមួយក៏ដោយ ក៏ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានមានករណីយកិច្ចត្រូវបង់ចំនួនលើសទឹកប្រាក់នៃកាតព្វកិច្ចដែលត្រូវសង។

### ៣.៤ សិទ្ធិទទួលយកមកវិញរបស់អ្នកបង្កើត

ជាគោលការណ៍ បើដល់កាលបរិច្ឆេទសងហើយប៉ុន្តែនៅមិនទាន់ទទួលបានសំណងនោះ ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានប្រើជម្រើសណាមួយក៏ដោយ ដើម្បីអនុវត្ត តែបើអ្នកបង្កើតបានសង ទោះបីជានៅក្រោយកាលកំណត់បានសងក៏ដោយ ប៉ុន្តែនៅមុនពេលបង់ប្រាក់ដែលលើសនោះកម្មសិទ្ធិត្រូវផ្ទេរទៅឱ្យអ្នកបង្កើតវិញ។

*ឧទាហរណ៍៖ ក្រោយដល់ពេលកំណត់ ខ បានជូនដំណឹងទៅ ក ហើយបានយកទំនិញនោះពីក្នុងឃ្លាំងដើម្បីប៉ាន់ស្មានតម្លៃ ហើយលក់ទំនិញទាំងនោះ។ មុនពេលបញ្ចប់ការវាយតម្លៃ ក ពិតជាមានសំណាងដែលមានទឹកប្រាក់គ្រប់គ្រាន់ដើម្បីសងបំណុល ហើយបានទាមទារឲ ខ ប្រគល់ទំនិញត្រឡប់មកវិញ។ ក្នុងករណីនេះ ក មាន សិទ្ធិទាមទារវិញបាន។ ប៉ុន្តែបើ ខ លក់ គ ហើយនោះ ក ពុំអាចទាមទារវិញបាននោះទេតែអាចទាមទារសំណងបានពីព្រោះសិទ្ធិទទួលបានមកវិញត្រូវរលត់ដោយការបញ្ចប់ការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន។*

### ៣.៥ ស្ថាប័នមានសមត្ថកិច្ចទាក់ទិននឹងការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន

#### ៣.៥.១ ក្រសួងយុត្តិធម៌

មុននឹងមានក្រមរដ្ឋប្បវេណី តាមអនុក្រឹត្យស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌ ឆ្នាំ ២០០០ ក្រសួងយុត្តិធម៌ ជាស្ថាប័នដែលមានភារកិច្ចតាក់តែងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិទាំងឡាយស្តីអំពី

---

[71] មាត្រា ៨៩៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

នីតិព្រហ្មទណ្ឌ នីតិវិធីព្រហ្មទណ្ឌ នីតិរដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី។[72] បន្ទាប់ពីបង្កើតក្រមរដ្ឋប្បវេណីអនុក្រឹត្យស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌ ឆ្នាំ ២០១៤ បញ្ញត្តិអំពីភារកិច្ចរបស់ក្រសួងយុត្តិធម៌ជាស្ថាប័នដែលកសាងសេចក្តីព្រាងច្បាស់ បទដ្ឋានគតិយុត្តិផ្សេងៗ នៅក្នុងវិស័យយុត្តិធម៌ទទួលពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់របស់ក្រសួងស្ថាប័ននានា។ បន្ថែមពីនេះទៀត ក្រសួងយុត្តិធម៌ ក៏ទទួលបន្ទុកលើការតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិទាំងឡាយក៏ដូចជាពិនិត្យ និងផ្តល់យោបល់លើបញ្ហានានាដែលទាក់ទងនឹងកិច្ចការរដ្ឋបុរី និងកិច្ចការព្រហ្មទណ្ឌផងដែរ។

ទាក់ទិននឹងការទទួលបន្ទុកលើការតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិទាំងឡាយក៏ដូចជាពិនិត្យ និងផ្តល់យោបល់លើបញ្ហានានាដែលទាក់ទងនឹងកិច្ចការរដ្ឋប្បវេណីនេះ ក្រសួងយុត្តិធម៌ជា ស្ថាប័នដែលមានសមត្ថកិច្ចដោយផ្ទាល់ក្នុងការពិនិត្យ និងផ្តល់យោបល់លើបញ្ហានានាដែលទាក់ទង នឹងប្រាតិភោគដោយអនុប្បទាន ព្រមទាំងតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ ដើម្បីដោះស្រាយនូវបញ្ហានោះផងដែរ។

### ៣.៥.២ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចគ្រប់គ្រង និងត្រួតពិនិត្យអាជីវកម្មទទួលបញ្ចាំ ទិញលក់ទ្រព្យបញ្ចាំ នឹងអាជីវកម្មទទួលប្រាតិភោគដោយ ឬទាន ដោយមាននាយកដ្ឋានគ្រប់គ្រងអាជីវកម្មបញ្ចាំ និងប្រាតិភោគដោយអនុប្បទានជាសេនាធិការ ដែលបំពេញមុខងារលើការងារគ្រប់គ្រងអាជីវកម្ម បញ្ចាំ និងប្រាតិភោគដោយអនុប្បទានផងដែរ។[73] បន្ថែមពីនេះទៀត ក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏ជាស្ថាប័នតែមួយគត់ដែល មានសមត្ថកិច្ចក្នុងការពិនិត្យ និងសម្រេចផ្តល់ ឬបដិសេធ ឬ បន្តសុពលភាពដល់ក្រុមហ៊ុនដែលប្រកបអាជីវកម្មប្រាតិភោគដោយអនុប្បទានផងដែរ។[74] លើសពីនេះទៅទៀត ក្រសួងនេះក៏មានសមត្ថកិច្ចក្នុងការដាក់ទណ្ឌកម្មជាការព្រមាន ឬពិន័យអន្តរការណ៍ចំពោះសកម្មភាពខុសច្បាប់នានាទាក់នឹងអាជីវកម្ម ប្រាតិភោគដោយអនុប្បទានផងដែរ។[75]

ករណីមានវិវាទរវាងក្រុមហ៊ុនទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទាន ជាមួយក្រុមហ៊ុនទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទាន ឬអ្នកដាក់ប្រាតិភោគដោយអនុប្បទានពាក់ព័ន្ធនឹងសកម្មភាព អាជីវកម្មបញ្ចាំ ឬ ប្រាតិភោគដោយអនុប្បទាន អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ឬ មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

[72] មាត្រា ៩ និង មាត្រា ១០ នៃអនុក្រឹត្យស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌, ឆ្នាំ ២០០០

[73] មាត្រា៤៩ មាត្រា៥០ ព្រឹក្សាស្តីពីការរៀបចំ និងព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឆ្នាំ ២០១៣

[74] ប្រការ ៦ និងប្រការ៧ ស្តីពីប្រកាសអាជីវកម្មបញ្ចាំ និង ប្រាតិភោគដោយអនុប្បទាន, ឆ្នាំ ២០១៧

[75] ប្រការ ៣៣ ដល់ ប្រការ ៣៨ ស្តីពីការប្រកាសអាជីវកម្មបញ្ចាំ និង ប្រាតិភោគដោយអនុប្បទាន, ឆ្នាំ ២០១៧

អាចដើរតួនាទីជាអ្នកផ្សះផ្សា បានតាមរយៈកិច្ចព្រមព្រៀងផ្សះផ្សា ដែលត្រូវចុះហត្ថលេខាដោយគូភាគីនៃវិវាទ ដោយមានប្រថាប់ត្រារបស់អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ឬ មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។[76] ប្រសិនបើក្រុមហ៊ុនទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទាន ឬ អ្នកដាក់ប្រាតិភោគដោយអនុប្បទាន មិនពេញចិត្ត ចំពោះសេចក្ដីសម្រេច វិធានការផ្សេងៗរបស់អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ឬ មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ភាគីមិនពេញចិត្តមានសិទ្ធដាក់ពាក្យបណ្ដឹងតវ៉ាទៅកាន់ក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មុននឹងអនុវត្តនីតិវិធីបណ្ដឹងទៅតុលាការ។ ការដោះស្រាយវិវាទក្រៅតុលាការដោយក្រសួង ឬ មន្ទីរបែបនេះ ជាយន្តការមួយដែលអាចជួយសម្រួលដល់ការដោះស្រាយវិវាទ ដោយអាចឱ្យគូភាគីទទួលបាននូវការប្រឹក្សាផ្នែកច្បាប់ មុននឹងឈានដល់ការដោះស្រាយតាមប្រព័ន្ធតុលាការមាននីតិវិធីស្មុគស្មាញ ព្រមទាំងចំណាយថវិកា និងពេលវេលាថែមទៀតផង។

#### ៣.៥.៣ ស្ថាប័នតុលាការ

ថ្វីបើភាគីអាចធ្វើការដោះស្រាយក្រៅប្រព័ន្ធតុលាការ ដោយប្រើប្រាស់យន្តការរបស់ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុក៏ពិតមែន ប៉ុន្តែដំណោះស្រាយនេះ ពុំមានអានុភាពបង្ខំអនុវត្តនោះទេ ប្រសិនបើ មានភាគីណាមួយមិនយល់ស្រប និងព្រមព្រៀងទៅលើដំណោះស្រាយ។ អាស្រ័យហេតុនេះហើយ ទើបស្ថាប័នតុលាការនៅតែជាជម្រើសដ៏សំខាន់ ដែលមានសិទ្ធិអំណាចក្នុងការជម្រះក្ដីទាក់ទង នឹង ប្រាតិភោគដោយអនុប្បទានក៏ដូចជារឿងក្ដីផ្សេងៗទៀតផងដែរព្រោះមានតែសេចក្ដីសម្រេចស្ថាពររបស់តុលាការទេដែលមានអានុភាពចាប់បង្ខំឱ្យភាគីគោរពតាម។

### ៣.៦ ការអនុវត្តក្នុងការប្រកបអាជីវកម្មប្រាតិភោគដោយអនុប្បទាន

#### ៣.៦.១ ការប្រកបអាជីវកម្មប្រាតិភោគដោយអនុប្បទានមានអាជ្ញាបណ្ណ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ កាលពីឆ្នាំ២០១០ បានចេញប្រកាសស្ដីពីការគ្រប់ដណ្ដប់លើអាជ្ញាប័ណ្ណនៃអាជីវកម្ម។ កាលពីចុងឆ្នាំ២០១៦ ក្រសួងកែសម្រួលប្រកាសនោះឡើងវិញ ដើម្បីធ្វើឱ្យវាស្របនឹងភាពពិតរបស់វិស័យនេះ ដែលមានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាបញ្ញត្តិករ និងមាននាយកដ្ឋានគ្រប់គ្រងអាជីវកម្ម អចលនវត្ថុបញ្ចាំ និងប្រាតិភោគដោយអនុប្បទាននៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុជាសេនាធិការ។ បើស្របតាមការ ប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវរាល់អាជីវកម្មដែលទទួលប្រាក់បញ្ចាំត្រូវតែសុំការអនុញ្ញាតិ ឬមានអាជ្ញាប័ណ្ណត្រឹមត្រូវពីក្រសួងដើម្បីដំណើរការអាជីវកម្មដោយស្របច្បាប់បាន ។ មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត បំពេញភារៈកិច្ចសម្របសម្រួល និងគាំទ្រការត្រួតពិនិត្យអាជីវកម្មទទួលបញ្ចាំខ្នាតតូចនៅតាម

---

[76] ប្រការ ៣១ ស្ដីពីការប្រកាសអាជីវកម្មបញ្ចាំ និង ប្រាតិភោគដោយអនុប្បទាន, ឆ្នាំ ២០១៧

រាជធានី-ខេត្ត។ ប្រជាពលរដ្ឋកម្ពុជាអាចដាក់ពាក្យស្នើសុំប្រកបអាជីវកម្មហាងបញ្ចាំខ្នាតតូចនៅមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរាជធានី-ខេត្តដោយបំពេញលក្ខខណ្ឌដូចជា៖

- ជានីតិបុគ្គលសញ្ជាតិខ្មែរ និងស្ថាប័នដែលបានចុះបញ្ជីពាណិជ្ជកម្មស្របតាមច្បាប់របស់ប្រទេសកម្ពុជា។
- ត្រូវមានដើមទុនប្រកបអាជីវកម្មតាមខ្នាតអាជីវកម្មដែលបានស្នើរសុំ
- ត្រូវតម្កល់ប្រាក់ធានាអាជីវកម្ម ១០% នៃដើមទុន
- អ្នកកាន់លិខិតអនុញ្ញាតិប្រកបអាជីវកម្មត្រូវមានកម្រិតវប្បធម៌ថ្នាក់បរិញ្ញាបត្រ ឬវិញ្ញាបនបត្រផ្សេងៗ ឬ សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬមានបទពិសោធន៍ពាក់ព័ន្ធទៅនឹងអាជីវកម្មស្រដៀងគ្នា ប្រសិនបើអ្នកឈរឈ្មោះមិនមែនជាម្ចាស់ភាគហ៊ុន ត្រូវមានលិខិតបញ្ជាក់ដោយអាជ្ញាធរមាន សមត្ថកិច្ច។[77]
- ត្រូវមានទីតាំងប្រកបអាជីវកម្មច្បាស់លាស់ដែលបញ្ជាក់ដោយអាជ្ញាធរមានសមត្ថកិច្ច។ លក្ខខណ្ឌ លម្អិតសម្រាប់ការដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតិ ប្រកបអាជីវកម្មមានកំណត់ក្នុងពាក្យស្នើសុំរបស់ មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ការរៀបចំប្រព្រឹត្តទៅរបស់ អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ អាជីវកម្មហាង បញ្ចាំស្ថិតនៅក្រោមការគ្រប់គ្រង និងត្រួតពិនិត្យនៃនិយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើសពីនេះ ប្រកាសស្តីពីការគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន ឆ្នាំ២០១៦ នឹងកំពុងត្រូវបានកែ សម្រួលម្តងទៀតក្នុងពេលនេះ។ ការប្រកបអាជីវកម្មស្របច្បាប់គឺដើម្បីអាចរក្សា បាននូវសណ្តាប់ធ្នាប់សង្គម ជៀសសវាងម្ចាស់អាជីវកម្មទទួលទ្រព្យបញ្ចាំពីករណីលួចប្លន់ជាដើម។ ម្យ៉ាងទៀត អ្នកខ្ចីគួរពិនិត្យមើលទីតាំង ទីកន្លែង និងលិខិតកិច្ចសន្យាឱ្យច្បាស់លាស់ ជៀសសវាងអាជីវកម្មមិនស្របច្បាប់ ដែលអាចធ្វើឱ្យខាតបង់ទ្រព្យធនរបស់អ្នកផងដែរ។[78]

### ៣.៦.២ ការប្រកបអាជីវកម្មប្រាតិភោគដោយអនុប្បទានពុំមានអាជ្ញាបណ្ណ

ទាក់ទិនជាមួយផ្នែកសមត្ថកិច្ច ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាស្ថាប័នដែលគ្រប់គ្រង ត្រួតពិនិត្យ នឹង ផ្តល់អាជ្ញាបណ្ណ ឬ លិខិតអនុញ្ញាតប្រកបអាជីកម្មទៅដល់ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន។ ដូចនេះ ប្រសិនបើមានការប្រកបអាជីវកម្ម ដោយពុំមានអាជ្ញាបណ្ណ ឬ លិខិតអនុញ្ញាតប្រកបអាជីវកម្មនោះទេ បញ្ហាមួយ ចំនួនកើតឡើងដូចជាការវាយតម្លៃវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាន មានតម្លៃទាបជាងទីផ្សារ ការ

[77] ប្រកាសស្តីពីការគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំ និង ទទួលប្រាតិភោគដោយអនុប្បទាន

[78] យោងតាមអនុក្រឹត្តលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ កក្កដារ ២០២១ ប្រកាសស្តីពីការគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំ និង ទទួល ប្រាតិភោគដោយអនុប្បទាន

ទទួលប្រាតិភោគដោយអនុប្បទាន ការយកអត្រាកាប្រាក់ខ្ពស់ហួសហេតុ ឬ កាត់យក ការប្រាក់ជាមុន ការលួចប្តូរសមាសភាគខ្លះ វត្ថុដែលជាកម្មវត្ថុ នៃប្រាតិភោគដោយអនុប្បទាន (ភាគច្រើនកើតទៅលើយានយន្ត និងគ្រឿងអេឡិចត្រូនិច ដោយការលួចផ្លាស់ប្តូរ ផ្នែកខ្លះ ជំនួសដោយគ្រឿងបន្ទាស់ដែលមានគុណភាពមិនល្អ ការប្រើប្រាស់ទ្រព្យម្ចាស់សិទ្ធិដោយគ្មានការ អនុញ្ញាត មិនមានទម្រង់កិច្ចសន្យា (ទម្រង់ដែលចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)[79]ច្បាស់លាស់ ដែលអាចធ្វើឱ្យខាតប្រយោជន៍អ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន និងបញ្ហាមិនបានបង់ពន្ធចូលរដ្ឋ។

ដូចនេះ ការប្រកបអាជីវកម្មប្រាតិភោគដោយអនុប្បទានដោយពុំមានអាជ្ញាបណ្ណ ឬ លិខិតអនុញ្ញាត ប្រកបអាជីវកម្មប្រាតិភោគដោយអនុប្បទាន ផ្តល់ផលប៉ះពាល់ដល់សង្គមខ្លាំងណាស់។ បញ្ហាការប្រកបអាជីវកម្មដោយពុំមានអាជ្ញាបណ្ណនេះ អាចធ្វើទៅបានដោយសារតែមានបញ្ហាអំពើពុករលួយ និង/ឬ ច្បាប់មិនមាន បច្ចុប្បន្ន។ ជាដំណោះស្រាយប្រទេសមួយចំនួនប្រើប្រាស់អាជីវកម្មនេះដោយលើកទឹកចិត្តឱ្យប្រជាជនផ្តល់ដំណឹង អំពីការប្រព្រឹត្តបទល្មើស ដោយការផ្តល់រង្វាន់លើកទឹកចិត្តមួយចំណែក ដែលបានមកពីការពិន័យទៅលើជនល្មើស។ ជាក់ស្តែងចំពោះសហរដ្ឋអាមេរិកផ្តល់រង្វាន់លើកទឹកចិត្ត មិនលើសពី ៣០% នៃប្រាក់ពិន័យ (អាស្រ័យទៅតាមកត្តាផ្សេងៗតាមឆន្ទានុសិទ្ធិរបស់តុលាការ) សម្រាប់ជនដែលបានរាយការណ៍អំពីបទល្មើស ។

## ៣.៧ អត្រាការប្រាក់ក្នុងការប្រកបអាជីវកម្មប្រាតិភោគដោយអនុប្បទាន

ប្រសិនបើ ភាគីនៃកិច្ចសន្យាយល់ព្រមលើអត្រាការប្រាក់នៅក្នុងកិច្ចសន្យាអត់ការប្រាក់ដែលត្រូវអនុវត្តគឺជាអត្រាការប្រាក់ក្នុងកិច្ចសន្យា។ ចំពោះការខ្ចីបរិភោគធម្មតា អត្រាការប្រាក់ គឺត្រូវបានព្រមព្រៀងដោយភាគីទាំងសងខាង។

ក្នុងករណីដែលភាគីនៃកិច្ចសន្យា បានយល់ព្រមថាអត្រាការប្រាក់នឹងត្រូវបង្កើតឡើង ប៉ុន្តែមិនបាន សម្រេចអំពីអត្រាការប្រាក់ទេ អត្រាការប្រាក់ត្រូវគិតចំនួន ៥ ភាគរយក្នុងមួយឆ្នាំដែលជាអត្រាការប្រាក់ដែលកំណត់ដោយច្បាប់។[80]

អត្រាការប្រាក់ក្នុងកិច្ចសន្យា អាចសម្រេចបានដោយសេរី រវាងភាគីនៃកិច្ចសន្យា។ ទោះបីជាយ៉ាងនេះក៏ដោយ បើសិនជាដាក់ការប្រាក់ខ្ពស់ពេក កូនបំណុលក៏មិនអាចមានលទ្ធភាពសងដែរ ដូច្នេះក្នុងប្រទេសជាច្រើនគេមានច្បាប់ស្តីពីការកម្រិតអត្រាការប្រាក់។ បើទោះបីជាច្បាប់ស្តីពីការកម្រិតអត្រាការប្រាក់មិនមានក៏ដោយ

[79] មាត្រា ៨៣២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[80] មាត្រា ៣១៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

កិច្ចសន្យាដែលកំណត់ អត្រាការប្រាក់ត្រូវទុកជាមោឃៈ នៅពេលដែលកិច្ចសន្យាផ្ទុយ នឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ។[81]

តាមមាត្រា ១៧ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ឆ្នាំ២០១១ បានកំណត់ថាអត្រាការប្រាក់ដែល ត្រូវបានកម្រិតត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រឹមអត្រាចាប់ពី ១០% ដល់ ៣០% ឆ្នាំ ក្នុង ១ ឆ្នាំ ។[82]

ប្រការ១នៃប្រកាសស្តីពីអត្រាការប្រាក់ដែលត្រូវបានកម្រិត ឆ្នាំ២០១១ បានចែងថាអត្រាការប្រាក់ដែលត្រូវបានកម្រិត ដែលបានកំណត់កថាខណ្ឌទី ១ នៃមាត្រា ១៧ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណៈ ត្រូវបានកំណត់មិនឲ្យលើសពី ១៨% ក្នុង១ឆ្នាំ១៥ ។

យោងតាមសេចក្តីប្រកាសព័ត៌មាន ស្តីពីការដាក់ពិដានអត្រាការប្រាក់ឥណទាន របស់ធនាគារជាតិនៃកម្ពុជាលេខ ធ៧.០១៧,១០៩ ប្រក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៧ បានសម្រេចដាក់ពិដានអត្រាការប្រាក់ទៅលើឥណទានមានកម្រិត ១៨% ក្នុង១ឆ្នាំ ហើយនឹងត្រូវអនុវត្តចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៧ នេះតទៅជាកំហិត ។ ការដាក់ពិដានឥណទាននេះ គឺជាការដាក់កម្រិតអតិបរមានៃអត្រាការប្រាក់ឥណទាន ដែលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងប្រតិបត្តិករឥណទានជនបទទាំងអស់ អាចកំណត់យកពីអតិថិជនដែលខ្ចីប្រាក់ពីគ្រឹះស្ថាន។[83]

លើសពីនេះ អត្រាការប្រាក់ក្នុងកិច្ចសន្យាត្រូវកំណត់ផ្អែកលើអត្រាការប្រាក់ប្រចាំឆ្នាំ ប៉ុន្តែក្នុងករណីដែលការប្រាក់ត្រូវបានកំណត់តាមការព្រមព្រៀងរបស់ភាគីនៃកិច្ចសន្យា ភាគីនៃកិច្ចសន្យាអាចព្រមព្រៀងគ្នាថាតើការប្រាក់ត្រូវបង្កើតឡើងជារៀងរាល់ឆ្នាំ រៀងរាល់ខែ ឬ រៀងរាល់ថ្ងៃ ។

[81] មាត្រា ៣៥៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[82] មាត្រា ១៧ ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ ២០១១

[83] យោងតាមសេចក្តីប្រកាសព័ត៌មានស្តីពីការដាក់ពិដានអត្រាការប្រាក់ឥណទានរបស់ធនាគារជាតិនៃកម្ពុជា, ឆ្នាំ២០០៧

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមការសិក្សាស្រាវជ្រាវសរសេរបកស្រាយខាងលើរួចមក យើងឃើញថាប្រទេសកម្ពុជាមានច្បាប់ និង បទប្បញ្ញត្តិដែលទាក់ទងនឹងសិទ្ធិប្រាតិភោគដោយអនុប្បទានទាំងនៅក្នុងក្រមរដ្ឋប្បវេណី ប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ព្រមទាំង អនុក្រឹត្យផ្សេងៗទៀតទាក់ទងនិងសិទ្ធិប្រាតិភោគដោយអនុប្បទាន។ ដោយឡែក ប្រជាជន និង អ្នកសិក្សាមួយចំនួនធំនៅមានការភ័ន្តច្រឡំរវាងប្រាតិភោគដោយអនុប្បទាន និង ការបញ្ចាំនៅឡើយ។ ហេតុនេះហើយទើបសារណានេះលេចរូបរាងឡើងព្រោះចង់ស្រាវជ្រាវ និង ពង្រីកការយល់ដឹងអំពីប្រធានបទនេះជៀសវាសការបោកប្រាស់ពីជនទុច្ចរិត មួយចំនួនក្នុងប្រទេសកម្ពុជា។ ដោយមើលឃើញថាការប្រកបអាជីវកម្មប្រាតិភោគដោយអនុប្បទាន ដោយពុំមានអាជ្ញាបណ្ណបានជះឥទ្ធិពលយ៉ាងខ្លាំងលើការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន បើទោះបីជាមានបទបញ្ញត្តិកំណត់រួចទៅហើយក្តី។ ដោយឡែកប្រសិនបើបុគ្គលណាម្នាក់ចង់បង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន រមែងត្រូវបំពេញនូវលក្ខខណ្ឌគ្រឹះដែលជាលក្ខខណ្ឌដ៏សំខាន់ដើម្បីឱ្យកិច្ចសន្យាមានសុពលភាពទៅតាមច្បាប់។ សិទ្ធិប្រាតិភោគដោយអនុប្បទាន មានអានុភាពលើវត្ថុដែលភ្ជាប់នឹងវត្ថុដែលជាកម្មវត្ថុនៅពេលដែលបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន។ អានុភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន កើតមានឡើងនៅពេលដែលកិច្ចសន្យាត្រូវបានបង្កើតឡើងភ្ជាប់ជាមួយលក្ខខណ្ឌត្រឹមត្រូវ។ យ៉ាងណាមិញ ចំពោះការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទានវិញ គឺមានលក្ខណៈងាយស្រួលហើយប្រហាក់ប្រហែលទៅនឹងកិច្ចសន្យាផ្សេងទៀតដែរ ដែលតម្រូវឲគូភាគីទាំងសងខាងឈរលើគោលការណ៍នៃការព្រមព្រៀងក្នុងការបង្កើតកិច្ចសន្យានេះឡើង។

កម្រិតយល់ដឹងរបស់ប្រជាជនកម្ពុជាអំពីប្រាតិភោគដោយអនុប្បទាន នៅមានកម្រិត។ ប្រជាជនមួយចំនួនធំមានការភាន់ច្រឡំរវាងការបញ្ចាំ និង ប្រាតិភោគដោយអនុប្បទាន ព្រោះតែការបញ្ចាំ និង ប្រាតិភោគដោយអនុប្បទានមានភាពស្រដៀងគ្នា។ ដោយឃើញថានៅក្នុងសង្គមជាក់ស្តែង ហាងបញ្ចាំបានយកគោលការណ៍នៃសិទ្ធិប្រាតិភោគដោយអនុប្បទានមកប្រើប្រាស់ជំនួសគោលការណ៍នៃសិទ្ធិលើការបញ្ចាំ ដែលគោលការណ៍នៃសិទ្ធិលើការបញ្ចាំ ទាមទារឱ្យឆ្លងកាត់នីតិវិធីតុលាការក្នុងការចាត់ចែងលើវត្ថុដែលជាកម្មវត្ថុ និង នីតិវិធីវង្វាយតម្លៃវត្ថុ។

ចំពោះការប្រកបអាជីវកម្មប្រាតិភោគដោយអនុប្បទានវិញ មានភាពពេញនិយមជាខ្លាំងនៅក្នុងសង្គមបច្ចុប្បន្ន ព្រោះ វិធីបានសម្រួលដល់ជីវភាពរបស់ប្រជាជនដែលកំពុងត្រូវការថវិការ ឬ តម្រូវការផ្សេងទៀតក្នុងការរស់នៅប្រចាំថ្ងៃរបស់ពួកគេ។ ដោយឡែក ទាក់ទិននឹងបញ្ហាការប្រកបអាជីវកម្មប្រាតិភោគដោយអនុប្បទានដោយពុំមានអាជ្ញាបណ្ណបានក្លាយជាឧបសគ្គដ៏ធំមួយ ក្នុងការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទានឱ្យមាន

តម្លាភាពត្រឹមត្រូវផងដែរ។ បញ្ហាទាំងអស់នេះបានកើតឡើងជារឿយៗដោយសារភាពលោភលន់របស់មនុស្សមួយចំនួនតូចក្នុងសង្គមនេះឯង។

ជារួមមក សារណានេះគ្របដណ្តប់ទៅលើប្រាតិភោគដោយអនុប្បទាន រួមមានរបបគតិយុត្តទូទៅទាក់ទងនឹងប្រាតិភោគដោយអនុប្បទាន អានុភាព និងការអនុវត្តទៅលើសិទ្ធិប្រាតិភោគដោយអនុប្បទាន។ កម្រងសារណាមួយនេះនឹងផ្តល់អត្ថប្រយោជន៍ដល់អ្នកអានគ្រប់រូប ឱ្យមានការយល់ដឹងកាន់តែច្បាស់អំពីសិទ្ធិប្រាតិភោគដោយអនុប្បទាន។

# អនុសាសន៍

# អនុសាសន៍

នៅក្នុងប្រទេសកម្ពុជាយើងបច្ចុប្បន្ននេះ ប្រជាជននៅតែមានការភាន់ច្រលំ និងមិនយល់ច្បាស់អំពីប្រាតិភោគដោយអនុប្បទាន ទាំងនេះហើយដែលជាបញ្ហាចោទ។ ដោយមើលឃើញពីបញ្ហាទាំងនេះ ដើម្បីឱ្យប្រជាជនមានការយល់ដឹង លុះត្រាតែមានការយកចិត្តទុកដាក់ពី រដ្ឋាភិបាល ជាពិសេសក្រសួងនានាដូចជាក្រសួងយុត្តិធម៌ ក្រសួងសេដ្ឋកិច្ច និងហរិញ្ញវត្ថុ គប្បីសិក្សាធ្វើការសម្រង់មតិថាតើប្រជាជនប៉ុន្មានភាគរយដែលពួកគេបានយល់ដឹង ប៉ុន្មានអ្នកដែលគ្រាន់តែធ្លាប់លឺ តែមិនដឹងថាមានន័យយ៉ាងណានោះ និងរៀបចំគោលនយោបាយក្នុងការផ្សព្វផ្សាយច្បាប់។ មួយវិញទៀត សញ្ញាណនៃប្រាតិភោគដោយអនុប្បទាននេះ មិនសូវជាត្រូវបានអនុវត្ត អោយត្រូវទៅតាមលក្ខខណ្ឌគតិយុត្តដែលច្បាប់តម្រូវនោះទេ ហើយក៏មិនសូវបានទូលំទូលាយដែរ ដោយកត្តាការយល់ដឹង និងការមិនអនុវត្តទៅតាមច្បាប់តែម្តង ព្រោះប្រជាពលរដ្ឋមួយចំនួនយល់ឃើញថាការបង្កើតប្រាតិភោគដោយអនុប្បទាននេះ ត្រូវចំណាយថវិការច្រើនអនេក ជាជាងផលចំណេញដែលទទួលបានដោយត្រូវការឯកសារ និងរបាយការណ៍ច្រើនដែលមិនបង្កលក្ខណៈងាយស្រួលដល់ពួកគេ។ ទន្ទឹមនឹងនេះ ទើបប្រជាជនយើង ដោយគ្រាន់តែមានការព្រមព្រៀងគ្នាតាមអ្វីដែលពួលគាត់ចង់បាន មិនគិតពីបញ្ហាច្បាប់ជាធំ ថាតើធ្វើបែបនេះខុស ឬត្រូវនោះទេ។ ហេតុនេះហើយ ចាំបាច់ត្រូវមានការផ្សព្វផ្សាយឱ្យបានទូលំទូលាយ ដែលការផ្សព្វផ្សាយនេះ អាចធ្វើទៅបានតាមរយៈការរៀបចំចងក្រងសៀវភៅអប់រំគោលការណ៍ច្បាប់មួយចំនួនដែល ត្រូវបានប្រើប្រាស់សម្រាប់ការប្រកបជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជន រួមទាំងបទប្បញ្ញត្តិដែលទាក់ទិននឹងប្រាតិភោគដោយអនុប្បទានផងដែរ។ សៀវភៅនេះដែរ គប្បីរៀបរៀងដោយប្រើប្រាស់ជាភាសាសាមញ្ញងាយយល់ ឱ្យសមស្របទៅនឹងកម្រិតយល់ដឹងរបស់ប្រជាជន ដោយបញ្ចូលទៅក្នុងកម្មវិធីសិក្សារបស់សិស្សនិស្សិត ដើម្បីជាមូលដ្ឋានគ្រឹះក្នុងការយល់ដឹងច្បាប់ និងអាចអនុវត្តបានក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាជន។

ពាក់ព័ន្ធនឹងការប្រកបអាជីវកម្មនៃប្រាតិភោគដោយអនុប្បទាននេះ ច្បាប់គួរតែមានវិធានការឱ្យបានច្បាស់លាស់លើបញ្ហាមួយចំនួនដូចជា ការដែលពុំមានអាជ្ញាប័ណ្ណប្រកបអាជីវកម្ម និងការប្រកបអំពើមួយមិនត្រឹមត្រូវ ឬដោយខុសច្បាប់ ចំពោះប្រាតិភោគដោយអនុប្បទាននេះឯង ។ ដោយចាំបាច់ត្រូវអនុវត្តច្បាប់ យន្តនាការលើអ្នកដែលបានប្រព្រឹត្តិខុស និងលើកកម្ពស់ដល់ប្រជាជនមួយចំនួនដែលមានអាជីវកម្មមានអាជ្ញាប័ណ្ណត្រឹមត្រូវ ជៀសជាង កុំឱ្យប្រជាជនគិតថាទោះអនុវត្តមិនអនុវត្តក៏នៅតែគ្មានបានប្រយោជន៍អ្វីទាល់តែសោះ ។

# ឯកសារយោង

# ឯកសារយោង

## ១. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តកម្ពុជា

-  រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣។
-  ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។
-  ក្រមរដ្ឋប្បវេណីរបស់ប្រទេសជប៉ុន(បកប្រែជាភាសាខ្មែរ)។
-  ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
-  សេចក្តីពន្យល់ក្រមរដ្ឋប្បវេណីភាគ ១ និង ភាគ ២។
-  ប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលេខ ០៣០ សហវ.ប្រក ឆ្នាំ ២០២៣។
-  ប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលេខស្តីពីការគ្រប់គ្រងអាជីវកម្មដោយបញ្ចាំ និង ប្រាតិភោគដោយអនុប្បទាន។
-  ប្រកាសអាជីវកម្មបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន។
-  ការអនុវត្តប្រាតិភោគដោយអនុប្បទាននៅកម្ពុជា។

## ២. ឯកសារផ្សេងៗពីប្រព័ន្ធ internet (URL)

-  ទទួលបានថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៣

  https://m.freshnewsasia.com/index.php/en/freshnewsplus/281966-2023-03-12-05-00-35.html
-  ទទួលបានថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ២០២៣

  https://www.jica.go.jp/project/cambodia/0701047/04/pdf/laws/01_02k.pdf
-  ទទួលបានថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ២០២៣

  https://drive.google.com/file/d/1lGrYMOZPqiE0kbzQhe2ymDYR4ZqEyGTc/view?usp=sharing
-  ទទួលបានថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ២០២៣

  https://ebooks.elibrary-rule.com/public/images/sarana_file/Thesis2021All%20(52).pdf

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

| ល.រ | ឈ្មោះ | លេខឧបសម្ព័ន្ធ |
|---|---|---|
| ១ | ប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ឧបសម្ព័ន្ធទី១ |
| ២ | ពាក្យសុំការអនុញ្ញាតប្រកបអាជីវកម្ម-សេវាកម្ម | ឧបសម្ព័ន្ធទី២ |

# ឧបសម្ព័ន្ធ ១
# ប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង
# ហិរញ្ញវត្ថុ ស្ដីពីការគ្រប់គ្រងអាជីវកម្ម
# បញ្ចាំ និង ប្រាតិភោគដោយអនុប្បទាន

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ..០៣៣០......សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំ និងទទួលផ្ញើគោគដោយអនុប្បទាន

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខនស/រកម/១២០៨/០២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤
- បានឃើញព្រះរាជក្រមលេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណីឆ្នាំ២០០៨
- បានឃើញអនុក្រឹត្យលេខ៨៨៨អនក្រ/បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ១៣៣០ សហវ.ប្រក ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានក្រោមចំណុះអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងដូចខាងក្រោម÷

- ធានាប្រសិទ្ធភាពនៃការគ្រប់គ្រង និងការត្រួតពិនិត្យអាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទាន
- ធានាសមធម៌ និងតុល្យភាពនៃផលប្រយោជន៍រវាងអ្នកដាក់បញ្ចាំ និងអ្នកទទួលទ្រព្យបញ្ចាំ
- បង្កើតឱ្យមានប្រព័ន្ធផ្គត់ផ្គង់សាច់ប្រាក់ឆាប់រហ័សដោយស្របច្បាប់ក្រៅពីប្រព័ន្ធធនាគារ
- រួមចំណែកទប់ស្កាត់ផលប៉ះពាល់អវិជ្ជមានក្នុងវិស័យទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទានដើម្បីធានានូវសន្តិសុខនិងសណ្តាប់ធ្នាប់សង្គម។

**ប្រការ២.-**

ប្រកាសនេះមានគោលដៅកំណត់ យន្តការ វិធាន និងនីតិវិធីនៃការគ្រប់គ្រង និងការត្រួតពិនិត្យប្រតិបត្តិការអាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះសកម្មភាពពាក់ព័ន្ធនឹងអាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយ-អនុប្បទាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤.-**

ពាក្យបច្ចេកស័ព្ទដែលបានប្រើនៅក្នុងប្រកាសនេះត្រូវបានកំណត់ដូចខាងក្រោម÷

- **ក្រសួង** សំដៅដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- **អគ្គនាយកដ្ឋាន** សំដៅដល់អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- **នាយកដ្ឋាន** សំដៅដល់នាយកដ្ឋានគ្រប់គ្រងអាជីវកម្មអចលនវត្ថុបញ្ចាំ និងប្រាតិភោគដោយអនុប្បទាននៃអគ្គ-នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- **មន្ទីរ** សំដៅដល់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត
- **អាជ្ញាបណ្ណ** សំដៅដល់លិខិតគតិយុត្តិដែលចេញដោយក្រសួង ដើម្បីអនុញ្ញាតឱ្យក្រុមហ៊ុន/សហគ្រាសណាមួយប្រកបអាជីវកម្មទទួលបញ្ចាំ និង/ឬអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាននៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយស្របតាមលក្ខខណ្ឌដូចមានចែងក្នុងប្រកាសនេះ
- **លិខិតអនុញ្ញាតប្រកបអាជីវកម្ម** សំដៅដល់លិខិតដែលចេញដោយមន្ទីរ ដើម្បីអនុញ្ញាតឱ្យ ក្រុមហ៊ុន/សហគ្រាសណាមួយប្រកបអាជីវកម្មទទួលបញ្ចាំ និង/ឬអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទានខ្នាតតូចនៅក្នុងព្រះរាជាណា-ចក្រកម្ពុជាដោយស្របតាមលក្ខខណ្ឌដូចមានចែងក្នុងប្រកាសនេះ
- **អាជីវកម្មទទួលបញ្ចាំ** សំដៅដល់សកម្មភាពពាណិជ្ជកម្មដែលអតិថិជនយកទ្រព្យទៅដាក់បញ្ចាំ ដើម្បីទទួលបានប្រាក់កម្ចីដោយសន្យាទូទាត់សងប្រាក់ដើម និងការប្រាក់ទៅតាមកិច្ចសន្យាដែលបានកំណត់
- **អាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន** សំដៅដល់សកម្មភាពពាណិជ្ជកម្មដែលអតិថិជនធ្វើអនុប្បទានសិទ្ធិលើចលនវត្ថុ របស់ខ្លួនជូនដល់អ្នកទទួលប្រាតិភោគដោយអនុប្បទាន ដើម្បីទទួលបានប្រាក់កម្ចីដោយសន្យាទូទាត់សងប្រាក់ដើម និងការប្រាក់ទៅតាមកិច្ចសន្យាដែលបានកំណត់
- **អ្នកទទួលបញ្ចាំ** សំដៅដល់នីតិបុគ្គលដែលទទួលបានអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មទទួលទ្រព្យបញ្ចាំពីក្រសួង/មន្ទីរ

- **អ្នកទទួលប្រាតិភោគដោយអនុប្បទាន** សំដៅដល់នីតិបុគ្គលដែលទទួលបានអាជ្ញាបណ្ណ/ លិខិតអនុញ្ញាតប្រកបអាជីវកម្មទទួលទ្រព្យប្រាតិភោគដោយអនុប្បទានពីក្រសួង/មន្ទីរ
- **អ្នកដាក់បញ្ចាំ** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលយកទ្រព្យទៅដាក់បញ្ចាំជាមួយអ្នកទទួលបញ្ចាំ ដើម្បីទទួលបានប្រាក់កម្ចី
- **អ្នកដាក់ប្រាតិភោគដោយអនុប្បទាន** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលយកទ្រព្យទៅដាក់ប្រាតិភោគដោយ-អនុប្បទានជាមួយអ្នកទទួលប្រាតិភោគដោយអនុប្បទាន ដើម្បីទទួលបានប្រាក់កម្ចី
- **ទ្រព្យ** សំដៅដល់ចលនវត្ថុ ឬអចលនវត្ថុដែលជាកម្មវត្ថុយកទៅដាក់បញ្ចាំ
- **លោះ** សំដៅដល់ការទទួលយកមកវិញនូវទ្រព្យដែលបានដាក់បញ្ចាំ ឬដែលបានដាក់ប្រាតិភោគដោយអនុប្បទានក្រោយពីបានសងប្រាក់ដើម (ប្រាក់កម្ចី) និងការប្រាក់គ្រប់ចំនួនទៅតាមកិច្ចសន្យាដែលបានកំណត់ជូនទៅអ្នកទទួលបញ្ចាំ ឬអ្នកទទួលប្រាតិភោគដោយអនុប្បទានវិញ
- **កិច្ចសន្យា** សំដៅដល់កិច្ចសន្យាទទួលបញ្ចាំ ឬទទួលប្រាតិភោគដោយអនុប្បទានដែលធ្វើឡើងរវាងអ្នកដាក់បញ្ចាំ ឬអ្នកដាក់ប្រាតិភោគដោយអនុប្បទាន និងអ្នកទទួលបញ្ចាំ ឬអ្នកទទួលប្រាតិភោគដោយអនុប្បទាន។

## ជំពូកទី២
## ស្ថាប័នគ្រប់គ្រង

**ប្រការ៥.-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាបញ្ញត្តិករក្នុងការគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយ-អនុប្បទាន។ ក្រសួងមាននាយកដ្ឋានគ្រប់គ្រងអាជីវកម្មអចលនវត្ថុ បញ្ចាំ និងប្រាតិភោគដោយអនុប្បទាននៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុជាសេនាធិការ។

មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត បំពេញតួនាទី និងភារកិច្ចសម្របសម្រួល និងគាំទ្រការងារគ្រប់គ្រង និងត្រួតពិនិត្យអាជីវកម្មទទួលបញ្ចាំ និង/ឬទទួលប្រាតិភោគដោយអនុប្បទានខ្នាតតូចនៅតាមរាជធានី-ខេត្ត ក្នុងនាមជាសេនាធិការរបស់អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ជំពូកទី៣
## អាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្មទទួលបញ្ចាំ និង/ឬ ទទួលប្រាតិភោគដោយអនុប្បទាន

**ប្រការ៦.-**

រាល់ការប្រកបអាជីវកម្មទទួលបញ្ចាំ និង/ឬអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទានខ្នាតមធ្យម និងខ្នាតធំត្រូវមានអាជ្ញាបណ្ណពីក្រសួង។ ដើម្បីទទួលបានអាជ្ញាបណ្ណក្រុមហ៊ុន/ សហគ្រាសត្រូវដាក់ពាក្យស្នើសុំទៅនាយកដ្ឋានដោយបំពេញលក្ខខណ្ឌដូចខាងក្រោម÷

- ជានីតិបុគ្គលសញ្ជាតិខ្មែរ និងបានចុះបញ្ជីពាណិជ្ជកម្មស្របតាមច្បាប់នៅព្រះរាជាណាចក្រកម្ពុជា (ចំពោះអាជីវកម្មខ្នាតធំកម្រិត២ត្រូវចុះបញ្ជីជាក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត)
- ត្រូវមានដើមទុនប្រកបអាជីវកម្មដូចមានចែងក្នុងប្រការ៩ នៃប្រកាសនេះ
- ត្រូវតម្កល់ប្រាក់ធានាអាជីវកម្ម១០%នៃដើមទុន
- អ្នកកាន់អាជ្ញាបណ្ណត្រូវមានកម្រិតវប្បធម៌ថ្នាក់បរិញ្ញាបត្រ ឬវិញ្ញាបនបត្រផ្សេងៗទៀតដែលទាក់ទងនឹងអាជីវកម្ម ឬមានបទពិសោធន៍ពាក់ព័ន្ធទៅនឹងធុរៈកិច្ចស្រដៀងគ្នា ឬធ្លាប់បម្រើការងារផ្នែកនេះ។ ក្នុងករណីអ្នកឈរឈ្មោះមិនមែនជាភាគហ៊ុននិកត្រូវមានលិខិតបញ្ជាក់ពីក្រសួងពាណិជ្ជកម្ម។

- ត្រូវមានទីតាំងប្រកបអាជីវកម្មច្បាស់លាស់ដែលបញ្ជាក់ដោយអាជ្ញាធរមានសមត្ថកិច្ច។

លក្ខខណ្ឌលម្អិតសម្រាប់ការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណត្រូវបានកំណត់ក្នុងពាក្យស្នើសុំអាជ្ញាបណ្ណរបស់ក្រសួង។

**ប្រការ៧.-**

រាល់ការប្រកបអាជីវកម្មទទួលបញ្ចាំ និង/ឬអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទានខ្នាតតូចត្រូវមានលិខិតអនុញ្ញាតប្រកបអាជីវកម្មពីមន្ទីរ។ ដើម្បីទទួលបានលិខិតអនុញ្ញាតប្រកបអាជីវកម្មក្រុមហ៊ុន/សហគ្រាសត្រូវដាក់ពាក្យស្នើសុំនៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត ដោយបំពេញលក្ខខណ្ឌដូចខាងក្រោម÷

- ជានីតិបុគ្គលសញ្ជាតិខ្មែរ និងបានចុះបញ្ជីពាណិជ្ជកម្មស្របតាមច្បាប់នៅព្រះរាជាណាចក្រកម្ពុជា
- ត្រូវមានដើមទុនប្រកបអាជីវកម្មដូចមានចែងក្នុងប្រការ៩ នៃប្រកាសនេះ
- ត្រូវតម្កល់ប្រាក់ធានាអាជីវកម្ម១០% នៃដើមទុន
- អ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្មត្រូវមានកម្រិតវប្បធម៌ថ្នាក់បរិញ្ញាបត្រ ឬវិញ្ញាបនបត្រផ្សេងៗ ឬសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬមានបទពិសោធន៍ពាក់ព័ន្ធទៅនឹងធុរៈកិច្ចស្រដៀងគ្នា ឬធ្លាប់បម្រើការងារផ្នែកនេះ។ ក្នុងករណីអ្នកឈរឈ្មោះមិនមែនជាភាគហ៊ុនិកត្រូវមានលិខិតបញ្ជាក់ពីក្រសួងពាណិជ្ជកម្ម
- ត្រូវមានទីតាំងប្រកបអាជីវកម្មច្បាស់លាស់ដែលបញ្ជាក់ដោយអាជ្ញាធរមានសមត្ថកិច្ច។

លក្ខខណ្ឌលម្អិតសម្រាប់ការដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្ម ត្រូវបានកំណត់ក្នុងពាក្យស្នើសុំស្នើសុំរបស់មន្ទីរ។

**ប្រការ៨.-**

ក្រសួង/មន្ទីរមានរយៈពេលយ៉ាងយូរ៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការក្នុងការពិនិត្យ និងសម្រេចផ្តល់ ឬបដិសេធ ឬបន្តសុពលភាពជូនក្រុមហ៊ុន/សហគ្រាសគិតចាប់ពីថ្ងៃទទួលបានសំណុំឯកសារពេញលេញ និងគ្រប់ចំនួន។

**ប្រការ៩.-**

ដើមទុនសម្រាប់ប្រកបអាជីវកម្មទទួលបញ្ចាំ និង/ឬអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទានត្រូវបានកំណត់ដូចខាងក្រោម÷

**ក- អាជីវកម្មទទួលបញ្ចាំរួមមាន÷**

| | |
|---|---|
| - ខ្នាតតូច | :ត្រូវមានដើមទុនចាប់ពី ២០ លានរៀល ដល់ ៤០ លានរៀល |
| - ខ្នាតមធ្យម | :ត្រូវមានដើមលើសពី ៤០ លានរៀល ដល់ ២០០ លានរៀល |
| - ខ្នាតធំ (កម្រិត១) | :ត្រូវមានដើមទុនលើសពី ២០០ លានរៀល ដល់ ៨០០ លានរៀល |
| - ខ្នាតធំ (កម្រិត២) | :ត្រូវមានដើមទុនលើសពី ៨០០ លានរៀល ឡើងទៅ |

**ខ- អាជីវកម្មទទួលប្រាតិភោគដោយអនុប្បទានរួមមាន÷**

| | |
|---|---|
| - ខ្នាតតូច | :ត្រូវមានដើមទុនចាប់ពី ២០ លានរៀល ដល់ ៤០ លានរៀល |
| - ខ្នាតមធ្យម | :ត្រូវមានដើមទុនលើសពី ៤០ លានរៀល ដល់ ២០០ លានរៀល |
| - ខ្នាតធំ (កម្រិត១) | :ត្រូវមានដើមទុនលើសពី ២០០ លានរៀល ដល់ ៨០០ លានរៀល |
| - ខ្នាតធំ (កម្រិត២) | :ត្រូវមានដើមទុនលើសពី ៨០០ លានរៀល ឡើងទៅ |

រាល់ការបន្ថែម ឬបន្ថយដើមទុនអាជីវកម្មខាងលើត្រូវមានការអនុញ្ញាតពីក្រសួង/មន្ទីរជាមុន។

**ប្រការ១០.-**

ប្រភេទ ខ្នាត ថ្លៃ និងសុពលភាពអាជ្ញាបណ្ណប្រកបអាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទានដែលចេញដោយក្រសួងត្រូវបានកំណត់ដូចខាងក្រោម÷

អ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្មត្រូវដាក់ពាក្យស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាតឱ្យបាន ៣០ ថ្ងៃមុនលិខិតអនុញ្ញាតនោះផុតសុពលភាព និងត្រូវបង់ថ្លៃបន្តសុពលភាពដូចមានចែងក្នុងប្រការនេះ។

**ប្រការ១២.-**

ក្រុមហ៊ុន/ សហគ្រាស អាចបង្កើតសាខាបានលុះត្រាតែមានអាជ្ញាបណ្ណពីក្រសួង/ លិខិតអនុញ្ញាតប្រកបអាជីវកម្មពីមន្ទីរ។

ដើម្បីបើកសាខាបានក្រុមហ៊ុន/ សហគ្រាសត្រូវបំពេញលក្ខខណ្ឌដូចមានចែងក្នុងប្រការ៦ និងប្រការ ៧នៃប្រកាសនេះ។

## ជំពូកទី៤
## កិច្ចដំណើរការអាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទាន
### ផ្នែកទី១
### កាតព្វកិច្ចរបស់អ្នកកាន់អាជ្ញាបណ្ណ និងអ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្ម

**ប្រការ១៣.-**

**អ្នកកាន់អាជ្ញាបណ្ណ និងអ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្មមានកាតព្វកិច្ចដូចខាងក្រោម÷**

- ត្រូវទទួលខុសត្រូវចំពោះអតិថិជនដែលពាក់ព័ន្ធនឹងអាជីវកម្មរបស់ខ្លួន
- ត្រូវមានស្លាកយីហោអាជីវកម្មនៅពីមុខកន្លែងធ្វើអាជីវកម្ម ហើយអាជ្ញាបណ្ណ/ លិខិតអនុញ្ញាតប្រកបអាជីវកម្មត្រូវដាក់បង្ហាញនៅកន្លែងដែលងាយមើលឃើញ
- ត្រូវធ្វើអាជីវកម្មឱ្យបានត្រឹមត្រូវស្របតាមឈ្មោះ អាសយដ្ឋានដែលបានបញ្ជាក់នៅក្នុងអាជ្ញាបណ្ណ/ លិខិតអនុញ្ញាតប្រកបអាជីវកម្ម
- ត្រូវមានកិច្ចសន្យា និងសៀវភៅកត់ត្រាប្រតិបត្តិការអាជីវកម្មទទួលបញ្ចាំ ឬទទួលប្រាតិភោគដោយអនុប្បទាន និងត្រូវថែរក្សាទុកដាក់ឱ្យបានល្អ។ ទម្រង់កិច្ចសន្យា និងសៀវភៅកត់ត្រាប្រតិបត្តការអាជីវកម្មនឹងមានផ្តល់ជូនដោយក្រសួង
- រាល់កិច្ចសន្យាដាក់បញ្ចាំ ឬដាក់ប្រាតិភោគដោយអនុប្បទានត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរជាមួយអតិថិជនព្រមទាំងមានការបញ្ជាក់ឱ្យបានច្បាស់លាស់នូវព័ត៌មានអប្បរមា លក្ខខណ្ឌ រយៈពេលកិច្ចសន្យាដូចមានចែងក្នុងកថាខណ្ឌទី២ នៃប្រការ១៦ និងកាតព្វកិច្ចដែលគូភាគីបានព្រមព្រៀងគ្នាដោយមានការចុះហត្ថលេខា ឬស្នាមមេដៃទទួលស្គាល់ត្រឹមត្រូវដោយគូភាគីនៃកិច្ចសន្យា
- ត្រូវរក្សាទុកទ្រព្យបញ្ចាំ និង/ ឬប្រាតិភោគដោយអនុប្បទាននៅកន្លែងដែលមានសុវត្ថិភាព និងមិនត្រូវយកទ្រព្យនោះទៅប្រើប្រាស់ឡើយ
- ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះការខូចខាត ឬបាត់បង់លើទ្រព្យបញ្ចាំ ឬទ្រព្យប្រាតិភោគដោយអនុប្បទានកើតឡើងក្នុងអំឡុងពេលជាប់កិច្ចសន្យា
- ត្រូវផ្តល់ព័ត៌មានជាបន្ទាន់ឱ្យនគរបាល ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធដែលមានទីតាំងនៅជិតកន្លែងអាជីវកម្មក្នុងករណីមានការសង្ស័យចំពោះអតិថិជន ឬទ្រព្យណាមួយដែលពាក់ព័ន្ធនឹងបទល្មើស
- ត្រូវផ្តល់ព័ត៌មាន ឬរបាយការណ៍អំពីអត្តសញ្ញាណនៃអតិថិជន និងទ្រព្យ (សៀវភៅចុះបញ្ជីទ្រព្យ) ជូនប៉ុស្តិ៍នគរបាលរដ្ឋបាល ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធដែលមានទីតាំងនៅជិតកន្លែងអាជីវកម្មក្នុងរយៈពេល០៧ (ប្រាំពីរ )ថ្ងៃយ៉ាងយូរបន្ទាប់ពីកាលបរិច្ឆេទទទួលទ្រព្យបញ្ចាំ និង/ ឬទ្រព្យប្រាតិភោគដោយអនុប្បទាន
- ត្រូវធានាថារាល់ការផ្សាយពាណិជ្ជកម្មរបស់ក្រុមហ៊ុន/ សហគ្រាសត្រូវតែជាការពិត និងមានការបញ្ជាក់ពីអត្តលេខក្រុមហ៊ុន/ សហគ្រាស

- ត្រូវបិទផ្សាយថ្ងៃ និងពេលវេលាម៉ោងធ្វើការរបស់ខ្លួននៅមុខច្រកទ្វារចេញ-ចូលនៃកន្លែងអាជីវកម្មឱ្យបានត្រឹមត្រូវ និងមិនត្រូវមានប្រតិបត្តិការទទួលបញ្ចាំ ឬទទួលប្រាតិភោគដោយអនុប្បទាន និងប្រមូលការប្រាក់ឡើយក្រៅពីថ្ងៃ ឬម៉ោងដែលបានប្រកាសបិទមិនធ្វើការ
- ត្រូវផ្តល់របាយការណ៍ឱ្យបានទៀងទាត់ដូចមានចែងក្នុងប្រការ២៩នៃប្រកាសនេះ ដោយត្រូវបញ្ជាក់ថាពិតជាត្រឹមត្រូវដោយនាយកក្រុមហ៊ុន/សហគ្រាស
- ត្រូវបំពេញកាតព្វកិច្ចពន្ធដារឱ្យបានត្រឹមត្រូវដូចមានចែងក្នុងច្បាប់ស្តីពីសារពើពន្ធ
- ត្រូវរាយការណ៍ជាបន្ទាន់ទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជានៃធនាគារជាតិនៃកម្ពុជា ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ឬមកក្រសួង/មន្ទីរក្នុងករណីសង្កេតឃើញសកម្មភាពណាមួយដែលបម្រើដល់ការលាងសម្អាតប្រាក់ ឬបម្រើផលប្រយោជន៍ដល់ភេរវករ ឬបទល្មើសភេរវកម្មណាមួយ
- ត្រូវអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀតដែលនៅជាធរមាន។

**ប្រការ១៤.-**

ក្រុមហ៊ុន/សហគ្រាសត្រូវបានហាមឃាត់សកម្មភាពអាជីវកម្មមួយចំនួនដូចខាងក្រោម៖

- មិនត្រូវផ្សព្វផ្សាយពាណិជ្ជកម្មដែលមានលក្ខណៈមិនពិត ឬឆបោក ឬនាំឱ្យមានការយល់ខុស ឬធ្វើឱ្យប៉ះពាល់ដល់ប្រយោជន៍សាធារណៈ
- មិនត្រូវទទួលយកទ្រព្យអ្វីមួយពីអនីតិជន ឬពីជនណាមួយដែលកំពុងថិតក្នុងភាពស្រវឹងជោគជាំ ជនវិប្បល្លាសស្មារតី ឬពីជនណាមួយដែលសង្ស័យថាជាចោរ ឬអ្នកទទួលផលចោរកម្ម
- មិនត្រូវបង្កវិវាទឬជិវាទក្នុងការធ្វើអាជីវកម្មជាមួយអ្នកទទួលបញ្ចាំ ឬប្រាតិភោគដោយអនុប្បទានដទៃទៀត
- មិនត្រូវចូលរួម ឬធ្វើអាជីវកម្ម ដើម្បីបម្រើដល់សកម្មភាពលាងសម្អាតប្រាក់ឬបម្រើផលប្រយោជន៍ដល់ភេរវករ ឬឧក្រិដ្ឋជនណាមួយឡើយ
- មិនត្រូវទទួលយកទ្រព្យបញ្ចាំ ឬទ្រព្យប្រាតិភោគដោយអនុប្បទានណាដែលពុំមានឯកសារ ឬលិខិតបញ្ជាក់អត្តសញ្ញាណទ្រព្យច្បាស់លាស់
- មិនត្រូវធ្វើអាជីវកម្មខុសពីកម្មវត្ថុនៃអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្មទទួលបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន
- មិនត្រូវទទួលយកទ្រព្យណាមួយដែលច្បាប់ហាមឃាត់។

## ផ្នែកទី ២

## ការផ្តល់ប្រាក់កម្ចី

**ប្រការ១៥.-**

ចំពោះក្រុមហ៊ុន/សហគ្រាស ដែលទទួលបានអាជ្ញាបណ្ណពីក្រសួង ការផ្តល់ប្រាក់កម្ចីដល់អ្នកដាក់បញ្ចាំ ឬដល់អ្នកដាក់ប្រាតិភោគដោយអនុប្បទាន ០១ ប្រតិបត្តិការមិនត្រូវលើសពី ២០ % (ម្ភៃភាគរយ) នៃដើមទុនអាជីវកម្មដែលបានប្រកាសឡើយ។ ការផ្តល់ប្រាក់កម្ចីសម្រាប់ឯកសារបញ្ជាក់សិទ្ធិកាន់កាប់អចលនវត្ថុមិនត្រូវលើសពី ២០.០០០.០០០ (ម្ភៃលាន) រៀលឡើយក្នុងមួយប្រតិបត្តិការនៃទ្រព្យបញ្ចាំ។

ចំពោះក្រុមហ៊ុន/សហគ្រាស ដែលទទួលបានលិខិតអនុញ្ញាតប្រកបអាជីវកម្មពីមន្ទីរ ការផ្តល់ប្រាក់កម្ចីដល់អ្នកដាក់បញ្ចាំ ឬអ្នកដាក់ប្រាតិភោគដោយអនុប្បទាន ០១ ប្រតិបត្តិការមិនត្រូវលើសពី ២០ % (ម្ភៃភាគរយ) នៃដើមទុនអាជីវកម្មដែលបានប្រកាសឡើយ។ ការផ្តល់ប្រាក់កម្ចីសម្រាប់ឯកសារបញ្ជាក់សិទ្ធិកាន់កាប់អចលនវត្ថុមិនត្រូវលើសពី ៤.០០០.០០០ (បួនលាន) រៀលក្នុងមួយប្រតិបត្តិការនៃទ្រព្យបញ្ចាំនោះ។

## ផ្នែកទី ៣
## អត្រាការប្រាក់ និងរយៈពេលនៃការដាក់បញ្ញើ និង/ឬប្រាតិភោគដោយអនុប្បទាន

**ប្រការ១៦.-**

អត្រាការប្រាក់ត្រូវកំណត់តាមការព្រមព្រៀងរវាងអ្នកទទួលបញ្ញើ ឬអ្នកទទួលប្រាតិភោគដោយអនុប្បទាន និងអ្នកដាក់បញ្ញើ ឬអ្នកដាក់ប្រាតិភោគដោយអនុប្បទាន និងត្រូវអនុលោមតាមបទប្បញ្ញត្តិ និងច្បាប់ដែលនៅជាធរមាន។

កិច្ចសន្យានេះមានសុពលភាពអនុវត្តយ៉ាងយូរត្រឹម០៤ (បួន) ខែ ចាប់ពីកាលបរិច្ឆេទនៃការដាក់ទ្រព្យបញ្ញើ ឬដាក់ទ្រព្យប្រាតិភោគដោយអនុប្បទាន និងអាចបន្តសុពលភាពសារជាថ្មីបាន។

## ផ្នែកទី ៤
## ការចាត់ចែងទ្រព្យ

**ប្រការ១៧.-**

ក្នុងករណីអ្នកដាក់បញ្ញើ ឬអ្នកដាក់ប្រាតិភោគដោយអនុប្បទានបានសងប្រាក់កម្ចី និងការប្រាក់គ្រប់ចំនួនដូចមានចែងក្នុងកិច្ចសន្យាក្រុមហ៊ុន/សហគ្រាសត្រូវប្រគល់ទ្រព្យបញ្ញើ ឬទ្រព្យប្រាតិភោគដោយអនុប្បទានទៅឱ្យអ្នកដាក់បញ្ញើ ឬអ្នកដាក់ប្រាតិភោគដោយអនុប្បទានវិញភ្លាម។

**ប្រការ១៨.-**

ក្រុមហ៊ុន/សហគ្រាស ពុំមានសិទ្ធិលក់ ផ្ទេរ ប្រើប្រាស់ ឬប្រគល់សិទ្ធិកាន់កាប់ទ្រព្យបញ្ញើ ឬទ្រព្យប្រាតិភោគ-ដោយអនុប្បទាន ឱ្យទៅបុគ្គលផ្សេងទៀតក្នុងអំឡុងពេលដែលទ្រព្យបញ្ញើ ឬទ្រព្យប្រាតិភោគដោយអនុប្បទាននោះកំពុងជាប់កិច្ចសន្យា ដោយពុំមានការឯកភាពពីអ្នកដាក់បញ្ញើ ឬអ្នកដាក់ប្រាតិភោគដោយអនុប្បទានឡើយ។

**ប្រការ១៩.-**

ក្នុងករណីអ្នកដាក់បញ្ញើ ឬអ្នកដាក់ប្រាតិភោគដោយអនុប្បទានពុំមានលទ្ធភាពសងប្រាក់កម្ចីនិងការប្រាក់តាមការកំណត់នៅពេលកិច្ចសន្យាដល់កាលវសានការចាត់ចែងលើទ្រព្យបញ្ញើ ឬទ្រព្យប្រាតិភោគដោយអនុប្បទានមានដូចខាងក្រោម÷

- **សម្រាប់អាជីវកម្មទទួលបញ្ញើ÷**ទ្រព្យបញ្ញើត្រូវចាត់ចែងអនុលោមតាមនីតិវិធីដែលមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។
- **សម្រាប់អាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន÷**ទ្រព្យប្រាតិភោគដោយអនុប្បទាននឹងត្រូវចាត់ចែងតាមលទ្ធភាពជាក់ស្តែង ឬនីតិវិធីដែលមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ផ្នែកទី៥
## ការផ្លាស់ប្តូរទីតាំង នាមករណ៍ ភាគទុនិក សមាជិកក្រុមប្រឹក្សាភិបាល អ្នកកាន់អាជ្ញាបណ្ណ ឬអ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្ម

**ប្រការ២០.-**

រាល់ការផ្លាស់ប្តូរទីតាំងអាជីវកម្ម នាមករណ៍ ភាគទុនិក សមាជិកក្រុមប្រឹក្សាភិបាល អ្នកកាន់អាជ្ញាបណ្ណ ឬអ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្ម ត្រូវមានការឯកភាពជាមុនពីក្រសួង/មន្ទីរ។

ក្រុមហ៊ុន/សហគ្រាសត្រូវដាក់សំណើជាលាយលក្ខណ៍អក្សរមកក្រសួង/មន្ទីរមុននឹងធ្វើការផ្លាស់ប្តូរ។

ក្រសួង ឬមន្ទីរ ត្រូវជូនដំណឹងអំពីការសម្រេចឯកភាព ឬជំទាស់ ក្នុងរយៈពេល ៣០ ថ្ងៃនៃថ្ងៃធ្វើការ ឬរយៈពេលសមស្របណាមួយ គិតចាប់ពីកាលបរិច្ឆេទនៃការទទួលសំណើ។

**ឧបសម្ព័ន្ធ២១.-**

ការផ្លាស់ប្តូរទីតាំងអាជីវកម្ម នាមករណ៍ ភាគទុនិក សមាជិកក្រុមប្រឹក្សាភិបាល អ្នកកាន់អាជ្ញាបណ្ណ ឬអ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្មរបស់ក្រុមហ៊ុន/សហគ្រាសត្រូវផ្តល់ឯកសារដូចខាងក្រោម÷

**ក. ការស្នើសុំផ្លាស់ប្តូរទីតាំងអាជីវកម្មរបស់ក្រុមហ៊ុន/សហគ្រាស÷**

- លិខិតជាលាយលក្ខណ៍អក្សរមកក្រសួង/មន្ទីរស្តីពីការស្នើសុំផ្លាស់ប្តូរដោយមានបញ្ជាក់ពីមូលហេតុឱ្យបានច្បាស់លាស់
- លិខិតឯកភាពពីអាជ្ញាធរដែនដីចំពោះទីតាំងអាជីវកម្មថ្មី
- លិខិតបញ្ជាក់ស្តីពីការបំពេញកាតព្វកិច្ចពន្ធដារត្រឹមត្រូវតាមច្បាប់ស្តីពីសារពើពន្ធ
- ឯកសារបញ្ជាក់សិទ្ធិកាន់កាប់អចលនវត្ថុទីតាំងថ្មី ឬកិច្ចសន្យាជួលទីតាំងថ្មី
- ឯកសារបញ្ជាក់ពីការចុះផ្សាយលើទិព័រសារព័ត៌មានក្នុងស្រុកណាមួយដោយទុករយៈពេលយ៉ាងតិច០១ ខែគិតចាប់ពីកាលបរិច្ឆេទនៃការចុះផ្សាយ ដើម្បីឱ្យអតិថិជនបានជ្រាបអំពីការផ្លាស់ប្តូរទីតាំងអាជីវកម្ម និងជម្រះបញ្ជីប្រតិបត្តិការជាមួយអតិថិជនឱ្យបានរួចរាល់

**ខ. ការស្នើសុំផ្លាស់ប្តូរនាមករណ៍របស់ក្រុមហ៊ុន/សហគ្រាស÷**

- លិខិតជាលាយលក្ខណ៍អក្សរមកក្រសួង/មន្ទីរស្តីពីការស្នើសុំផ្លាស់ប្តូរនាមករណ៍ដោយមានបញ្ជាក់ពីមូលហេតុឱ្យបានច្បាស់លាស់
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលស្តីពីការផ្លាស់ប្តូរនាមករណ៍ ឬលិខិតសម្រេចរបស់នាយកក្រុមហ៊ុន/សហគ្រាស
- ឯកសារបញ្ជាក់ពីការចុះផ្សាយលើទិព័រសារព័ត៌មានក្នុងស្រុកណាមួយដោយទុករយៈពេលយ៉ាងតិច០១ ខែគិតចាប់ពីកាលបរិច្ឆេទនៃការចុះផ្សាយ ដើម្បីឱ្យអតិថិជនបានជ្រាបអំពីការផ្លាស់ប្តូរនាមករណ៍

**គ. ការស្នើសុំផ្លាស់ប្តូរភាគទុនិក ឬសមាជិកក្រុមប្រឹក្សាភិបាលប្រកបអាជីវកម្ម÷**

- លិខិតជាលាយលក្ខណ៍អក្សរមកក្រសួង/មន្ទីរ ស្តីពីការស្នើសុំផ្លាស់ប្តូរភាគទុនិក ឬសមាជិកក្រុមប្រឹក្សាភិបាលដោយមានបញ្ជាក់ពីមូលហេតុឱ្យបានច្បាស់លាស់
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលស្តីពីការផ្លាស់ប្តូរភាគទុនិក ឬសមាជិកក្រុមប្រឹក្សាភិបាល
- លិខិតទិញ-លក់ភាគហ៊ុនរបស់ភាគហ៊ុននិក
- លិខិតថ្កោលទោសឬលិខិតបញ្ជាក់កិរិយាមារយាទចេញដោយអាជ្ញាធរមានសមត្ថកិច្ច

**ឃ. ការស្នើសុំផ្លាស់ប្តូរអ្នកកាន់អាជ្ញាបណ្ណ/អ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្ម÷**

- លិខិតជាលាយលក្ខណ៍អក្សរមកក្រសួង/មន្ទីរ ស្តីពីការស្នើសុំផ្លាស់ប្តូរដោយមានបញ្ជាក់ពីមូលហេតុឱ្យបានច្បាស់លាស់
- អាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មច្បាប់ដើម
- សញ្ញាបត្រថ្នាក់បរិញ្ញាបត្រ ឬវិញ្ញាបនបត្រផ្សេងៗ ឬលិខិតបញ្ជាក់បទពិសោធន៍ពាក់ព័ន្ធធុរៈកិច្ចស្រដៀងគ្នា ឬធ្លាប់បម្រើការងារផ្នែកនេះចំពោះអ្នកកាន់អាជ្ញាបណ្ណ។
- សញ្ញាបត្រថ្នាក់បរិញ្ញាបត្រ ឬវិញ្ញាបនបត្រផ្សេងៗ ឬសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬលិខិតបញ្ជាក់បទពិសោធន៍ពាក់ព័ន្ធធុរៈកិច្ចស្រដៀងគ្នា ឬធ្លាប់បម្រើការងារផ្នែកនេះ ចំពោះអ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្ម
- លិខិតថ្កោលទោស ឬលិខិតបញ្ជាក់កិរិយាមាយាទចេញដោយអាជ្ញាធរមានសមត្ថកិច្ច។

## ផ្នែកទី ៦
## ប្រាក់តម្កល់ធានាអាជីវកម្ម

**ប្រការ២២.-**

ក្រុមហ៊ុន/សហគ្រាស ខ្នាតមធ្យម និងខ្នាតធំត្រូវដាក់ប្រាក់តម្កល់ធានាអាជីវកម្មចំនួន ១០ % (ដប់ភាគរយ) នៃដើមទុនប្រកបអាជីវកម្មទៅក្នុងគណនីទោលរតនាគារជាតិដែលបើកនៅធនាគារជាតិ នៃកម្ពុជាតាមដីកាអមរបស់នាយកដ្ឋាន។

ក្រុមហ៊ុន/សហគ្រាសខ្នាតតូច ត្រូវដាក់ប្រាក់តម្កល់ធានាអាជីវកម្មចំនួន ១០% (ដប់ភាគរយ) នៃដើមទុនប្រកបអាជីវកម្មទៅក្នុងគណនីទោលរបស់សាខារតនាគារជាតិ ដែលបើកនៅសាខាធនាគារជាតិនៃកម្ពុជាតាមដីកាអមរបស់មន្ទីរសាមីនោះ។

ប្រាក់តម្កល់ធានាអាជីវកម្មដូចមានចែងក្នុងកថាខណ្ឌទី១ និងទី២ ខាងលើអាចដកវិញបានក្រោយពីក្រុមហ៊ុន/សហគ្រាសបានបញ្ឈប់សកម្មភាពអាជីវកម្មជាស្ថាពរ ហើយត្រូវគោរពតាមលក្ខខណ្ឌដូចមានចែងក្នុងប្រការ២៥ ។

**ប្រការ២៣.-**

នៅក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការគិតចាប់ពីថ្ងៃបានទទួលលិខិតស្នើសុំដកប្រាក់តម្កល់ និងឯកសារតម្រូវផ្សេងៗ ក្រសួងត្រូវចេញលិខិតអនុញ្ញាតឱ្យដក ឬលិខិតបដិសេធដកប្រាក់តម្កល់នោះ ដោយបញ្ជាក់ហេតុផលត្រឹមត្រូវ។

## ជំពូកទី ៥
## ការផ្អាក និងការបញ្ឈប់សកម្មភាពអាជីវកម្ម

**ប្រការ២៤.-**

ក្នុងករណីផ្អាកសកម្មភាពអាជីវកម្ម ក្រុមហ៊ុន/សហគ្រាសត្រូវដាក់សំណើជាលាយលក្ខណ៍អក្សរមកក្រសួង/មន្ទីរ ដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធដូចខាងក្រោម÷

- លិខិតជាលាយលក្ខណ៍អក្សរមកក្រសួង/មន្ទីរស្តីពីការស្នើសុំផ្អាកដោយមានបញ្ជាក់ពីមូលហេតុឱ្យបានច្បាស់លាស់
- លិខិតបញ្ជាក់ស្តីពីការបំពេញកាតព្វកិច្ចពន្ធដារត្រឹមត្រូវតាមច្បាប់សារពើពន្ធ
- លិខិតជូនដំណឹងទៅអាជ្ញាធរពន្ធដារមានសមត្ថកិច្ចស្តីពីការផ្អាកសកម្មភាពអាជីវកម្ម
- ឯកសារពាក់ព័ន្ធការជម្រះបញ្ជីជាមួយអតិថិជនដែលដាក់បញ្ញើ ឬដាក់ប្រាតិភោគដោយអនុប្បទាន

ក្រសួង/មន្ទីរអនុញ្ញាតឱ្យ ក្រុមហ៊ុន/សហគ្រាសផ្អាកសកម្មភាពអាជីវកម្មរបស់ខ្លួនជាបណ្តោះអាសន្នយ៉ាងយូរត្រឹម៤ (បួន) ខែ ក្នុង១ (មួយ) ឆ្នាំ ឬត្រឹមសុពលភាពអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មដែលនៅសល់តែប៉ុណ្ណោះ។

**ប្រការ២៥.-**

ក្នុងករណីបញ្ឈប់សកម្មភាពអាជីវកម្ម ក្រុមហ៊ុន/សហគ្រាសត្រូវដាក់សំណើជាលាយលក្ខណ៍អក្សរមកក្រសួង/មន្ទីរ មុនបញ្ឈប់សកម្មភាពអាជីវកម្ម និងត្រូវភ្ជាប់មកជាមួយនូវសំណុំឯកសារដូចខាងក្រោម÷

- លិខិតស្នើសុំបញ្ឈប់អាជីវកម្មដោយបញ្ជាក់ពីមូលហេតុច្បាស់លាស់
- អាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មច្បាប់ដើម
- លិខិតបញ្ជាក់ពីការបំពេញកាតព្វកិច្ចពន្ធដារត្រឹមត្រូវដែលចេញដោយអាជ្ញាធរពន្ធដារមានសមត្ថកិច្ច
- ឯកសារពាក់ព័ន្ធការចុះផ្សាយលើទំព័រសារព័ត៌មានក្នុងស្រុកណាមួយដោយទុករយៈពេលយ៉ាងតិច០១ ខែគិតចាប់ពីកាលបរិច្ឆេទនៃការចុះផ្សាយ ដើម្បីឱ្យអតិថិជនបានជ្រាបអំពីការបញ្ឈប់សកម្មភាពអាជីវកម្ម និងការជម្រះបញ្ជីប្រតិបត្តិការជាមួយអតិថិជន
- បង្កាន់ដៃបង់ប្រាក់តម្កល់ធានាអាជីវកម្ម។

**ប្រការ២៦.-**

នៅក្នុងរយៈពេលយ៉ាងយូរ៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការគិតចាប់ពីថ្ងៃបានទទួលលិខិតស្នើសុំផ្អាក ឬបញ្ឈប់សកម្មភាពអាជីវកម្ម ឯកសារតម្រូវផ្សេងៗក្រសួង/មន្ទីរ ត្រូវចេញលិខិតបញ្ជាក់យល់ព្រម ឬបដិសេធសំណើរបស់ក្រុមហ៊ុន/សហគ្រាសដោយបញ្ជាក់ហេតុផលត្រឹមត្រូវ។

## ជំពូកទី៦
## ការត្រួតពិនិត្យ និងរបាយការណ៍

**ប្រការ២៧.-**

ក្រសួង/មន្ទីរមានសិទ្ធិចាត់មន្ត្រីជំនាញចុះត្រួតពិនិត្យជាក់ស្តែងដល់ទីកន្លែងដើម្បីធានាដល់ការអនុវត្តប្រកាសនេះ។

**ប្រការ២៨.-**

មន្ទីរត្រូវផ្តល់ជូននាយកដ្ឋាននូវរបាយការណ៍ដូចខាងក្រោម÷

-របាយការណ៍ប្រចាំត្រីមាសស្តីពីសកម្មភាពអាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទានឱ្យបានមុនថ្ងៃទី១៥ នៃត្រីមាសបន្ទាប់

-របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ក្រុមហ៊ុន/សហគ្រាសទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទានឱ្យបានមុនបំណាច់ត្រីមាសទី១ នៃឆ្នាំសារពើពន្ធ។

ទម្រង់នៃរបាយការណ៍ខាងលើត្រូវបានកំណត់ទៅតាមគំរូដែលនាយកដ្ឋានបានផ្តល់ជូន។

**ប្រការ២៩.-**

ក្រុមហ៊ុន/ សហគ្រាសដែលទទួលបានអាជ្ញាបណ្ណ/ លិខិតអនុញ្ញាតប្រកបអាជីវកម្ម ត្រូវផ្តល់ជូនក្រសួង/ មន្ទីរនូវរបាយការណ៍ដូចខាងក្រោម÷

- របាយការណ៍ប្រតិបត្តិការអាជីវកម្មប្រចាំខែមិនឱ្យលើសពីថ្ងៃទី១៥ នៃខែបន្ទាប់
- របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមិនឱ្យលើសពីត្រីមាសទី១ នៃឆ្នាំបន្ទាប់

ទម្រង់នៃរបាយការណ៍ខាងលើត្រូវបានកំណត់តាមគំរូដែលកំណត់ដោយក្រសួង។

**ប្រការ៣០.-**

ក្រសួង/ មន្ទីរមានសិទ្ធិតែងតាំងសវនករឯករាជ្យ ដើម្បីធ្វើសវនកម្មក្រុមហ៊ុន/ សហគ្រាសទាំងអស់ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួន ក្នុងករណីរកឃើញភាពមិនប្រក្រតីលើឯកសារពាក់ព័ន្ធនឹងប្រតិបត្តិការអាជីវកម្មដែលផ្តល់ដោយក្រុមហ៊ុន/ សហគ្រាស ដោយរាល់ការចំណាយលើសវនករឯករាជ្យជាបន្ទុករបស់ក្រុមហ៊ុន/ សហគ្រាស។

## ជំពូកទី៧
## ការផ្សះផ្សា និងដោះស្រាយវិវាទ

**ប្រការ៣១.-**

វិវាទរវាងក្រុមហ៊ុន/ សហគ្រាសទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទានជាមួយក្រុមហ៊ុន/ សហគ្រាសទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទាន និង/ ឬជាមួយអ្នកដាក់បញ្ចាំ/ អ្នកដាក់ប្រាតិភោគដោយអនុប្បទានពាក់ព័ន្ធនឹងសកម្មភាពអាជីវកម្មបញ្ចាំ ឬប្រាតិភោគដោយអនុប្បទានអាចជាកម្មវត្ថុនៃការសម្រុះសម្រួល និងផ្សះផ្សាដោយអគ្គនាយកដ្ឋាន/ មន្ទីរ។

ក្រសួង/ មន្ទីរសម្រុះសម្រួល និងផ្សះផ្សាវិវាទតាមការស្នើសុំរបស់ភាគីវិវាទក្នុងរយៈពេល០២ខែយ៉ាងយូរ។ ការផ្សះផ្សាវិវាទអាចឈានទៅដល់ការចុះកិច្ចព្រមព្រៀងផ្សះផ្សា ដែលត្រូវចុះហត្ថលេខាដោយគូភាគីវិវាទដោយមានប្រថាប់ត្រារបស់អគ្គនាយកដ្ឋាន/ មន្ទីរ។ កិច្ចព្រមព្រៀងផ្សះផ្សាមានអានុភាពអនុវត្តភ្លាមៗចំពោះគូភាគី។

**ប្រការ៣២.-**

ក្រុមហ៊ុន/សហគ្រាស ឬអ្នកដាក់បញ្ចាំ ឬដាក់ប្រាតិភោគដោយអនុប្បទានដែលមិនពេញចិត្តចំពោះសេចក្តីសម្រេច ឬវិធានការផ្សេងៗរបស់ក្រសួង/មន្ទីរមានសិទ្ធិដាក់ពាក្យបណ្តឹងតវ៉ាមកក្រុមប្រឹក្សានីតិកម្ម នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មុននឹងអនុវត្តនីតិវិធីបណ្តឹងទៅតុលាការលើកលែងតែរឿងព្រហ្មទណ្ឌ។

ក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវដោះស្រាយបណ្តឹងក្នុងរយៈពេល៩០ ថ្ងៃនៃថ្ងៃធ្វើការក្រោយពីទទួលបានពាក្យបណ្តឹងតវ៉ា ឬក្នុងរយៈពេលមួយសមស្រប។

ក្នុងការដោះស្រាយវិវាទក្រុមប្រឹក្សានីតិកម្ម នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអាចអញ្ជើញភាគីពាក់ព័ន្ធវិវាទដើម្បីសាកសួរ ឬផ្តល់ភស្តុតាងតាមការចាំបាច់។

សេចក្តីសម្រេច ស្តីពីការដោះស្រាយវិវាទត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរដោយមានបញ្ជាក់អំពីអង្គហេតុសំអាងហេតុ និងការសន្និដ្ឋាន។

ក្នុងករណីមិនពេញចិត្តនឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សានីតិកម្ម ភាគីវិវាទអាចដាក់ពាក្យបណ្តឹងតវ៉ាទៅតុលាការមានសមត្ថកិច្ចដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី៨

## ទោសប្បញ្ញត្តិ

**ប្រការ៣៣.-**

ត្រូវបានចាត់ទុកជាអំពើបំពាននឹងបទប្បញ្ញត្តិនៃប្រកាសនេះចំពោះអំពើដូចខាងក្រោម÷

- ប្រកបអាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទាន គ្មានអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្ម
- ក្លែងបន្លំអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្ម
- ប្រើប្រាស់អាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មផុតសុពលភាព
- ប្រកបអាជីវកម្មខុសពីទីតាំងដែលបានបញ្ជាក់នៅលើអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្ម
- ផ្តល់ប្រាក់កម្ចីខុសពីលក្ខខណ្ឌដូចមានចែងក្នុងប្រការ១៥ នៃប្រកាសនេះ
- យឺតយ៉ាវក្នុងការស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃមុនពេលអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មនោះផុតសុពលភាព
- បង្កើតសាខាដោយគ្មានការអនុញ្ញាតពីក្រសួង/មន្ទីរ
- ប្រកបអាជីវកម្មខុសពីកម្មវត្ថុនៃអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មដែលបានផ្តល់ជូន
- អនុវត្តផ្ទុយនឹងប្រការ១៣ ប្រការ១៤ ប្រការ១៥ ប្រការ២០ ប្រការ២៤ និងប្រការ២៥ នៃប្រកាសនេះ
- មិនបានផ្តល់ ឬផ្តល់របាយការណ៍យឺតយ៉ាវតាមការកំណត់ដូចមានចែងក្នុងប្រការ២៩ នៃប្រកាសនេះ
- ពុំអនុវត្តតាមការណែនាំជាលាយលក្ខណ៍អក្សររបស់ក្រសួង។

**ប្រការ៣៤.-**

ក្រុមហ៊ុន/សហគ្រាសទាំងឡាយណាដែលបានប្រព្រឹត្តកំហុសដូចមានចែងក្នុងប្រការ៣៣នៃប្រកាសនេះនឹងត្រូវទទួលរងទណ្ឌកម្មរដ្ឋបាលដូចខាងក្រោម÷

- ព្រមានជាលាយលក្ខណ៍អក្សរ
- ហាមឃាត់ការធ្វើប្រតិបត្តិការឬរឹតត្បិតសកម្មភាពមួយចំនួន
- ព្យួរអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មបណ្តោះអាសន្នពី០៦ ខែទៅ១ ឆ្នាំ
- ដកហូតអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្ម
- ផ្សព្វផ្សាយជាសាធារណៈនូវអំពើបំពាននឹងបទប្បញ្ញត្តិនៃប្រកាសនេះ

- ចាត់វិធានការផ្សេងៗទៀតទៅតាមច្បាប់ជាធរមាន។

**ប្រការ៣៥.-**

ក្រសួង/មន្ទីរមានសិទ្ធិព្យួរអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មនៅពេលដែលក្រុមហ៊ុន/សហគ្រាសបានប្រព្រឹត្តល្មើសក្នុងករណីណាមួយដូចខាងក្រោម÷

- ខកខានមិនបានផ្តល់របាយការណ៍ប្រចាំខែដោយចេតនា ឬអចេតនាក្រោយពីទទួលបានការព្រមានជាលាយលក្ខណ៍អក្សរ
- បង្កើតសាខាដោយគ្មានការអនុញ្ញាតពីក្រសួង/មន្ទីរជាមុន
- ប្រកបអាជីវកម្មខុសពីកម្មវត្ថុនៃអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មដែលបានផ្តល់ជូនដោយចេតនាក្រោយពីទទួលការព្រមានជាលាយលក្ខណ៍អក្សរ
- បន្តអនុវត្តផ្ទុយនឹងប្រការ១៣ ប្រការ១៤ ប្រការ១៥ ប្រការ២០ ប្រការ២៤ និងប្រការ២៥ នៃប្រកាសនេះក្រោយពីទទួលបានលិខិតព្រមានជាលាយលក្ខណ៍អក្សរ។

**ប្រការ៣៦.-**

ក្រសួង/មន្ទីរ មានសិទ្ធិដកហូតអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មនៅពេលដែលក្រុមហ៊ុន/សហគ្រាសបានប្រព្រឹត្តល្មើសក្នុងករណីណាមួយដូចខាងក្រោម÷

- ខកខានមិនបានផ្តល់របាយការណ៍ប្រចាំខែដោយចេតនា ឬអចេតនាចាប់ពី០៦ ខែឡើងទៅ
- ក្រោយពីទទួលការព្រមានជាលាយលក្ខណ៍អក្សរលើកទី២ ហើយនៅតែមិនរៀងចាលទៀត
- ខកខានមិនបានបំពេញកាតព្វកិច្ចពន្ធដារត្រឹមត្រូវតាមច្បាប់ស្តីពីសារពើពន្ធលើសពី០៦ ខែឡើងទៅ
- ប្រើប្រាស់អាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មផុតសុពលភាពលើសពី០៣ ខែឡើងទៅ
- ក្រោយពីទទួលការព្រមានជាលាយលក្ខណ៍អក្សរ ហើយនៅតែបន្តប្រកបអាជីវកម្មខុសពីទីតាំងដែលបានបញ្ជាក់នៅលើអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មទៀត
- ផ្តល់ប្រាក់កម្ចីខុសពីលក្ខខណ្ឌដូចមានចែងក្នុងប្រការ១៥ នៃប្រកាសនេះលើសពី០៥ ករណីឡើងទៅ
- យឺតយ៉ាវក្នុងការស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មលើសពី០៣ ខែ ក្រោយពេលអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មនោះផុតសុពលភាព
- បង្កើតសាខាលើសពី០២ (ពីរ) សាខាឡើងទៅដោយគ្មានការអនុញ្ញាតពីក្រសួង/មន្ទីរជាមុន
- ធ្វើអាជីវកម្មខុសពីកម្មវត្ថុនៃអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្ម ដែលបានផ្តល់ជូនដោយចេតនាក្រោយពីទទួលការព្រមានជាលាយលក្ខណ៍អក្សរលើកទី២ហើយ
- នៅបន្តអនុវត្តផ្ទុយនឹងប្រការ១៣ ប្រការ១៧ ប្រការ១៩ និងប្រការ២៥ នៃប្រកាសនេះក្រោយពីអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មត្រូវបានព្យួររួចហើយ
- បានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ឬប្រព្រឹត្តបទល្មើសហិរញ្ញវត្ថុ ឬអំពើមិនស្របច្បាប់ណាមួយដែលមានភស្តុតាងច្បាស់លាស់ពីអាជ្ញាធរមានសមត្ថកិច្ច។

ក្រសួង/មន្ទីរ នឹងជូនដំណឹងជាលាយលក្ខណ៍អក្សរចំនួន៣០ (សាមសិប) ថ្ងៃមុននឹងដកហូតអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មពីក្រុមហ៊ុន/សហគ្រាសដែលបានប្រព្រឹត្តខុស។

**ប្រការ៣៧.-**

ការប្រកបអាជីវកម្មទទួលបញ្ចាំ/ទទួលប្រាតិភោគដោយអនុប្បទានដោយគ្មានអាជ្ញាបណ្ណ ត្រូវទទួលពិន័យអន្តរការណ៍ពីក្រសួងចំនួន១០.០០០.០០០ (ដប់លាន)រៀល និងត្រូវបញ្ឈប់សកម្មភាពអាជីវកម្មជាបន្ទាន់។ ដើម្បីអាចប្រកបអាជីវកម្មបាន ក្រុមហ៊ុន/សហគ្រាសត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណមកក្រសួង។

ការប្រកបអាជីវកម្មទទួលបញ្ចាំ/ទទួលប្រាតិភោគដោយអនុប្បទាន ដោយគ្មានលិខិតអនុញ្ញាតប្រកបអាជីវកម្មត្រូវទទួលពិន័យអន្តរការណ៍ពីក្រសួងចំនួន ៥.០០០.០០០(ប្រាំលាន)រៀល និងត្រូវបញ្ឈប់សកម្មភាពអាជីវកម្មជាបន្ទាន់។ ដើម្បីអាចប្រកបអាជីវកម្មបានក្រុមហ៊ុន/សហគ្រាសត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្មមកមន្ទីរ។

**ប្រការ៣៨.-**

ការក្លែងបន្លំអាជ្ញាបណ្ណត្រូវទទួលពិន័យអន្តរការណ៍ចំនួន ១០.០០០.០០០ (ដប់លាន) រៀល និងបញ្ឈប់សកម្មភាពអាជីវកម្មជាបន្ទាន់។

ការក្លែងបន្លំលិខិតអនុញ្ញាតប្រកបអាជីវកម្មត្រូវទទួលពិន័យអន្តរការណ៍ចំនួន ៥.០០០.០០០ (ប្រាំលាន) រៀល និងបញ្ឈប់សកម្មភាពអាជីវកម្មជាបន្ទាន់។

**ប្រការ៣៩.-**

ការប្រើប្រាស់អាជ្ញាបណ្ណផុតសុពលភាពត្រូវទទួលពិន័យអន្តរការណ៍ចំនួន ៥.០០០.០០០ (ប្រាំលាន) រៀល និងត្រូវរួសរាន់ដាក់ពាក្យស្នើសុំបន្តសុពលភាពក្នុងករណីមិនរាងចាលក្រសួងនឹងចាត់វិធានការបញ្ឈប់សកម្មភាពអាជីវកម្មជាស្ថាពរ។

ការប្រើប្រាស់លិខិតអនុញ្ញាតប្រកបអាជីវកម្មផុតសុពលភាពត្រូវទទួលពិន័យអន្តរការណ៍ចំនួន ២.៥០០.០០០ (ពីរលានប្រាំរយពាន់) រៀល និងត្រូវរួសរាន់ដាក់ពាក្យស្នើសុំបន្តសុពលភាពក្នុងករណីមិនរាងចាលមន្ទីរនឹងចាត់វិធានការបញ្ឈប់សកម្មភាពអាជីវកម្មជាស្ថាពរ។

**ប្រការ៤០.-**

ការប្រកបអាជីវកម្មខុសពីទីតាំងដែលបានបញ្ជាក់នៅលើអាជ្ញាបណ្ណត្រូវទទួលពិន័យអន្តរការណ៍ចំនួន ២.០០០.០០០ (ពីរលាន)រៀល និងត្រូវបញ្ឈប់សកម្មភាពអាជីវកម្មជាបន្ទាន់។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង។

ការប្រកបអាជីវកម្មខុសពីទីតាំងដែលបានបញ្ជាក់នៅលើលិខិតអនុញ្ញាតប្រកបអាជីវកម្ម ត្រូវទទួលពិន័យអន្តរការណ៍ចំនួន ១.០០០.០០០(មួយលាន) រៀល និងត្រូវបញ្ឈប់សកម្មភាពអាជីវកម្មជាបន្ទាន់។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង។

**ប្រការ៤១.-**

ការផ្តល់ប្រាក់កម្ចីលើសពីដើមទុនដែលបានប្រកាសជាមួយក្រសួងត្រូវទទួលពិន័យអន្តរការណ៍ចំនួន ៣.០០០.០០០ (បីលាន) រៀល។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង និងឈានដល់ការព្យួរអាជ្ញាបណ្ណបណ្តោះអាសន្ន។

ការផ្តល់ប្រាក់កម្ចីលើសពីដើមទុនដែលបានប្រកាសជាមួយមន្ទីរត្រូវទទួលពិន័យអន្តរការណ៍ចំនួន១.៥០០.០០០ (មួយលានប្រាំរយពាន់) រៀល។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង និងឈានដល់ការព្យួរអាជ្ញាបណ្ណបណ្តោះអាសន្ន។

**ប្រការ៤២.-**

ការយឺតយ៉ាវក្នុងការដាក់ពាក្យស្នើសុំបង់ថ្លៃបន្តសុពលភាពអាជ្ញាបណ្ណប្រចាំឆ្នាំដូចមានចែងក្នុងប្រការ១០ ត្រូវទទួលពិន័យអន្តរការណ៍ចំនួន២០.០០០(ម្ភៃពាន់) រៀល ក្នុង ០១ ថ្ងៃសម្រាប់រយៈពេល៣០ថ្ងៃដំបូង។ ក្នុងករណីមិនរាងចាលចំនួនទឹកប្រាក់ផាកពិន័យត្រូវគុណទ្វេដង។

ការយឺតយ៉ាវក្នុងការដាក់ពាក្យស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាតប្រកបអាជីវកម្មក្នុងរយៈពេល៣០ថ្ងៃមុន លិខិតអនុញ្ញាតប្រកបអាជីវកម្មផុតសុពលភាពត្រូវទទួលពិន័យអន្តរការណ៍ចំនួន១០.០០០ (ដប់ពាន់)រៀល ក្នុង០១ថ្ងៃសម្រាប់រយៈពេល៣០ថ្ងៃដំបូង។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍ត្រូវគុណទ្វេដង។

**ប្រការ៤៣.-**

ការបង្កើតសាខាដោយគ្មានអាជ្ញាបណ្ណពីក្រសួងត្រូវទទួលពិន័យអន្តរការណ៍ចំនួន ៣.០០០.០០០ (បីលាន) រៀល ក្នុង០១សាខា និងត្រូវផ្អាកសកម្មភាពអាជីវកម្មសាខា។ ដើម្បីអាចបន្តសកម្មភាពអាជីវកម្មបាន ក្រុមហ៊ុន/សហគ្រាស ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណសាខានោះ។ ក្នុងករណីមិនរាងចាលក្រសួងនឹងព្យួរឬដកហូតអាជ្ញាបណ្ណក្រុមហ៊ុន/ សហគ្រាសមេ។

ការបង្កើតសាខាដោយគ្មានលិខិតអនុញ្ញាតប្រកបអាជីវកម្មពីមន្ទីរត្រូវទទួលពិន័យអន្តរការណ៍ចំនួន ១.៥០០.០០០ (មួយលានប្រាំរយពាន់) រៀលក្នុង០១ សាខា និងត្រូវផ្អាកសកម្មភាពអាជីវកម្មសាខា។ ដើម្បីអាចបន្តសកម្មភាពអាជីវកម្មបាន ក្រុមហ៊ុន/សហគ្រាស ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតសម្រាប់សាខានោះ។ ក្នុងករណីមិនរាងចាលមន្ទីរនឹងព្យួរ ឬដកហូតលិខិតអនុញ្ញាតប្រកបអាជីវកម្មក្រុមហ៊ុន/ សហគ្រាសមេ។

**ប្រការ៤៤.-**

ការធ្វើអាជីវកម្មខុសពីកម្មវត្ថុនៃអាជ្ញាបណ្ណត្រូវទទួលពិន័យអន្តរការណ៍ចំនួន២.០០០.០០០ (ពីរលាន) រៀលក្នុង០១ករណី និងផ្អាកអាជីវកម្មនោះជាបន្ទាន់។ ក្នុងករណីមិនរាងចាលក្រសួងនឹងព្យួរ ឬដកហូតអាជ្ញាបណ្ណនោះ។

ការធ្វើអាជីវកម្មខុសពីកម្មវត្ថុនៃលិខិតអនុញ្ញាតប្រកបអាជីវកម្មត្រូវទទួលពិន័យអន្តរការណ៍ចំនួន១.០០០.០០០ (មួយលាន) រៀលក្នុង០១ ករណី និងផ្អាកអាជីវកម្មនោះជាបន្ទាន់។ ក្នុងករណីមិនរាងចាលមន្ទីរនឹងព្យួរ ឬដកហូតលិខិតអនុញ្ញាតប្រកបអាជីវកម្មនោះ។

**ប្រការ៤៥.-**

ក្រោយពីទទួលលិខិតព្រមានជាលាយលក្ខណ៍អក្សរ អ្នកកាន់អាជ្ញាបណ្ណនៅតែប្រព្រឹត្តផ្ទុយនឹងចំណុចណាមួយនៃប្រការ១៣ និងប្រការ១៤ នៃប្រកាសនេះត្រូវទទួលពិន័យអន្តរការណ៍ពីក្រសួងចំនួន៤០០.០០០ (បួនរយពាន់) រៀលក្នុង០១ ករណី។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង និងឈានដល់ការដកហូត ឬបញ្ឈប់សកម្មអាជីកម្ម។

ក្រោយពីទទួលលិខិតព្រមានជាលាយលក្ខណ៍អក្សរ ហើយអ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្មនៅតែប្រព្រឹត្តផ្ទុយនឹងចំណុចណាមួយនៃប្រការ១៣ និងប្រការ១៤ នៃប្រកាសនេះត្រូវទទួលពិន័យអន្តរការណ៍ពីមន្ទីរចំនួន២០០.០០០ (ពីររយពាន់)រៀលក្នុង០១ ករណី។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង និងឈានដល់ការដកហូត ឬបញ្ឈប់សកម្មអាជីកម្ម។

**ប្រការ៤៦.-**

អ្នកកាន់អាជ្ញាបណ្ណទាំងឡាយណាដែលប្រព្រឹត្តផ្ទុយនឹងប្រការ១៥ នៃប្រកាសនេះត្រូវទទួលពិន័យអន្តរការណ៍ចំនួន ២.០០០.០០០(ពីរលាន) រៀលក្នុង០១ ករណី។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង។

អ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្មទាំងឡាយណាដែលប្រព្រឹត្តផ្ទុយនឹងប្រការ១៥ នៃប្រកាសនេះត្រូវទទួលពិន័យអន្តរការណ៍ចំនួន១.០០០.០០០ (មួយលាន) រៀលក្នុង០១ ករណី។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង។

**ប្រការ៤៧.-**

អ្នកកាន់អាជ្ញាបណ្ណទាំងឡាយណាដែលប្រព្រឹត្តផ្ទុយនឹងប្រការ២០ នៃប្រកាសនេះត្រូវទទួលពិន័យអន្តរការណ៍ចំនួន ១.០០០.០០០ (មួយលាន) រៀលក្នុង០១ ករណី និងត្រូវផ្អាកសកម្មភាពអាជីវកម្មជាបន្ទាន់ហើយត្រូវបំពេញឯកសារស្នើសុំ។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង។

អ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្មទាំងឡាយណាដែលប្រព្រឹត្តផ្ទុយនឹងប្រការ២០ នៃប្រកាសនេះត្រូវទទួលពិន័យអន្តរការណ៍ចំនួន៥០០.០០០ (ប្រាំរយពាន់) រៀលក្នុង០១ ករណី និងត្រូវផ្អាកសកម្មភាពអាជីវកម្មជាបន្ទាន់។ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង។

**ប្រការ៤៨.-**

អ្នកកាន់អាជ្ញាបណ្ណទាំងឡាយណាដែលផ្តល់របាយការណ៍យឺតយ៉ាវដូចមានចែងក្នុងប្រការ២៩ នៃប្រកាសនេះត្រូវទទួលពិន័យអន្តរការណ៍ចំនួន២០.០០០ (ម្ភៃពាន់) រៀលក្នុង០១ (មួយ) ថ្ងៃសម្រាប់រយៈពេល៣០ ថ្ងៃដំបូង។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង និងឈានដល់ការព្យួរ ឬដកហូតអាជ្ញាបណ្ណ។

អ្នកកាន់លិខិតអនុញ្ញាតប្រកបអាជីវកម្មទាំងឡាយណាដែលផ្តល់របាយការណ៍យឺតយ៉ាវ ដូចមានចែងក្នុងប្រការ២៩ នៃប្រកាសនេះត្រូវទទួលពិន័យអន្តរការណ៍ចំនួន១០.០០០ (ដប់ពាន់) រៀល ក្នុង០១ (មួយ) ថ្ងៃសម្រាប់រយៈពេល៣០ ថ្ងៃដំបូង។ ក្នុងករណីមិនរាងចាលពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេរដង និងឈានដល់ការព្យួរ ឬដកហូតលិខិតអនុញ្ញាតប្រកបអាជីវកម្ម។

## ជំពូកទី០៩
## អន្តរប្បញ្ញត្តិ

**ប្រការ៤៩.-**

អាជ្ញាបណ្ណទទួលបញ្ចាំ និង/ឬទទួលប្រាតិភោគដោយអនុប្បទានដែលក្រសួងផ្តល់ជូនមុនពេលដាក់ឱ្យអនុវត្តប្រកាសនេះនៅបន្តមានសុពលភាពរហូតដល់ផុតកាលកំណត់សុពលភាពរបស់អាជ្ញាបណ្ណនោះ។

## ជំពូកទី១០
## អវសានប្បញ្ញត្តិ

**ប្រការ៥០.-**

ប្រកាសលេខ០២៨សហវ.ប្រក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១០ ស្តីពីការផ្តល់អាជ្ញាបណ្ណអាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន និងបទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៥១.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្រុមហ៊ុន/សហគ្រាស និងបុគ្គលដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧ តទៅ។

ថ្ងៃទី១៣ ខែ មករា ឆ្នាំ២០១៧

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- ធនាគារជាតិនៃកម្ពុជា
- សាលារាជធានី-ខេត្ត
- ដូចប្រការ៥១
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធ ២

# ពាក្យសុំការអនុញ្ញាតប្រកបអាជីវកម្ម-សេវាកម្ម

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យសុំការអនុញ្ញាតប្រកបអាជីវកម្ម - សេវាកម្ម

ខ្ញុំបាទ នាងខ្ញុំឈ្មោះ..........................................................................................ឆ្នាំកំណើត...............
ជនជាតិ.........................សញ្ជាតិ............................ទីលំនៅបច្ចុប្បន្ននៅ ឡូត៍លេខ........................................
ផ្ទះលេខ...................................ផ្លូវលេខ........................................សង្កាត់......................................................
ខណ្ឌ..................................................រាជធានីភ្នំពេញ ។

**សូមគោរពជូន**
**លោកស្រីប្រធានមន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ**

**កម្មវត្ថុ:** សំណើសុំការអនុញ្ញាត................................................................................................................
តាមកម្មវត្ថុដូចបានជំរាបជូនខាងលើនេះ ដោយរូបខ្ញុំមានបំណងប្រកបអាជីវកម្ម សេវាកម្ម ដែលមានទីតាំងនៅ ឡូត៍លេខ................ ផ្ទះលេខ....................ផ្លូវ..................ក្រុមទី...........ភូមិ.......................................... សង្កាត់...........................................................ខណ្ឌ..........................................................................រាជធានីភ្នំពេញ មាននាមករណ៍.............................................................................................................................នឹងចាប់ដំណើរការ នៅថ្ងៃទី..................ខែ......................ឆ្នាំ២០១..................ទូរស័ព្ទទំនាក់ទំនង.........................................................

អាស្រ័យហេតុនេះ សូមលោកស្រីប្រធានមន្ទីរ មេត្តាជ្រាប និង ពិនិត្យអនុញ្ញាត ដោយអនុគ្រោះ។

ជូនភ្ជាប់មកជាមួយនូវ:

**<u>សម្រាប់ទីតាំងថ្មី</u>**

| | |
|---|---|
| -រូបថត(រូបថតបច្ចុប្បន្នទំហំ៤គុណ៦) | ០២សន្លឹក |
| -រូបថតបញ្ជាក់ទីតាំង(ទំហំ ១០ គុណ ១៥) | ០២សន្លឹក |
| -អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន(ច្បាប់ថតចម្លង) | ០២សន្លឹក |
| -កិច្ចសន្យា | ០២ច្បាប់ |
| -ប័ណ្ណកម្មសិទ្ធទីតាំង ឬ កិច្ចសន្យាជួលទីតាំង(ច្បាប់ថតចម្លង) | ០២ច្បាប់ |
| -វិក័យប័ត្រគំរូ | ០២សន្លឹក |

**<u>សម្រាប់ទីតាំងបន្ត</u>**

| | |
|---|---|
| -លិខិតអនុញ្ញាតប្រកបអាជីវកម្ម ច្បាប់ដើម | |
| -លិខិតអនុញ្ញាតបិទស្លាកថ្លៃជារូបិយប័ណ្ណបរទេស | |
| -រូបថត(រូបថតបច្ចុប្បន្នទំហំ៤គុណ៦) | ០១សន្លឹក |
| -អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន(ច្បាប់ថតចម្លង) | ០១សន្លឹក |
| -ប័ណ្ណប៉ាតង់ ច្បាប់ថតចម្លង (បើមាន) | ០១សន្លឹក |

ខ្ញុំបាទ នាងខ្ញុំ សូមសន្យាថា ពេលទទួលបានការអនុញ្ញាតរួចហើយ នឹងគោរពឲ្យបានម៉ឺងម៉ាត់តាមគោលការណ៍ច្បាប់របស់រដ្ឋ នឹងទទួលខុសត្រូវអនុវត្តឲ្យបានត្រឹមត្រូវ ទៅតាមកិច្ចសន្យារបស់ខ្ញុំបាទ នាងខ្ញុំ ចុះថ្ងៃទី....................ខែ.........................ឆ្នាំ ២០១ ។

សូមលោកស្រីប្រធាន ទទួលនូវសេចក្តីគោរពរាប់អានដ៏ស្មោះ អំពីខ្ញុំ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី...................ខែ.....................ឆ្នាំ២០១

**ហត្ថលេខាឬ ស្នាមមេដៃសាមីខ្លួន**

CS Scanned with CamScanner

# ជីវប្រវត្តិរបស់ខ្ញុំ

4X6

១-នាមត្រកូល និង នាមខ្លួន..................................................................................................

២-ភេទ................................ជនជាតិ...................................សញ្ជាតិ.............................................

៣-ថ្ងៃខែឆ្នាំកំណើត.....................................................................................................................

៤-ទីកន្លែងកំណើត.......................................................................................................................

..................................................................................................................................................

៥ -កំរិតវប្បធម៌............................................................................................................................

៦-មុខជំនាញបច្ចេកទេស..............................................................................................................

..................................................................................................................................................

៧-ទីលំនៅបច្ចុប្បន្នផ្ទះលេខ.................................ផ្លូវ..........................................ក្រុមទី........................

សង្កាត់.......................................ខណ្ឌ.............................................រាជធានីភ្នំពេញ

៨-ស្ថានភាពគ្រួសារ: ឈ្មោះប្ដី ឬ ប្រពន្ធ.........................................................ឆ្នាំកំណើត.......................

មុខរបរ.......................................................................................................................

កូនក្នុងបន្ទុកចំនួន...........................................................................នាក់

១-..................................................................................................ឆ្នាំកំណើត.............................

២-..................................................................................................ឆ្នាំកំណើត.............................

៣-..................................................................................................ឆ្នាំកំណើត.............................

៤..................................................................................................ឆ្នាំកំណើត.............................

៥-..................................................................................................ឆ្នាំកំណើត.............................

៦-..................................................................................................ឆ្នាំកំណើត.............................

៧-..................................................................................................ឆ្នាំកំណើត.............................

ភ្នំពេញ, ថ្ងៃទី..............................ខែ............................ឆ្នាំ២០១

**ហត្ថលេខា ឬ ស្នាមមេដៃ**

CS Scanned with CamScanner

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## កិច្ចសន្យា

ខ្ញុំបាទនាងខ្ញុំឈ្មោះ........................................................ឆ្នាំកំណើត............ជនជាតិ..............សញ្ជាតិ...............
ទីលំនៅបច្ចុប្បន្នផ្ទះលេខ................ ផ្លូវ........................សង្កាត់.........................ខណ្ឌ............................រាជធានីភ្នំពេញ
ប្រកបមុខរបរអាជីវកម្មសេវាកម្ម.............................................................................................នៅឡូត៍លេខ........
ផ្ទះលេខ..............ផ្លូវ..............ក្រុមទី..........ភូមិ.................សង្កាត់..................ខណ្ឌ........................រាជធានីភ្នំពេញ។

ក្រោយពីទទួលបានការអនុញ្ញាតឲ្យធ្វើអាជីវកម្ម សេវាកម្ម ខ្ញុំសូមសន្យាដូចតទៅ:

១. គោរព អនុវត្តតាមគោលការណ៍ច្បាប់ បទបញ្ជា ប្រកាស សេចក្តីសម្រេច សេចក្តីណែនាំ របស់ រាជរដ្ឋាភិបាល ស្ថាប័នមានសមត្ថកិច្ច និង របស់រដ្ឋបាលរាជធានីភ្នំពេញ

២. ធានាថាពុំមានជាប់ទោសពៃរ៍ក្នុងកិច្ចការពាណិជ្ជកម្ម រដ្ឋប្បវេណី ឬ ព្រហ្មទណ្ឌ និងពុំមែនជាមន្ត្រីរាជការ ក្នុងក្រសួង ស្ថាប័នរដ្ឋណាមួយ នៃព្រះរាជាណាចក្រកម្ពុជាឡើយ ហើយព័ត៌មានទាំងឡាយ នៅក្នុងពាក្យស្នើសុំ និងឯកសារភ្ជាប់ជូន គឺពិត និងពេញលេញ

៣. ធានាមិនធ្វើអ្វីមួយឲ្យប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈជាពិសេសគឺមិនដាក់លក់ទំនិញ ឬធ្វើសេវាដែលធ្វើឲ្យរាំងស្ទះដល់ចរាចរធ្វើដំណើរតាមដងផ្លូវ

៤. រួមចំណែក ថែរក្សាបរិស្ថាន សុខុមាលភាពសង្គម និង វប្បធម៌ ប្រពៃណីជាតិ

៥. មិនប្រកបមុខរបរអាជីវកម្ម សេវាកម្មដែលផ្ទុយពីច្បាប់រដ្ឋហាមឃាត់ដូចជា: ការជួញដូរគ្រឿងញៀន អាវុធគ្រឿងផ្ទុះ ការទិញ លក់ ទំនិញក្លែងក្លាយ ទំនិញខូចគុណភាព ទំនិញដែលជាផលបានមកពីប្រភពចោរកម្មឬអាជីវកម្មផ្លូវភេទ។ល។

៦. ត្រូវដាក់ស្លាកថ្លៃជារូបិយប័ណ្ណ(រៀល)ដើម្បីបង្ហាញជូនអតិថិជន លើមុខទំនិញអាជីវកម្ម និង សេវាកម្ម។ ក្នុងករណីមានបំណងចង់ដាក់ស្លាកថ្លៃជារូបិយប័ណ្ណបរទេសត្រូវមានការអនុញ្ញាតពីមន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញជាមុនសិន

៧. អនុវត្តកាតព្វកិច្ចបង់ពន្ធ តាមច្បាប់ជាធរមាន

៨. ផ្តល់របាយការណ៍អំពីស្ថានភាពអាជីវកម្ម សេវាកម្ម ជូនមន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ នៅរាល់ពេលណាដែលមានសំណូមពរចាំបាច់

៩.មិនទាមទារសិទ្ធិរក្សានាមករណ៍ ដែលបានស្នើសុំដាក់បញ្ចូលក្នុងលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម ។

ខ្ញុំបាទ នាងខ្ញុំសូមសន្យាថា ក្នុងករណីរូបខ្ញុំមិនអនុវត្តត្រឹមត្រូវតាមកិច្ចសន្យានេះ ខ្ញុំបាទនាងខ្ញុំសុខចិត្តទទួលរងការអនុវត្តវិធានការនានារបស់រដ្ឋបាលរាជធានីភ្នំពេញដូចជា ការព្រមាន ផាកពិន័យ ហើយប្រសិនណាបង្កឲ្យមានបាតុភាពធ្ងន់ធ្ងរដល់សង្គម និងទីផ្សារ ខ្ញុំបា នាងខ្ញុំសុខចិត្តឲ្យអាជ្ញាធរមានសមត្ថកិច្ចបិទទីតាំងអាជីវកម្មជាស្ថាពរព្រមទាំងទទួលខុសត្រូវទាំងស្រុង តាមទោសបញ្ញត្តិជាធរមាន។

កិច្ចសន្យានេះធ្វើឡើងចំនួន០៣ច្បាប់ និង តំកល់ទុកនៅ:

| | |
|---|---|
| -សាម៉ីខ្លួន | ០១ច្បាប់ |
| -សាលាសង្កាត់ | ០១ច្បាប់ |
| -មន្ទីរពាណិជ្ជកម្មរាជធានី | ០១ច្បាប់ |

លេខ......................................................

បានឃើញ និង បញ្ជាក់ថា
ស្នាមមេដៃនៅខាងស្តាំនេះ ពិតជារបស់
ឈ្មោះ........................................................ពិតប្រាកដមែន
ភ្នំពេញ,ថ្ងៃទី.......................ខែ.........................ឆ្នាំ ២០១
**ចៅសង្កាត់**..........................................................

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី..........ខែ...........ឆ្នាំ២០១
**ស្នាមមេដៃ**

Scanned with CamScanner

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## កិច្ចសន្យា

ខ្ញុំបាទនាងខ្ញុំឈ្មោះ.......................................................ឆ្នាំកំណើត............ជនជាតិ..............សញ្ជាតិ...............
ទីលំនៅបច្ចុប្បន្នផ្ទះលេខ................ ផ្លូវ.........................សង្កាត់........................ខណ្ឌ............................រាជធានីភ្នំពេញ
ប្រកបមុខរបរអាជីវកម្មសេវាកម្ម........................................................................................................នៅឡូត៍លេខ........
ផ្ទះលេខ..............ផ្លូវ..............ក្រុមទី..........ភូមិ.................សង្កាត់..................ខណ្ឌ.........................រាជធានីភ្នំពេញ។

ក្រោយពីទទួលបានការអនុញ្ញាតឲ្យធ្វើអាជីវកម្ម សេវាកម្ម ខ្ញុំសូមសន្យាដូចតទៅ:

១. គោរព អនុវត្តតាមគោលការណ៍ច្បាប់ បទបញ្ជា ប្រកាស សេចក្តីសម្រេច សេចក្តីណែនាំ របស់ រាជរដ្ឋាភិបាល ស្ថាប័នមានសមត្ថកិច្ច និង របស់រដ្ឋបាលរាជធានីភ្នំពេញ

២. ធានាថាពុំមានជាប់ទោសពៃរ៍ក្នុងកិច្ចការពាណិជ្ជកម្ម រដ្ឋប្បវេណី ឬ ព្រហ្មទណ្ឌ និងពុំមែនជាមន្ត្រីរាជការ ក្នុងក្រសួង ស្ថាប័នរដ្ឋណាមួយ នៃព្រះរាជាណាចក្រកម្ពុជាឡើយ ហើយព័ត៌មានទាំងឡាយ នៅក្នុងពាក្យស្នើសុំ និងឯកសារ ភ្ជាប់ជូន គឺពិត និងពេញលេញ

៣. ធានាមិនធ្វើអ្វីមួយឲ្យប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈជាពិសេសគឺមិនដាកលក់ទំនិញ ឬធ្វើសេវាដែលធ្វើឲ្យរាំងស្ទះដល់ចរាចរធ្វើដំណើរតាមដងផ្លូវ

៤. រួមចំណែក ថែរក្សាបរិស្ថាន សុខុមាលភាពសង្គម និង វប្បធម៌ ប្រពៃណីជាតិ

៥. មិនប្រកបមុខរបរអាជីវកម្ម សេវាកម្មដែលផ្ទុយពីច្បាប់រដ្ឋហាមឃាត់ដូចជា: ការជួញដូរគ្រឿងញៀន អាវុធគ្រឿងផ្ទុះ ការទិញ លក់ ទំនិញក្លែងក្លាយ ទំនិញខូចគុណភាព ទំនិញដែលជាផលបានមកពីប្រភពចោរកម្មឬអាជីវកម្មផ្លូវភេទ។ល។

៦. ត្រូវដាក់ស្លាកថ្លៃជារូបិយប័ណ្ណ(រៀល)ដើម្បីបង្ហាញជូនអតិថិជន លើមុខទំនិញអាជីវកម្ម និង សេវាកម្ម។ ក្នុងករណីមានបំណងចង់ដាក់ស្លាកថ្លៃជារូបិយប័ណ្ណបរទេសត្រូវមានការអនុញ្ញាតពីមន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញជាមុនសិន

៧. អនុវត្តកាតព្វកិច្ចបង់ពន្ធ តាមច្បាប់ជាធរមាន

៨. ផ្តល់របាយការណ៍អំពីស្ថានភាពអាជីវកម្ម សេវាកម្ម ជូនមន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ នៅរាល់ពេលណាដែលមានសំណូមពរចាំបាច់

៩.មិនទាមទារសិទ្ធិរក្សានាមករណ៍ ដែលបានស្នើសុំដាក់បញ្ចូលក្នុងលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម ។

ខ្ញុំបាទ នាងខ្ញុំសូមសន្យាថា ក្នុងករណីរូបខ្ញុំមិនអនុវត្តត្រឹមត្រូវតាមកិច្ចសន្យានេះ ខ្ញុំបាទនាងខ្ញុំសុខចិត្តទទួលរងការអនុវត្តវិធានការនានារបស់រដ្ឋបាលរាជធានីភ្នំពេញដូចជា ការព្រមាន ផាកពិន័យ ហើយប្រសិនណាបង្កឲ្យមានបាតុភាពធ្ងន់ធ្ងរដល់សង្គម និងទីផ្សារ ខ្ញុំបា នាងខ្ញុំសុខចិត្តឲ្យអាជ្ញាធរមានសមត្ថកិច្ចបិទទីតាំងអាជីវកម្មជាស្ថាពរព្រមទាំងទទួលខុសត្រូវទាំងស្រុង តាមទោសបញ្ញត្តិជាធរមាន។

កិច្ចសន្យានេះធ្វើឡើងចំនួន០៣ច្បាប់ និង តំកល់ទុកនៅ:

| | |
|---|---|
| -សាម៉ីខ្លួន | ០១ច្បាប់ |
| -សាលាសង្កាត់ | ០១ច្បាប់ |
| -មន្ទីរពាណិជ្ជកម្មរាជធានី | ០១ច្បាប់ |

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី..........ខែ...........ឆ្នាំ២០១

**ស្នាមមេដៃ**

លេខ.................................................

បានឃើញ និង បញ្ជាក់ថា

ស្នាមមេដៃនៅខាងស្តាំនេះ ពិតជារបស់

ឈ្មោះ.....................................................ពិតប្រាកដមែន

ភ្នំពេញ,ថ្ងៃទី.......................ខែ........................ឆ្នាំ ២០១

**ចៅសង្កាត់**.......................................................

Scanned with CamScanner

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## កិច្ចសន្យា

ខ្ញុំបាទនាងខ្ញុំឈ្មោះ...........................................................ឆ្នាំកំណើត............ជនជាតិ..............សញ្ជាតិ...............
ទីលំនៅបច្ចុប្បន្នផ្ទះលេខ................ ផ្លូវ.........................សង្កាត់.........................ខណ្ឌ............................រាជធានីភ្នំពេញ
ប្រកបមុខរបរអាជីវកម្មសេវាកម្ម..............................................................................................នៅឡូត៍លេខ........
ផ្ទះលេខ..............ផ្លូវ..............ក្រុមទី..........ភូមិ.................សង្កាត់...................ខណ្ឌ.........................រាជធានីភ្នំពេញ។

ក្រោយពីទទួលបានការអនុញ្ញាតឲ្យធ្វើអាជីវកម្ម សេវាកម្ម ខ្ញុំសូមសន្យាដូចតទៅ:

១. គោរព អនុវត្តតាមគោលការណ៍ច្បាប់ បទបញ្ជា ប្រកាស សេចក្ដីសម្រេច សេចក្ដីណែនាំ របស់ រាជរដ្ឋាភិបាល ស្ថាប័នមានសមត្ថកិច្ច និង របស់រដ្ឋបាលរាជធានីភ្នំពេញ

២. ធានាថាពុំមានជាប់ទោសពៃរ៍ក្នុងកិច្ចការពាណិជ្ជកម្ម រដ្ឋប្បវេណី ឬ ព្រហ្មទណ្ឌ និងពុំមែនជាមន្ត្រីរាជការ ក្នុងក្រសួង ស្ថាប័នរដ្ឋណាមួយ នៃព្រះរាជាណាចក្រកម្ពុជាឡើយ ហើយព័ត៌មានទាំងឡាយ នៅក្នុងពាក្យស្នើសុំ និងឯកសារ ភ្ជាប់ជូន គឺពិត និងពេញលេញ

៣. ធានាមិនធ្វើអ្វីមួយឲ្យប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាព សណ្ដាប់ធ្នាប់សាធារណៈជាពិសេសគឺមិនដាកលក់ទំនិញ ឬធ្វើសេវាដែលធ្វើឲ្យរាំងស្ទះដល់ចរាចរធ្វើដំណើរតាមដងផ្លូវ

៤. រួមចំណែក ថែរក្សាបរិស្ថាន សុខុមាលភាពសង្គម និង វប្បធម៌ ប្រពៃណីជាតិ

៥. មិនប្រកបមុខរបរអាជីវកម្ម សេវាកម្មដែលផ្ទុយពីច្បាប់រដ្ឋហាមឃាត់ដូចជា: ការជួញដូរគ្រឿងញៀន អាវុធគ្រឿងផ្ទុះ ការទិញ លក់ ទំនិញក្លែងក្លាយ ទំនិញខូចគុណភាព ទំនិញដែលជាផលបានមកពីប្រភពចោរកម្មឬអាជីវកម្មផ្លូវភេទ។ល។

៦. ត្រូវដាក់ស្លាកថ្លៃជារូបិយប័ណ្ណ(រៀល)ដើម្បីបង្ហាញជូនអតិថិជន លើមុខទំនិញអាជីវកម្ម និង សេវាកម្ម។ ក្នុងករណីមានបំណងចង់ដាក់ស្លាកថ្លៃជារូបិយប័ណ្ណបរទេសត្រូវមានការអនុញ្ញាតពីមន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញជាមុនសិន

៧. អនុវត្តកាតព្វកិច្ចបង់ពន្ធ តាមច្បាប់ជាធរមាន

៨. ផ្ដល់របាយការណ៍អំពីស្ថានភាពអាជីវកម្ម សេវាកម្ម ជូនមន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ នៅរាល់ពេលណាដែលមានសំណូមពរចាំបាច់

៩.មិនទាមទារសិទ្ធិរក្សានាមករណ៍ ដែលបានស្នើសុំដាក់បញ្ចូលក្នុងលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម ។

ខ្ញុំបាទ នាងខ្ញុំសូមសន្យាថា ក្នុងករណីរូបខ្ញុំមិនអនុវត្តត្រឹមត្រូវតាមកិច្ចសន្យានេះ ខ្ញុំបាទនាងខ្ញុំសុខចិត្តទទួលរងការអនុវត្តវិធានការនានារបស់រដ្ឋបាលរាជធានីភ្នំពេញដូចជា ការព្រមាន ផាកពិន័យ ហើយប្រសិនណាបង្កឲ្យមានបាតុភាពធ្ងន់ធ្ងរដល់សង្គម និងទីផ្សារ ខ្ញុំបា នាងខ្ញុំសុខចិត្តឲ្យអាជ្ញាធរមានសមត្ថកិច្ចបិទទីតាំងអាជីវកម្មជាស្ថាពរព្រមទាំងទទួលខុសត្រូវទាំងស្រុង តាមទោសបញ្ញត្តិជាធរមាន។

កិច្ចសន្យានេះធ្វើឡើងចំនួន០៣ច្បាប់ និង តំកល់ទុកនៅ:

-សាមីខ្លួន ០១ច្បាប់
-សាលាសង្កាត់ ០១ច្បាប់
-មន្ទីរពាណិជ្ជកម្មរាជធានី ០១ច្បាប់

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី..........ខែ...........ឆ្នាំ២០១

**ស្នាមមេដៃ**

លេខ.......................................................

បានឃើញ និង បញ្ជាក់ថា
ស្នាមមេដៃនៅខាងស្ដាំនេះ ពិតជារបស់
ឈ្មោះ.......................................................ពិតប្រាកដមែន
ភ្នំពេញ,ថ្ងៃទី.......................ខែ.........................ឆ្នាំ ២០១

**ចៅសង្កាត់**.......................................................

Scanned with CamScanner

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាខណ្ឌ................................

សាលាសង្កាត់.................................

លេខ:.........................................

**<u>លិខិតបញ្ជាក់ទីតាំង</u>**

-មុខរបរអាជីវកម្ម-សេវាកម្ម.....................................................................................................................

របស់ឈ្មោះ..............................................................................ភេទ.................ឆ្នាំកំណើត.........................

-ស្ថិតនៅទីតាំង..................................................ផ្លូវលេខ.............................................ភូមិ.....................................................

សង្កាត់..................................................ខណ្ឌ.........................................រាជធានីភ្នំពេញ ។

-ផ្ទៃក្រឡាសុំប្រកបអាជីវកម្ម សរុប.....................................................................................................

-ពុំប៉ះពាល់ដល់សោភ័ណ្ឌភាព សណ្តាប់ធ្នាប់របស់ទីក្រុង និងបង្កឲ្យមានកាកសំណល់ហើយ និងភាពគ្រោះថ្នាក់ឡើយ ។

-ធានានូវសុវត្ថិភាព និងពុំប៉ះពាល់ដល់សប្បាយភាពអ្នកជិតខាងដោយបង្កឲ្យមានសំឡេងឮខ្លាំងឬមានផ្សែងភ្លើងជាដើម។

-ទីតាំងស្នើសុំនេះ មានលក្ខណៈសមស្របនិង អាជីវកម្មដែលស្នើសុំខាងលើ ។

ភ្នំពេញ, ថ្ងៃទី.........ខែ.................ឆ្នាំ២០១......

**ចៅសង្កាត់**

លេខ .........................................

បានឃើញ និង ឯកភាព

ភ្នំពេញ,ថ្ងៃទី..............ខែ...........ឆ្នាំ២០១......

**អភិបាលខណ្ឌ**

CS Scanned with CamScanner

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាខណ្ឌ................................
សាលាសង្កាត់..................................
លេខ:..........................................

**<u>លិខិតបញ្ជាក់ទីតាំង</u>**

-មុខរបរអាជីវកម្ម-សេវាកម្ម.............................................................................................................................................
របស់ឈ្មោះ.........................................................................................ភេទ.................ឆ្នាំកំណើត.........................
-ស្ថិតនៅទីតាំង..................................................ផ្លូវលេខ..............................................ភូមិ....................................................
សង្កាត់..................................................ខណ្ឌ.........................................រាជធានីភ្នំពេញ ។
-ផ្ទៃក្រឡាសុំប្រកបអាជីវកម្ម សរុប...................................................................................................................................
-ពុំប៉ះពាល់ដល់សោភ័ណ្ឌភាព សណ្តាប់ធ្នាប់របស់ទីក្រុង និងបង្កឲ្យមានកាកសំណល់ហើយ និងភាពក្រខ្វក់ឡើយ ។
-ធានានូវសុវត្ថិភាព និងពុំប៉ះពាល់ដល់សប្បាយភាពអ្នកជិតខាងដោយបង្កឲ្យមានសំឡេងឮខ្លាំងឬមានផ្សែងភ្លើងជាដើម។
-ទីតាំងស្នើសុំនេះ មានលក្ខណៈសមស្របនិង អាជីវកម្មដែលស្នើសុំខាងលើ ។

ភ្នំពេញ, ថ្ងៃទី.........ខែ.................ឆ្នាំ២០១......
**ចៅសង្កាត់**

លេខ ........................................
បានឃើញ និង ឯកភាព
ភ្នំពេញ,ថ្ងៃទី..............ខែ...........ឆ្នាំ២០១......
**អភិបាលខណ្ឌ**

CS Scanned with CamScanner